مدرسة اهل البيت

صلوات الله عليهم

# សាលា
# អាស្ស់លុល-បៃត៍

## សៀវភៅសិក្សា សីលធម៌ (أَخْلاَقٌ ) ថ្នាក់ទី ៨

(អាយុ ១២-១៣ ឆ្នាំ)

قَالَ اَلنَّبِيُّ صَلَّى اللَّهُ عَلَيْهِ وَ آلِهِ : طَلَبُ اَلْعِلْمِ فَرِيضَةٌ عَلَى كُلِّ مُسْلِمٍ وَ مُسْلِمَةٍ (بحار الأنوار ج ١ ص ١٧٧)

ព្រះសាស្ដាﷺមានព្រះវចនៈថា៖ "ស្វែងរកចំណេះវិជ្ជាជាកាតព្វកិច្ចលើមុស្លីមប្រុសស្រីគ្រប់រូប ។"

# សិក្សាសាសនា

# បញ្ជីមាតិកា


មេរៀនទី ១ ហេតុអ្វីយើងត្រូវមានសីលធម៌..........................................................៥
មេរៀនទី ២ សេចក្តីស្អាត..............................................................................................៩
មេរៀនទី ៣ រឹតបន្តឹងទំនាក់ទំនងជាមួយអ្នកដទៃ.................................................. ១១
មេរៀនទី ៤ ចិញ្ចឹមជីវិតដោយវិធីហាឡាល់......................................................... ១៦
មេរៀនទី ៥ ខ្លួនទីពឹងខ្លួន.................................................................................... ១៩
មេរៀនទី ៦ ការរស់នៅក្នុងសហាគមន៍ ..................................................................២២
មេរៀនទី ៧ វប្បធម៌អ៊ីស្លាម ................................................................................២៩
មេរៀនទី ៨ អភិវឌ្ឍន៍អំណាចចិត្ត ....................................................................... ៣២
មេរៀនទី ៩ សេចក្តីទៀងត្រង់............................................................................... ៣៤
មេរៀនទី ១០ អៀស្ចសាន - ស្ហ៊ុករ៍........................................................................ ៣៦
មេរៀនទី ១១ សប្បុរសធម៌ ................................................................................... ៤០
មេរៀនទី ១២ មានយុត្តិធម៌ក្នុងខ្លួន វិនិច្ឆ័យប្រឆាំងអ៊ីស្លាម................................... ៤៥
មេរៀនទី ១៣ ស្រឡាញ់អំណាច កិត្តិយសនិងទ្រព្យសម្បត្តិ ............................... ៤៩
មេរៀនទី ១៤ ទុស្សម៉ាស្ទ (ចោទគេ) ...................................................................៥២
មេរៀនទី ១៥ តាកាប់ប៊ូរ (ឫកឡឹត) ...................................................................៥៦
មេរៀនទី ១៦ ការបោកបញ្ឆោត និង កលល្បិច ...................................................៦០
មេរៀនទី ១៧ សេចក្តីស្មោះត្រង់និងការល្មើសកិច្ចសន្យា - យ៉ាគ្វីន.......................៦៤
មេរៀនទី ១៨ ខ្ជះខ្ជាយ ..........................................................................................៦៦
មេរៀនទី ១៩ រោងកុន មើលកុន ......................................................................... ៦៩
មេរៀនទី ២០ តន្ត្រីនិងផលវិបត្តិ......................................................................... ៧២

**មេរៀនទី ១**

# ហេតុអ្វីយើងត្រូវមានសីលធម៌

ការបរិបូណ៌ដោយមារយាទល្អឬត្រឹមត្រូវ (គឺអាចារសម្បត្តិ) ជាប្រការសំខាន់ណាស់សម្រាប់អ៊ីស្លាម ។

ហេតុអ្វី ? ហេតុអ្វីយើងត្រូវប្រព្រឹត្តខ្លួនឲ្យល្អប្រពៃនិងត្រូវគោរពអ្នកដទៃ ? ហេតុអ្វីឲ្យធ្វើដូច្នេះ ?

គេអាចអធិប្បាយបានដូចតទៅ ។

កាលអល់ឡោះហ្ ﷻ បង្កើតមនុស្ស ព្រះអង្គ ﷻ បានបង្កើតវាជាពីរប៉ែក ។ មួយប៉ែកប្រៀបបាននឹងសំបករថយន្ត ប្រើសម្រាប់ដាក់អ្វីៗ គេហៅវាថា**ដងខ្លួន** ។ មួយប៉ែកទៀតប្រៀបបាននឹងយន្តឬម៉ាស៊ីន ពោលគឺ **វិញ្ញាណ** ។

ដងខ្លួនឬសំបកខ្លួនយើងទាមទារការមើលថែរក្សា ។ គេត្រូវបំប៉នវា ត្រូវផ្តល់កម្តៅឲ្យវា ដើម្បីនឹងកុំវាឈឺថ្កាត់ឬរងការឈឺចាប់ ។

វិញ្ញាណ ដែលគេហៅថា ណាហ្វ៍ស៍ (نَفْس) នោះក៏ទាមទារការមើលថែរក្សាដែរ ពុំនោះទេវានឹងឈឺថ្កាត់ដែរ ។ ដើម្បីថែរក្សាវិញ្ញាណនេះ ត្រូវស្តាប់ ត្រូវគិត ត្រូវគោរពនិងត្រូវជួយ ។ ពេលយើងជួយគេ យើងមានអារម្មណ៍រីករាយ តែមិនមែនខ្លួនទេដែលរីករាយនោះ ។ មិនមែនដៃទេ មិនមែនជើងទេ មិនមែនក្បាលទេដែលរីករាយនោះ តែអ្វីមួយផ្សេង ។ អ្វីនោះគឺណាហ្វ៍ស៍យើង ។ សីលធម៌ (អាក់ឡាក់) ក្នុងអ៊ីស្លាមជាចំណីរបស់វិញ្ញាណ បើយើងបំប៉នវាទៀងទាត់ វានឹងមានសុខភាពល្អ ។

ប្រការទាំងនេះនាំមកនូវសំណួរមួយទៀត ។ សាសនាឯទៀតក៏ណែនាំឲ្យចេះគោរពដែរ ។ ដូច្នេះហេតុអ្វីយើងមិនតាមសាសនាទាំងនោះ ?

សាសនាទាំងអស់ដែលអល់ឡោះហ្ ﷻ ដាក់មកនោះត្រូវនាំមក ដោយមានច្បាប់ទូន្មានដោយផ្ទាល់ ។ សាសនានីមួយៗបានពង្រីកនិងបានបន្ថែមបន្តិចម្តងៗលុះអ៊ីស្លាមផុសឡើង ច្បាប់ទូន្មានទាំងអស់ត្រូវសម្រិតឲ្យសុក្រឹតជាស្រេច ។ សាសនាឯទៀតត្រូវកែប្រែដោយមនុស្សដោយវិធីនីមួយ មានតែសាសនាអ៊ីស្លាមទេ

ដែលនៅតែបរិសុទ្ធដដែល ដូចកាលពីយប់ដែលគេបានបើកឲ្យដឹងសាសនាអ៊ីស្លាម នោះម្ល៉េះ ។ បានសេចក្តីថាពេលអ្នកគោរពសីលធម៌ដែលអ៊ីស្លាមបង្គាប់នោះ អ្នកនឹងបំប៉នណាហ្វ៍ស៍របស់អ្នកដោយចំណីដែលប្រសើរបំផុត ។

ព្រះសាស្តាមូហាំម៉ាដ៉ូﷺមានព្រះវចនៈថា៖ "ខ្ញុំﷺត្រូវចាត់បញ្ជូនមកដើម្បីដុសខាត់ចរិយាមារយាទ (គឺសីលធម៌) អស់លោកឲ្យសុក្រឹតឥតខ្ចោះ[1] ។"

គេធ្លាប់ថាដែរថាភ្នែកជាបង្អួចរបស់ដួងព្រលឹង ។ បានសេចក្តីថាអ្វីក៏ដោយដែលអ្នកសម្លឹងមើល វានឹងប៉ះពាល់ដោយផ្ទាល់ដល់ទៅណាហ្វ៍ស៍របស់អ្នក ។

បើអ្នកមើលប្រការហ្រាំ អ្នកធ្វើឲ្យគុណភាពណាហ្វ៍ស៍អ្នកអន់ថយ តែបើអ្នកទប់ខ្លួនបាន មិនមើលប្រការហ្រាំទេ អ្នកនឹងពង្រឹងជំនឿនៅក្នុងណាហ្វ៍ស៍អ្នក ។

បញ្ហាក្នុងសម័យសព្វថ្ងៃនេះគឺគេថែរក្សាខ្លួនបានល្អ តែមិនយកចិត្តទុកដាក់អំពីវិញ្ញាណសោះ ។ ហេតុដូច្នេះឯងបានជាវិញ្ញាណយើងរងការខូចខាត មនុស្សមិនដឹងខ្លួនទេ ។ យូរៗទៅវាបណ្តាលឲ្យមានការខូចខាតធំនិងយូរអង្វែង ។

គ្រូពេទ្យព្យាបាលណាហ្វ៍ស៍ប្រសើរបំផុត ពោលគឺ បណ្តាអ្នកដែលដាក់ច្បាប់និងគំរូឲ្យយើងតាម គឺម៉ាក់ស៊ូមីន (مَعْصُومِينَ) ទាំង ១៤ អង្គعليهم السلام ។

ពេលនេះ យើងនឹងពិនិត្យណាហ្វ៍ស៍នេះដោយល្អិតល្អន់ តើវាមានលក្ខណៈដូចម្តេច ។ នៅក្នុងព្រះគម្ពីរគួរអាន អល់ឡោះហ្ទ៍ﷻប្រាប់យើងថាយើងមិនអាចយល់ណាហ្វ៍ស៍និងការបង្កើតវាបានទេ ។ ក៏ប៉ុន្តែ គេបានប្រាប់យើងឲ្យដឹងថាណាហ្វ៍ស៍មានច្រើនប្រភេទ ។

ជាទូទៅ ណាហ្វ៍ស៍មានបីមុខសំខាន់ៗ ហៅថា៖

ក. ណាហ្វ៍ស៍ អាល់-អាំម៉ារ៉ោះត៍ (النَّفْسُ الْأَمَّارَةُ) - នេះគឺណាហ្វ៍ស៍អាក្រក់បំផុត ។

---

[1] . " وَحَدَّثَنِي عَنْ مَالِكٍ، أَنَّهُ قَدْ بَلَغَهُ أَنَّ رَسُولَ اللَّهِ صلى الله عليه وسلم قَالَ " بُعِثْتُ لأُتَمِّمَ حُسْنَ الأَخْلاَقِ (យ៉ាស្ញ៉ាបានប្រាប់ខ្ញុំតមកពីម៉ាលិកថាលោកបានឮព្រះសាស្តាﷺរបស់អល់ឡោះហ្ទ៍ﷻមានព្រះវចនៈថា៖ "ខ្ញុំﷺត្រូវចាត់បញ្ជូនមកដើម្បីធ្វើឲ្យចរិយាមារយាទសុក្រិតឥតខ្ចោះ ។" (ដកស្រង់ពី *មូវ៉ាត់ត្តក៍ ម៉ាលិក (موطأ مالك)* ។"), Muwatta Malik (موطأ مالك), Arabic reference: Book 47, Hadith 1643, USC-MSA web (English) reference: Book 47, Hadith 8

វានាំបុគ្គលទៅរកប្រការអាក្រក់ ។ ដល់ដំណាក់ការនេះ បុគ្គលមានតម្លៃថោកជាងសត្វសម្រាប់អល់ឡោះហ្ទ៏ﷻ ។ បុគ្គលគិតតែប្រយោជន៍ផ្ទាល់ខ្លួន មើលប្រការហាមឃាត់ មិនអើពើអ្នកដទៃទេ ។ នេះគឺរោគសញ្ញារបស់ជម្ងឺនេះ ដូចក្អកនិងគ្រុនជារោគសញ្ញារបស់ជម្ងឺផ្តាសាយដែរ ។

ខ. ណាហ្វ៍ស៍ អាល់-ឡៅវ៉ាម៉ាស្ទ៌ (اَلنَّفس اللَّوَّامَة) - ដល់ដំណាក់ការនេះ យើងមិនអាក្រក់ទេ តែយើងនៅតែធ្វើខុស ។ គេហៅណាហ្វ៍ស៍នេះថាសតិសម្បជញ្ញៈ ព្រោះពេលណាគេធ្វើប្រការអាក្រក់ ពេលនោះណាហ្វ៍ស៍នេះបន្ទោសយើង មិនឲ្យយើងធ្វើប្រការនោះទេ វាប្រាប់យើងឲ្យស្តាយក្រោយនិងរាងចាល ។

គ. ណាហ្វ៍ស៍ អាល់-មុត្មម៉ាអ៊ីនណាស្ទ៌ (اَلنَّفْسُ الْمُطْمَئِنَّةُ) - កំណាក់ការដែលត្រូវទៅដល់ នេះគឺគោលដៅក្នុងជីវិតយើង ។ ដំណាក់ការត្រេកអរបរិបូររបស់អល់ឡោះហ្ទ៏ﷻ (ដំណាក់ការដែលអល់ឡោះហ្ទ៏ﷻពេញចិត្តជាទីបំផុត) ។ មិនសាងបាបសោះនិងត្រេកអរធ្វើប្រការល្អ ។ វិញ្ញាណនេះឯងដែលត្រូវមានក្នុងថ្ងៃអាស៊ូរ៉អ៊ុ (عَاشُورَاء) កាលអ៊ីមុាំហ៊ូសែន៍ﷺបានដាក់ដាវចុះហើយបានឮសម្លេងមួយប្រាប់ព្រះអង្គﷺថា៖ "ឱវិញ្ញាណត្រេកអរអើយ ! ចូរអ្នកវិលត្រឡប់ទៅរកព្រះម្ចាស់ﷻរបស់អ្នកវិញ ដោយពេញចិត្ត[នឹងខ្លួនឯង] និងដោយសព្វព្រះហឫទ័យព្រះអង្គﷻ ។"

ព្រះសន្តអ៊ីមុាំអាលីﷺមានវចនៈថា៖ "ណាហ្វ៍ស៍ដូចសេះព្រៃដែលលោកជិះ ។ បើលោកប្រហែសខ្លួនមួយភ្លែត វានឹងគ្រវាត់លោកធ្លាក់មកដី ។"
"ទប់វិញ្ញាណ[ឬខ្លួន]កុំឲ្យឃ្លានជាឃ្មីហ្វាដ្ទ៍ធំបំផុត ។"
ត្រង់នេះ ព្រះអង្គﷺចង់និយាយអំពីណាហ្វ៍ស៍ អាល់-អាំម៉ារ៉េាះត៌ ។

## លំហាត់

ចូរពន្យល់ហ្គាឌីស្ហខាងលើនេះដោយប្រើពាក្យផ្ទាល់ខ្លួនរបស់អ្នក ។

## មេរៀនទី ២

# សេចក្តីស្អាត

យើងបានអធិប្បាយអំពីសេចក្តីស្អាតច្រើនលើកហើយក្នុងមេរៀនមុនៗ ។

ថ្វីដ្បិតរក្សាសេចក្តីស្អាតនិងសេចក្តីបរិសុទ្ធ (ត៏ហ្វារ៉ោះត៏) ជាប្រការសំខាន់ មេរៀននេះផ្តោតទៅលើលក្ខណៈមួយទៀតរបស់សេចក្តីស្អាត ។

យើងមិនត្រូវចាត់ទុកសេចក្តីស្អាតជាប្រការមួយ ដែលយើងត្រូវធ្វើឬមិនត្រូវធ្វើនោះទេ តែយើងត្រូវចាត់ទុកសេចក្តីស្អាតជាមួយប៉ែករបស់យើង ។ សេចក្តីស្អាតត្រូវតែនៅជាប់ក្នុងគ្រប់សកម្មភាពរបស់យើង នៅជាប់ក្នុងគ្រប់គំនិតរបស់យើងនិងនៅជាប់ក្នុងគ្រប់ទង្វើរបស់យើង ។

យើងមិនត្រឹមតែរក្សាខ្លួនប្រាណយើងតែម្យ៉ាងឲ្យស្អាតនោះទេ តែយើងត្រូវរក្សាគំនិតនិងការប្រព្រឹត្តរបស់យើងឲ្យស្អាតដែរ ។

វិញ្ញាណយើងប្រៀបបាននឹងទឹកថ្លា អ្វីដែលផ្ទុកទឹកថ្លានេះ (គឺខ្លួនយើង) ប្រៀបបាននឹងថូ ។ អ្វីៗដែលយើងមើលឃើញតាមភ្នែកយើងចូលទៅក្នុងទឹកវិញ្ញាណយើង ។ បើយើងមើលប្រការអាក្រក់ យើងនឹងធ្វើឲ្យទឹកទៅជាកខ្វក់ ដូច្នេះវិញ្ញាណយើងនឹងទៅជាកខ្វក់ ។ ពេលប្រការនេះកើតឡើង យើងនឹងចាប់ផ្តើមចង់ឃើញនិងចង់ធ្វើប្រការនានាដែលនឹងធ្វើឲ្យយើងកាន់តែខូចខាតច្រើន ទាល់តែទឹកវិញ្ញាណយើងទៅជាស្រអាប់ទៅៗ ទីបំផុតយើងនឹងថប់ដង្ហើមហើយផុងខ្លួននៅក្នុងកម្អែលនោះ ។

យើងត្រូវការពារវិញ្ញាណយើងកុំឲ្យវាប្រឡាក់ ដោយបណ្តោយឲ្យអ្វីដែលប្រកបដោយគុណធម៌តែម្យ៉ាងចូលទៅក្នុងវិញ្ញាណនោះ ។

យើងអាចធ្វើបែបនេះបានដោយវិធីមួយ គឺនៅក្នុងសភាពត៏ហ្វារ៉ោះត៏ (បរិសុទ្ធ) ។ ពេលយើងមានទឹកវូឌុអ៏ ឬងូតទឹកគុស្លូលឲ្យទៀងទាត់ថ្ងៃសុក្រឬថ្ងៃស៊ូណាត់ យើងនឹងរក្សាចិត្តយើងសម្រាប់អល់ឡោះហ្ ﷻ ទង្វើនេះជាខែលការពារយើងពីស្ហៃតន ﷺនិងពីគំនិតលាមក ដែលវា ﷺលួចដាក់ទៅក្នុងចិត្តយើងដោយ

ឧបាយកល ។

ព្រះសាស្តាមូហាំម៉ាដ់ﷺមានព្រះវចនៈថា៖ "នឹងមានថ្ងៃមួយមនុស្សនឹងកខ្វក់ខាងក្នុងតែស្អាតខាងក្រៅ ។ ពួកគេនឹងស្រេកឃ្លានទ្រព្យលោកិយ មិនចង់បានអ្វីដែលនៅឯអល់ឡោះហ្ ﷻទេ ។ ពួកគេប្រតិបត្តិសាសនាសម្រាប់តែបង្ហាញគេទេ ។ ពួកគេនឹងធ្វើសក្ការៈអល់ឡោះហ្ ﷻដូចបុគ្គលដែលកំពុងលង់ទឹក អល់ឡោះហ្ ﷻនឹងមិនស្តាប់ការធ្វើសក្ការៈរបស់ពួកគេទេ ។"

ទង្វើសាមញ្ញដូចជាយកទឹកវូឌុអ៍មុនចូលដេកជាដើម ជាទង្វើមួយដែលគេបានណែនាំឲ្យធ្វើកុំខាន ។ បើអ្នកធ្វើទង្វើនេះ ដូចអ្នកបានធ្វើសក្ការៈពេញមួយយប់ ។

ទង្វើឯទៀតទាក់ទងនឹងសេចក្តីស្អាតប៉ែកខាងក្រៅ ។ គេតែងតែប្រាប់យើងឲ្យចេះសម្អាតខ្លួននិងសំលៀកបំពាក់ តែរក្សាផ្ទះសម្បែងនិងបរិស្ថានយើងឲ្យស្អាតជាប្រការសំខាន់ដែរ ។ គ្រឿងសម្គាល់មុស្លីមគឺពេលគេប្រើរបស់នីមួយ គេទុករបស់នោះវិញដោយធ្វើឲ្យវាស្អាតលើសមុនពេលយកវាមកប្រើ ។ បានសេចក្តីថាយើងត្រូវប្រព្រឹត្តខ្លួនជាគំរូសម្រាប់បណ្តាអ្នកមិនមែនមុស្លីម កុំចោលសំរាមតាមផ្លូវ រៀបចំផ្ទះឲ្យមានរបៀបរៀបរយ ។ បើយើងធ្វើបែបនេះ គេនឹងមិនចង្អុលយើងទេ នឹងមិនស្តីបន្ទោសយើងទេ ។ ពុំនោះទេ យើងនឹងធ្វើឲ្យអ៊ីស្លាមមានកេរ្តិ៍ឈ្មោះដែលអ៊ីស្លាមសមនឹងបាន ។

## មេរៀនទី ៣

# រីតបន្ដឹងទំនាក់ទំនងជាមួយអ្នកដទៃ

ជីវិតជាដំណើរផ្លូវឆ្ងាយពីអង្រឹងទៅផ្នូរ ។ ក្នុងពេលធ្វើដំណើរនេះយើងនឹងបានជួបមនុស្សសន្ធឹកសន្ធាប់ យើងនឹងភ្លេចមនុស្សខ្លះមុនពួកគេចេញផុតពីខ្សែភ្នែកយើង ។ មនុស្សខ្លះទៀត ផ្ទុយទៅវិញ យើងចងចាំពួកគេទោះបីក្រោយពីពួកគេបានឆ្លងកាត់មហាសាគរដ៏សែនឆ្ងាយក៏ដោយ ។

បុគ្គលម្នាក់ៗដែលយើងនឹងបានជួបប្រទះនោះនឹងធ្វើឲ្យយើងទទួលបាន នូវអ្វីមួយ ។ យើងនឹងប្រព្រឹត្តចំពោះមនុស្សទូទៅដោយអាកប្បកិរិយាផ្ទាល់ខ្លួន និងខុសពីអ្នកដទៃ ឯអ្នកដទៃក៏ប្រព្រឹត្តចំពោះខ្លួនយើងតាមអាកប្បកិរិយារបស់យើងដែរ ។

ជាក់ស្ដែងគឺមនុស្សមួយក្រុមដែលជាគ្រួសារយើង ។ បើយើងដួល មនុស្សទាំងអស់ទុកយើងចោល គ្រួសារយើងនឹងជួយលើកយើងឡើងឈរវិញ ។

## គ្រួសារ

គ្រួសារជាក្រុមមនុស្សមួយក្រុម ជាប់ទាក់ទិនគ្នាដោយទំនាក់ទំនងពិសេស ។ ទំនាក់ទំនងនោះអាចជាខ្សែលោហិតឬក្រសែផ្សេង ។ ទោះបីគ្រួសារយើងប្រព្រឹត្តមកលើខ្លួនយើងដូចម្ដេចក៏ដោយ ឬទោះបីយើងពិបាកយកចិត្តគ្រួសារយើងក៏ដោយ យើងត្រូវតែកុំធ្វើឲ្យគ្រួសារយើងបែបាក់គ្នានិងរក្សាទំនាក់ទំនងជាមួយសាច់ញាតិយើង ។

ជួនកាលពិបាកស៊ូទ្រាំការបំពារបំពាន ឬការជេរប្រទេចរបស់សាច់ញាតិយើង តែបើអ្នកធ្វើល្អតបទៅលើអ្នកកាចដាក់យើង អ្នកនឹងសម្ដែងឲ្យឃើញថាអ្នកគ្រាន់បើជាង អល់ឡោះហ្ជ៍ﷻនឹងតបស្នងអ្នកដែលបានប្រព្រឹត្តខ្លួនជាគំរូដែលពួកគេគប្បីយកតម្រាប់តាម ។ អល់ឡោះហ្ជ៍ﷻមានព្រះបន្ទូលក្នុងស៊ូរ៉ោះត៍ អាន់-ណាស្ល៍ អាយ៉ាស្ទ៍ 90 (16:90) ថា៖

۞إِنَّ ٱللَّهَ يَأْمُرُ بِٱلْعَدْلِ وَٱلْإِحْسَٰنِ وَإِيتَآيِٕ ذِى ٱلْقُرْبَىٰ وَيَنْهَىٰ عَنِ ٱلْفَحْشَآءِ وَٱلْمُنكَرِ وَٱلْبَغْىِ ۚ يَعِظُكُمْ لَعَلَّكُمْ تَذَكَّرُونَ ﴿٩٠﴾

*90. អល់ឡោះហ្វ៍ដាក់បញ្ជាឲ្យប្រព្រឹត្តដោយយុត្តិធម៌ ឲ្យធ្វើអំពើល្អនិងឲ្យប្រគល់ឲ្យញាតិសន្តាន[នូវសិទ្ធិពួកគេ] (គឺដោយមានចិត្តទូលាយ) ។ ព្រះអង្គហាមប្រព្រឹត្តអសីលធម៌ អំពើអាក្រក់និងអំពើកំណាច ។ ព្រះអង្គដាស់តឿនពួកអ្នកដើម្បីពួកអ្នកនឹងយកចិត្តទុកដាក់ ។*

ចូរនឹកដល់ពាក្យពេជន៍របស់ព្រះសន្តអ៊ីម៉ាំទី ៤ របស់យើងصلوات الله عليه والسلام នៅក្នុងសាត្រា ស្ហ៊ីហ្វ៊ាស្ហ៍ កាមីឡាស្ហ៍ (صحيفة كاملة) គឺ៖ "អល់ឡោះហ្វ៍عز وجلអើយ សូមព្រះអង្គعز وجلធ្វើឲ្យទូលព្រះបង្គំជាខ្ញុំصلوات الله عليه والسلامមានចិត្តមេត្តាប្រព្រឹត្ត ដោយស្មោះចំពោះបណ្តាអ្នកដែលមិនស្មោះចំពោះទូលព្រះបង្គំជាខ្ញុំصلوات الله عليه والسلام ។"

នៅជាមួយគ្រួសារអ្នកជាករណីយកិច្ចរបស់អ្នក ទោះបីគេខុសក៏ដោយ ។ ចូរកុំបណ្តោយឲ្យការប្រកែប្រកាន់ខ្លួន ឬនយោបាយជ្រៀតជ្រែកមកក្នុងចិត្តអ្នកឡើយ ។ ចូរប្រព្រឹត្តដោយរបៀបនីមួយដែលអល់ឡោះហ្វ៍عز وجلទ្រង់សព្វព្រះហឫទ័យ អ្វីៗនឹងប្រសើរជាមិនខាន ។

## អ្នកជិតខាង/មនុស្សចាស់

គោរពអ្នកជិតខាងមិនបានសេចក្តីថាអ្នកដែលរស់នៅក្បែរផ្ទះទេ តែបណ្តាអ្នកដែលរស់នៅជុំវិញផ្ទះអ្នក (៤០ ផ្ទះ) ។ យើងត្រូវគិតដល់បណ្តាអ្នកជិតខាងយើង ត្រូវព្យាយាមមិនធ្វើអ្វីដែលរំខានគេទេ ។ យើងត្រូវជួយគេដែរដោយវិធីផ្សេងៗ ពោលគឺ ដោយលះបង់ពេលវេលា បើចាំបាច់ត្រូវជួយគេដោយថវិកា ។

ព្រះសាស្តាមូហ៊ាំម៉ាដ់صلى الله عليه وآله وسلمមានសេចក្តីគួរសមចំពោះអ្នកជិតខាងណាស់ ព្រះអង្គបានធ្វើល្អច្រើនប្រការសម្រាប់បណ្តាអ្នកជិតខាង ដល់ថ្នាក់មុស្លីមសម័យនោះខ្លាចត្រូវរាប់បញ្ចូលអ្នកជិតខាងក្នុងមរតកជាវ៉ាឃ្លីបដែរពេលពួកគេស្លាប់ (ពោលគឺក្នុងការចែកមរតក) ។

យើងអាចគោរពអ្នកជិតខាងបានដោយវិធីមួយ គឺជូនគេនូវហាល់វ៉ា (حلوى ចំណីផ្អែម) ឬស្ករគ្រាប់ជាដើមពេលយើងធ្វើបុណ្យនីមួយ ដូចជាបុណ្យអ៊ីឌុល-ហ្វិទ្រី ជាដើម ។ ធ្វើដូច្នេះ យើងអាចធ្វើឲ្យគេឃើញបានថាអ៊ីស្លាមជាសាសនាប្រកប ដោយសន្តិភាព ថាជនមុស្លីមជាមិត្តនិងមានទឹកចិត្តចេះជួយមនុស្សដូចគ្នា ។

សេចក្តីគោរពមនុស្សចាស់ជាប្រការសំខាន់ណាស់ ។ មនុស្សចាស់មិនត្រឹមតែជាមនុស្សជរាទេ តែជាមនុស្សដែលមានគុណបំណាច់ក្នុងការផ្តល់ផលប្រយោជន៍ដល់សហគមន៍ ។ លោកបានប្រកបកិច្ចការយ៉ាងលំបាក ដែលយើងមានសព្វគ្រប់ជុំវិញខ្លួនយើងសព្វថ្ងៃនេះដោយសារតែអស់លោក ។ ត្រឹមត្រូវទេ ដែលពេលអស់លោកមានអាយុច្រើនពុំអាចប្រកបកិច្ចការបាននោះ យើងបំភ្លេចលោកទុកលោកចោលនៅឯមន្ទីរសម្រាប់មនុស្សចាស់ ? ពេលនេះយើងនៅក្មេង តែយើងនឹងមានអារម្មណ៍ដូចម្តេចប្រសិនបើ ក្រោយពីបានរស់នៅនិងបានលះបង់មួយប៉ែកនៃជីវិតដើម្បីផ្តល់ផលប្រយោជន៍ដល់សហគមន៍ យុវជនយើងចោលយើង មិនអើពើយើង ភ្លេចយើង ?

យើងមិនត្រឹមតែគោរពរៀមច្បងយើងតែម្យ៉ាងទេ តែយើងត្រូវអរគុណលោកស្តាប់យោបល់លោកដែរ ។ ទោះបីយើងចេះដឹងប៉ុណ្ណាក៏ដោយ រៀមច្បងយើងធ្លាប់មានបទពិសោធន៍ច្រើន ។ ព្រះសន្តអ៊ីមុាំអាលី عليه الصلوات الله والسلام មានវចនៈថា៖ "អ្វីដែលប្រសើរលើសការចេះដឹងគឺបទពិសោធន៍ ។"

អល់ឡោះហ្ទ៍ عزّ وجلّ បានប្រាប់យើងថាលំអដ៏ឆ្នើមរបស់សហគមន៍ គឺប្រជារាស្រ្តចំណាស់របស់សហគមន៍នោះ ។ អស់លោកជាបុព្វហេតុនៃសេចក្តីល្អដ៏ច្រើន ប្រសិនបើយុវជនដឹងថាអល់ឡោះហ្ទ៍ عزّ وجلّ ស្រឡាញ់មនុស្សចាស់ខ្លាំងប៉ុណ្ណានោះ ពួកគេប្រាកដជានឹងមិនចោលអស់លោកទេ ទោះមួយភ្លែតក្តី ។

## អ្នកតូចទាប/អ្នកឈឺ/បម្រើគេ

បុគ្គលទាំងនេះនៅក្នុងឋានៈនីមួយក្រោមអាជ្ញាធររបស់អ្នក និងក្រោមការគ្រប់គ្រងរបស់អ្នក ។ គោរពនិងគិតដល់អ្នកផងទាំងឡាយជាទង្វើមួយ តែប្រព្រឹត្ត

ចំពោះអ្នកផងទាំងពួងជាទង្វើមួយផ្សេង ។

គ្រាមួយ មានបុរសក្រអ្នកចម្ការម្នាក់ ។ សំលៀកបំពាក់គាត់ប្រឡាក់ដីនិងរហែក ។ គាត់មកម៉ាស់យ៉ិដ្ទ អង្គុយជិតបុរសអ្នកមានម្នាក់ ។ បុរសអ្នកមានទាញសំលៀកបំពាក់ទៅម្ខាងកុំឲ្យប៉ះបុរសអ្នកក្រ ។ ព្រះសាស្តាﷺបានឃើញទង្វើនេះ ព្រះអង្គﷺបានសួរបុរសអ្នកមានថាហេតុអ្វីបានជាធ្វើដូច្នេះ ។ គាត់ខ្លាចថាពេលប៉ះបុរសអ្នកក្រនោះគាត់នឹងក្លាយទៅជាអ្នកក្រដូចបុរសនោះដែរ ? បុរសអ្នកមានសូមទោសហើយបានសូមចែកទ្រព្យពាក់កណ្តាលរបស់គាត់ ឲ្យទៅបុរសដែលគាត់បានប្រមាថនោះ ។ បុរសអ្នកក្របដិសេធដោយថាគាត់ខ្លាចថា បើគាត់ទទួលយកទ្រព្យបុរសអ្នកមាននោះ គាត់នឹងទៅជាបុគ្គលប្រកាន់ខ្លួនដែរ ភ្លេចគោរពអ្នកមិនមានដូចគ្នា ។ សឲ្យឃើញថាយើងមិនត្រឹមតែគោរពអ្នកដទៃតែម្យ៉ាងទេ តែត្រូវប្រព្រឹត្តចំពោះអ្នកដទៃស្មើនឹងខ្លួនយើងដែរ ។

យើងភាគច្រើនមិនដែលទៅមន្ទីរពេទ្យទេ ដើម្បីទៅលេងនិងលើកទឹកចិត្តអ្នកជម្ងឺ ។ យើងចាត់ទុកថាសុខភាពដែលអល់ឡោះហ៊្វ ﷻប្រទានឲ្យយើងនោះជារបស់យើងដាច់មុខ ។ មនុស្សភាគច្រើនមិនមានសំណាងដូចយើងទេ ។ គេមិនអាចដឹងមុនបានទេ យើងអាចធ្លាក់ខ្លួនឈឺថ្ងៃស្អែក ឬមានគ្រោះថ្នាក់ ។ វិធីមួយសម្រាប់អរព្រះគុណអល់ឡោះហ៊្វ ﷻដែលព្រះអង្គ ﷻអាណិតអាសូរយើងនោះ គឺទៅលេងអ្នកជម្ងឺ សម្តែងឲ្យគាត់ឃើញថាគេមិនភ្លេចគាត់ទេ និយាយលេងជាមួយគាត់និងជូនអំណោយបន្តិចបន្តួចដល់គាត់ ដើម្បីនឹងកុំឲ្យគាត់មានអារម្មណ៍កណ្តោចឯកា ។ ធ្វើដូច្នេះ អ្នកសម្តែងប្រាប់អល់ឡោះហ៊្វ ﷻថាអ្នកដឹងព្រះគុណព្រះអង្គ ﷻ ថាអ្នកចំណាយទ្រព្យនិងសុខភាពអ្នក សម្រាប់ជួយបណ្តាអ្នកដែលពុំមានសំណាងដូចអ្នកដែរ ។

អ្នកបម្រើការផ្ទះមិនមែនទាសៈទាសីទេ តែជាមនុស្សដែលប្រកបកិច្ចការឲ្យអ្នក ។ បើអ្នកមានស្ត្រីធ្វើការផ្ទះឬមានអ្នកបោសសំអាតផ្ទះ ឬមានអ្នកបម្រើការឲ្យអ្នក អ្នកនោះធ្វើការឲ្យអ្នក ។ យើងមិនត្រូវប្រព្រឹត្តចំពោះអ្នកបម្រើកិច្ចការផ្ទះឬអ្នកស៊ីឈ្នួលដូចមនុស្សអន់ឬទាបជាងយើងទេ ។ ធ្វើបែបនេះបានសេចក្តីថាយើង

ប្រកាន់ខ្លួននិងក្រអឺតក្រទម ។ សៃយីដ្ហាស្វហ្វាទិ៍ម៉ាស្វ ﷺមានស្ត្រីអ្នកបម្រើកិច្ចការផ្ទះម្នាក់ ។ ថ្វីដ្បិតព្រះនាង ﷺអាចអង្គុយមួយកន្លែងបានពេលស្ត្រីបម្រើធ្វើការនោះ តែព្រះនាង ﷺជួយធ្វើកិច្ចការ ។ ថ្ងៃមួយព្រះនាង ﷺធ្វើការ ថ្ងៃបន្ទាប់ជាវេនស្ត្រីបម្រើធ្វើការ ។ ពេលបរិភោគ ទាំងអស់គ្នាបរិភោគជុំគ្នាលើតុតែមួយ ។ យើងត្រូវប្រព្រឹត្តចំពោះបណ្ដាអ្នកធ្វើការឲ្យយើងបែបនេះឯង ។

**មេរៀនទី ៤**

# ចិញ្ចឹមជីវិតដោយវិធីហាឡាល់

យើងធ្លាប់តែវែកញែកឲ្យដឹងហាឡាល់ ដឹងហារ៉ាំពេលយើងនិយាយអំពីវត្ថុដូចជាហារ៉ាំបរិភោគរបស់នេះ សាច់នេះហាឡាល់ ជាដើម ។ តែយើងមិនគិតអំពីទង្វើរបស់យើងសោះ ។

ទង្វើ ដូចវត្ថុដែរ អាចចាត់ទុកបានថាជាទង្វើហារ៉ាំឬហាឡាល់ ។

បើខ្ញុំរើសប្រាក់បាន 5€ តាមផ្លូវទៅសាលារៀន ខ្ញុំអាចយកវាទុកឬខ្ញុំអាចយកវាទៅឲ្យនគរបាលបាន ។

បើខ្ញុំជិះរថភ្លើងជានិច្ចកាល ខ្ញុំមានមធ្យោបាយចៀសវាងបង់ថ្លៃសំបុត្រ តើខ្ញុំគួរធ្វើឬមិនគួរធ្វើ ?

យើងអាចជួបប្រទះរឿងបែបនេះគ្រប់ពេល យើងត្រូវជ្រើសរើសយកទង្វើត្រឹមត្រូវ ។

ជីវភាពរបស់យើងគឺរបៀបរស់នៅរបស់យើង និងរបៀបចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់យើង ។

សម្រាប់មនុស្សធំគឺរបៀបរកប្រាក់ចំណូល របៀបជួយអ្នកដទៃ របៀបប្រព្រឹត្តខ្លួនចំពោះអ្នកដទៃ មធ្យោបាយបង់ពន្ធ មធ្យោបាយគ្រប់គ្រងមុខរបររបស់ខ្លួន បានបង់ឃុំមស៍ឬទេ ។ល ។

សម្រាប់ក្មេងៗ នៅសិក្សានៅឡើយ គឺរបៀបប្រព្រឹត្តខ្លួនចំពោះមិត្រភក្តិ របៀបធ្វើកិច្ចការដែលគ្រូដាក់ឲ្យធ្វើនៅឯផ្ទះ របៀបឆ្លើយដោះសាពេលពួកគេពុំបានធ្វើប្រការណាមួយ ។ល ។

អ៊ីស្លាមទាញអារម្មណ៍ឲ្យយកចិត្តទុកដាក់អំពីទង្វើទាំងនេះ ឲ្យវាស្របតាមច្បាប់ស្ហារីអ៊ាស្ហ៍អ៊ីស្លាម ពោលគឺ ចូរធានាថាទង្វើទាំងនេះជាទង្វើហាឡាល់ ។

មនុស្សភាគច្រើនមិនយកចិត្តទុកដាក់អំពីមធ្យោបាយធ្វើទេ ។ ឧទាហរណ៍ ខ្ញុំមិនខ្វល់អំពីការលួចរបស់គេទេ ឲ្យតែខ្ញុំដាក់ទានឲ្យគេបន្តិចវាជាការស្រេច ។ ខ្ញុំមិន

ខ្វល់បង់ឃុំមស់ទេ ឲ្យតែខ្ញុំស្ទុំឡាត់វាជាការស្រេច ។ ការប្រព្រឹត្តបែបនេះមិនស័ក្តិសមនឹងអ៊ីស្លាមទេ យុវជនក្នុងសហាគមន៍ត្រូវដឹងនិងត្រូវប្រាប់គ្នាឲ្យដឹងប្រការនេះជាគំរូ ។

ហេតុអ្វីយើងត្រូវចិញ្ចឹមជីវិតដោយវិធីហ្ហាឡាល់ ? ខុសអ្វីក្នុងការបោកប្រាស់គេនោះ ?

បើយើងបោកប្រាស់គេ យើងនឹងឈ្នះដោយធ្វើឲ្យគេខូចខាត ។

បើយើងធ្វើការរួមគ្នា បានប្រាក់ ១០ រៀល ។ ត្រូវចែកប្រាក់នេះស្មើគ្នា តែបើខ្ញុំចែកឲ្យអ្នក ៤ រៀលទុក ៦ រៀលដោយមិនឲ្យអ្នកដឹងទេ ខ្ញុំនឹងបាន ១ រៀលលើសអ្នក អ្នកនឹងបាត់បង់ប្រាក់ ១ រៀល ។

ដូចគ្នាដែរ អល់ឡោះហ៍ عزّوجلّ ឲ្យយើងមានពេលតិចសម្រាប់លោកនេះ ។ ព្រះអង្គ عزّوجلّ ទុកឲ្យយើងជ្រើសរើសដោយខ្លួនឯងគឺ បោកប្រាស់គេឬប្រព្រឹត្តត្រឹមត្រូវ ។

បើយើងនៅលើផ្លូវអ៊ីស្លាម គឺលើផ្លូវយុត្តិធម៌ យើងនឹងបានទាំងផលប្រយោជន៍ក្នុងលោកនេះ ទាំងផលប្រយោជន៍ក្នុងលោកមុខ ។ តែបើយើងបោកប្រាស់គេនិងតាមគន្លងស្ហៃតូន لعنه الله យើងអាចទៅជាអ្នកមានតែយើងនឹងមិនមានសេចក្តីសុខក្នុងលោកនេះឡើយ ហើយយើងនឹងមិនមានសេចក្តីសុខជាដាច់ខាតឯលោកមុខ ។

ព្រះសាស្តាមូហ៊ាំម៉ាដ់ صلى الله عليه وآله وسلم មានព្រះវចនៈថា៖ "អ្នកណាចិញ្ចឹមជីវិតដោយវិធីហ្ហាឡាល់ ៤០ ថ្ងៃ អល់ឡោះហ៍ عزّوجلّ នឹងបំភ្លឺចិត្តអ្នកនោះនិងធ្វើឲ្យមានញាណប្រាជ្ញាចេញពីចិត្តអ្នកនោះមកលើអណ្តាតអ្នកនោះ ។"

មិនបានសេចក្តីថាយើងត្រូវរកស៊ីចិញ្ចឹមជីវិត ៤០ ថ្ងៃក្រោយពីនោះយើងចាប់ផ្តើមបោកប្រាស់គេទៀតនោះទេ ។ ហាឌីស្សនេះចង់បង្ហាញយើងនូវរង្វាន់ដែលអល់ឡោះហ៍ عزّوجلّ ប្រទានឲ្យយើងពេលយើងធ្វើតាមព្រះអង្គ عزّوجلّ និងចេះអត់ទ្រាំយកឈ្នះប្រការអាក្រក់ ។

ព្រះសន្តអ៊ីម៉ាំអាលី صلوات الله عليه والسلام មានវចនៈប្រាប់ប្រជារាស្ត្រព្រះអង្គ صلوات الله عليه والسلام ថា៖ "អ្នក

មានសទ្ធាជាអ្នកណា ?" បន្ទាប់មកព្រះអង្គ صلوات الله عليه والسلام បានអធិប្បាយរៀបរាប់ចម្លើយសំណួរ សូមលើកយកមកអធិប្បាយជូនមួយប៉ែក ថា៖ "អ្នកមានសទ្ធាគឺបុគ្គលដែលមិនធ្វើឲ្យមនុស្សខ្លាចបាត់បង់ជីវិតទេ មិនធ្វើមនុស្សខ្លាចបាត់បង់ទ្រព្យនិងមិនធ្វើឲ្យមនុស្សខ្លាចបាត់បង់សេចក្តីថ្លៃថ្នូរទេ ។ បុគ្គលនោះចិញ្ចឹមជីវិតដោយវិធីត្រឹមត្រូវថ្លៃថ្នូរ ។"

យើងត្រូវចងចាំជានិច្ចថា អល់ឡោះហ៍ عز وجل ទុកឲ្យយើងបង្ហាញប្រាប់ព្រះអង្គ عز وجل ថាយើងជាមនុស្សត្រឹមត្រូវ ។ យើងអាចធ្វើឲ្យព្រះអង្គ عز وجل ទ្រង់សព្វព្រះហឫទ័យបានដោយច្បាំងណាហ្វ៍ស៍យើងនិងដោយមានយុត្តិធម៌ក្នុងលោកនេះ ឬយើងអាចធ្វើឲ្យព្រះអង្គ عز وجل ទ្រង់ព្រះពិរោធដោយធ្វើតាមណាហ្វ៍ស៍យើង ។ ចូរនឹកឃើញរឿង ហ៊្វរ (اَلْحُرَّ بْنَ يَزِيدَ الرِّيَاحِيَّ) កាលលោកនៅពីមុខផ្លូវបែកពីរ ផ្លូវមួយនាំទៅរកសេចក្តីស្លាប់ថ្លៃថ្នូរនៅខាងព្រះសន្តអ៊ីម៉ាំហ៊្វូសែន៍ صلوات الله عليه والسلام ផ្លូវមួយទៀតនាំទៅរកទ្រព្យសម្បត្តិគ្មានខ្លឹមសារ ។ លោកបានជ្រើសយកជម្រើសត្រឹមត្រូវ បានបង្ហាញគំរូយើង ។ តើយើងមានសេចក្តីក្លាហានដើរតាមគន្លងលោកទេ ?

## ជម្រើសនៅលើខ្លួនយើង...

## មេរៀនទី ៥

# ខ្លួនទីពឹងខ្លួន

ពឹងគេ គឺផ្អែកទៅលើគេ ។

ពេលទើបនឹងកើតមក មួយឆ្នាំដំបូងក្នុងជីវិតវា កូនក្មេងពឹងផ្អែកលើគេទាំងស្រុង ។ វាពឹងលើម្ដាយវាទាំងស្រុងក្នុងការបរិភោគ ក្នុងការស្លៀកពាក់ ក្នុងការបាននូវភាពកក់ក្ដៅ វាត្រូវការសេចក្ដីស្រឡាញ់និងការថ្នាក់ថ្នមពីម្ដាយវា ។

អល់ឡោះហ៊ូ ﷻ ប្រទានជីវិតឲ្យយើង ដោយធ្វើឲ្យយើងពឹងផ្អែកលើជីវិតនោះខានមិនបានតាំងពីកំណើត ។ ពេលយើងធំឡើង អ្នកដទៃពឹងផ្អែកលើយើង (ដូចជាកូនៗយើងជាដើម) ពេលយើងចាស់ជរាយើងពឹងពាក់លើអ្នកផ្សេងម្ដងទៀតព្រោះយើងខ្សោយ ។




វដ្តដំណើរជីវិត

ដូច្នេះ ជីវិតដូចរង្វង់មូល យើងផ្លាស់ប្ដូរពីកន្លែងមួយ ទៅកន្លែងមួយទៀត នៅទីបំផុតយើងវិលមកកាន់កន្លែងដើមវិញ ។

កាលយើងនៅក្មេង យើងមិនអាច មើលថែរក្សាខ្លួនឯងបានទេ យើងពឹងផ្អែកលើគេ ។ អ៊ីស្លាមណែនាំយើងឲ្យធំឡើង និងចេញពីដំណាក់ការនេះ ដើម្បីនឹងចេះថែរក្សាខ្លួនឯង ។

គេហៅដំណាក់ការនេះថា ខ្លួនទីពឹងខ្លួន បានសេចក្ដីថាយើងធ្វើអ្វីៗដោយខ្លួនឯងតាមសមត្ថភាពយើង ។ មិនបានសេចក្ដីថាយើងត្រូវធ្វើ**សព្វគ្រប់**ដោយខ្លួនឯងនោះទេ ។ យើងមិនត្រូវបដិសេធជំនួយពីអ្នកដទៃទេ ។

មនុស្សខ្លះធ្លាប់តែសូមឲ្យគេធ្វើអ្វីៗដែលខ្លួនចង់បាននោះឲ្យខ្លួន ទោះបីខ្លួនអាចធ្វើអ្វីៗទាំងនោះបានដោយខ្លួនឯងក៏ដោយ ។ មិនមែនអ្នកនោះចង់ត្រួតត្រាគេ

ឬចង់រំលោភសិទ្ធិគេទេ ។ នេះជាទម្លាប់គួរឲ្យខ្លាចដែលអាចធ្វើឲ្យអ្នកដទៃមិនចង់សេពគប់ជាមួយ ។

អតិថិវិន័យអ៊ីស្លាម (សីលធម៌) បង្ហាត់បង្រៀនយើងថាយើងមិនត្រូវសូមឲ្យគេធ្វើអ្វីដែលយើងអាចធ្វើបានដោយខ្លួនឯងទេ ទោះបីយើងធ្វើបែបនេះមួយដងមួយកាលក៏ដោយព្រោះវាមិនមែនជាទម្លាប់របស់យើងនោះ ។ ច្បាប់នេះត្រូវលើកចោលសម្រាប់មនុស្សខ្លះ ដូចជាឪពុកម្ដាយយើង រៀមច្បងយើង អ្នកពិការខ្លះ ជាដើម ។

ដូច្នេះ យើងត្រូវពឹងពាក់តែលើខ្លួនឯងរាល់ពេលដែលអាចធ្វើបាន ។

## តើយើងអនុវត្តច្បាប់នេះដូចម្ដេច?

បានសេចក្ដីថាយើងត្រូវរៀបកន្លែងដេកយើងឲ្យមានរបៀបរៀបរយ ពេលងើបពីដេក ត្រូវបោសសម្អាតបន្ទប់ដេកយើង ត្រូវចេះលាងចានខ្លួនឯង ត្រូវចេះធ្វើមុខងារខ្លួនឯង ។ យើងមិនត្រូវចាំឲ្យគេត្រួតពិនិត្យមើលតាមក្រោយយើងទេដើម្បីនឹងដឹងថាយើងបានធ្វើមុខងារស្រេចហើយ លើកលែងតែយើងនៅតូចនៅឡើយ ។

មនុស្សខ្លះមិនពឹងផ្អែកលើអ្នកដទៃហួសព្រំដែន ។ អ៊ីស្លាមចែងប្រាប់យើងថាទោះបីយើងមានចំណាស់ប៉ុណ្ណាក៏ដោយ ឪពុកម្ដាយយើងមានអាជ្ញាលើខ្លួនយើងជានិច្ច ។ ចាស់ជាងយើង លោកមានបទពិសោធន៍ច្រើននិងដឹងថាអ្វីល្អសម្រាប់យើង (ជាញឹកញយ) ។ ក៏ប៉ុន្តែ កូនខ្លះតមាត់ឪពុកម្ដាយថាខ្លួនដឹងជាងលោក ពួកគេនឹងធ្វើតាមចិត្តព្រោះខ្លួនធំពេញវ័យហើយ ។

យើងត្រូវចងចាំថាមានតែមួយប្រការទេដែលយើងគេចមិនផុត នោះគឺអល់ឡោះហ៍ﷻ ។

ទោះបីយើងមានប៉ុណ្ណាក៏ដោយ ទោះបីយើងអាចធ្វើអ្វីៗបានដោយខ្លួនឯងច្រើនប៉ុណ្ណាក៏ដោយ យើងមានជីវិតរស់នៅនេះដោយសារតែអល់ឡោះហ៍ﷻ ដែលមិនត្រឹមតែបានបង្កើតយើងមកនោះទេ តែព្រះអង្គﷻរក្សាយើងឲ្យគង់ជីវិតគ្រប់ពេលវេលាទៀតផង ។

បន្ទាប់ពីបានដើរផ្លូវឆ្ងាយ ទាំងអស់គ្នាឈប់សម្រាកនៅឯកន្លែងមួយ ។ ព្រះ

សាស្ដាមូហាំម៉ាដ់ﷺនិងបណ្ដាសាវកបានចុះពីលើសេះ ស្រាយអ៊ីវ៉ាន់ ។ បន្ទាប់មកបានសម្រេចសំឡេះសត្វមួយសម្រាប់បរិភោគ ។ សាវកម្នាក់បានថា៖ "ខ្ញុំសំឡេះសត្វ ។" ម្នាក់ទៀតថា៖ "ខ្ញុំពន្លាត់ស្បែកនិងវះពោះវា ។" សាវកទីបីស្ម័គ្រចិត្តដាំស្ល ។ ដូច្នេះ ទាំងអស់គ្នាស្ម័គ្រចិត្តជួយធ្វើកិច្ចផ្សេងៗ ។ ព្រះសាស្ដាមូហាំម៉ាដ់ﷺមានព្រះវចនៈថា៖ "ខ្ញុំﷺនឹងទៅរកឧស ។" បណ្ដាសាវកក៏បានងើបឡើងភ្លាម ទូលថា៖ "ព្រះសាស្ដាﷺអល់ឡោះហ្វ៍ﷻអឺយ កុំអី! ទុកឲ្យអស់ទូលបង្គំមានកិត្តយសបម្រើព្រះអង្គﷺ សូមព្រះអង្គﷺសម្រាកចុះ ។ អស់ទូលបង្គំនៅទីនេះដើម្បីធ្វើការឲ្យព្រះអង្គﷺ ។" ព្រះសាស្ដាមូហាំម៉ាដ់ﷺមានព្រះវចនៈថា៖ "ខ្ញុំﷺដឹងថាអស់លោកអាចធ្វើបាន ។ តែអល់ឡោះហ្វ៍ﷻស្អប់មនុស្សណាដែលពេញចិត្តនឹងឯកសិទ្ធិបែបនេះក្នុងចំណោមមិត្តនិងកនរបស់ខ្លួន ។ ព្រះអង្គﷻស្អប់អ្នកណាដែលគិតតែខ្លួនឯងដោយពឹងផ្អែកលើបុណ្យស័ក្ដិ ។" បន្ទាប់មក ព្រះអង្គﷺទៅឯព្រៃ រើសកូនឈើនិងមែកឈើងាប់មកសម្រាប់បង្កាត់ភ្លើង ។

## មេរៀនទី ៦

# ការរស់នៅក្នុងសហគមន៍

អ៊ីស្លាមមិនគ្រាន់តែជាសាសនាមួយទេ ។ អ៊ីស្លាមជាមធ្យោបាយតែមួយគត់ក្នុងការដឹកនាំជីវិតសុក្រឹតឥតខ្ចោះនិងបរិបូរ ។ សេចក្តីអធិប្បាយរៀបរាប់អំពីជីវិតរស់នៅក្នុងសង្គមអ៊ីស្លាមមានដូចតទៅ ដោយមានច្បាប់ទូន្មាន (ក្រមសីលធម៌) ជាបន្តបន្ទាប់ដែលមុស្លីមទាំងអស់ត្រូវអនុវត្តិ ។

ពាក្យថាសហគមន៍មានអត្ថន័យថា "មនុស្សមួយក្រុមរួបរួមគ្នាជាអង្គភាពសង្គម... ដោយមានជាតិសាសន៍ សាសនា ។ល ។តែមួយ ។"

អ៊ីស្លាមជាសាសនាដែលអល់ឡោះហ៍ عزّ وجلّ ដាក់មកឲ្យមនុស្សជាតិ ជាអំណោយដើម្បីបង្រួបបង្រួមពួកគេជុំគ្នានៅក្នុងសន្តិភាពនិងនៅក្នុងការចុះសម្រុងគ្នា ។ លុះត្រាតែសហគមន៍ទាំងមូលនៅក្នុងសន្តិភាព ទើបអាចប្រព្រឹត្តដូច្នេះបាន ហើយលុះត្រាតែម្នាក់ៗនៅក្នុងសន្តិភាព ទើបសហគមន៍ទាំងមូលអាចនៅក្នុងសន្តិភាពបាន ។

ចូរគិតថាសហគមន៍ជាក្រុមកីឡាមួយក្រុម ។ ដើម្បីឈ្នះ ក្រុមកីឡាករត្រូវធ្វើសហាប្រតិបត្តិការ (រួមកម្លាំងគ្នា) ម្នាក់ៗត្រូវលេងឲ្យបានល្អដើម្បីក្រុមទាំងមូលនឹងលេងបានល្អ ។

អ៊ីស្លាមនឹងធានាបាននូវការរស់នៅជុំគ្នាដោយសុខសាន្ត ដោយចាត់ចែងឲ្យមានច្បាប់សង្គម (របៀបប្រតិបត្តិខ្លួន) ដែលជាប៉ែកដ៏សំខាន់មួយរបស់បុគ្គលនីមួយៗ (ពោលគឺ បុគ្គលគ្រប់រូបក្នុងសហគមន៍ត្រូវអនុវត្តិច្បាប់នេះ) ដើម្បីនឹងជះឥទ្ធិពលទៅលើសហគមន៍ទាំងមូល ។

សហគមន៍ជាការល្បងពិសោធន៍ដែរសម្រាប់មនុស្សជាតិ ព្រោះមនុស្សនៅក្រោមអំណាចនៃចំណង់គ្រប់ពេលវេលា ដូចនៅក្នុងឧទាហរណ៍ខាងក្រោមនេះ ។

គ្រាមួយ មានបុរសម្នាក់ចូលទៅក្នុងរូងភ្នំតែម្នាក់ឯង ដាច់ស្រយាលពីមនុស្ស ។ គាត់ធ្លាប់តែរស់នៅក្នុងរូងនោះ ធ្វើសក្ការៈនៅក្នុងរូងនោះ កាន់សីលត្រណមនៅក្នុងរូងនោះ ។ ថ្ងៃមួយ មានគេដើរកាត់តាមនោះឃើញគាត់ សួរគាត់ថា៖



"ហេតុអ្វី លោករស់នៅកន្លែងនេះ ដែលគ្មានមនុស្សនៅ ?" បុរសនោះឆ្លើយទៅគាត់ថា៖ "ខ្ញុំយល់ឃើញថា នៅកន្លែងនេះ ខ្ញុំងាយស្រួលមិនធ្វើប្រការអាក្រក់ និងងាយស្រួលផ្គាប់ចិត្តអល់ឡោះហ្ ។ ខ្ញុំមិននិយាយដើមគេទេ មិនធ្វើប្រការហ្វីតណាស់ និងហ្វាសាដ់ទេ ខ្ញុំមិនក្រោធទេ មិនជេរប្រមាថអ្នកជិតខាងទេ ។ មកដល់ពេលនេះខ្ញុំជឿសប់ចិត្តណាស់ ។" បុរសអ្នកសួរគាត់សើចហើយថា៖ "លោកកុហកតែខ្លួនឯងទេ ។ ដែលលោករក្សាបាននូវសេចក្តីថ្លៃថ្នូរនោះ ព្រោះតែនៅកន្លែងនេះលោកពុំមានអ្នកដទៃដែលលោកអាចប្រព្រឹត្តបំពានលើបាន ។ រស់នៅជាមួយគេឯងជាការពិសោធន៍ដើម្បីនឹងដឹងថាលោកអាចគ្រប់គ្រងខ្លួនឯងបានដូចម្តេច ។ តើលោកអាចអត់ឱនឲ្យបុគ្គលដែលប្រព្រឹត្តអាក្រក់លើលោកបានទេ តើលោកអាចទប់ខ្លួនកុំឲ្យនិយាយដើមគេឬបង្ករឿងបានទេ ។ល ។ ដែលលោកកំពុងធ្វើនៅទីនេះគឺគេចវេះនិងបរាជ័យក្នុងការពិសោធន៍សាកល្បង ។"

ដូចមិនបានទៅសាលារៀនថ្ងៃប្រលងដែរ រួចហើយអ្នកប្រាប់ឪពុកម្តាយថា៖ "ខ្ញុំមិនបានប្រលងធ្លាក់ទេ ។" អ្វីដែលអ្នកត្រូវដឹងគឺអ្នកមិនបានចូលប្រលងបានមួយវិញ្ញាសាសោះ ។

បេះដូងរបស់សហគមន៍គឺជំនឿដែលចងសហគមន៍ភ្ជាប់ជាសម្ព័ន្ធ និងដែលធ្វើឲ្យសហគមន៍ចេះធ្វើសក្ការៈអល់ឡោះហ្ ។ យើងអាចឃើញដូច្នេះបានក្នុងឱកាសច្រើនដូចជាក្នុងឱកាសធ្វើសក្ការជុំគ្នា (الْجُمْعَة យ៉ូមអ៊ាស្ម) ក្នុងម៉ាយ៉្លាលិស (ក្នុងឱកាសប្រជុំគ្នា) និងក្នុងឱកាសជួបជុំគ្នាច្រើនទៀតជាដើម ។ អល់ឡោះហ្ ណែនាំយើងនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ អាល់-អាន់បីយ៉ាអ៍ អាយ៉ាស់ 92 (21:92) ថា៖

إِنَّ هَٰذِهِۦٓ أُمَّتُكُمْ أُمَّةً وَٰحِدَةً وَأَنَا۠ رَبُّكُمْ فَٱعْبُدُونِ ﴿٩٢﴾

*92.ពិតណាស់ សហគមន៍របស់ពួកអ្នកមួយនេះជាសហគមន៍តែមួយ ។ អញជាព្រះ*

*ម្ចាស់របស់ពួកអ្នក ដូច្នេះចូរពួកអ្នកគោរពបូជាអញ ។*

កម្លាំងរបស់សហគមន៍នៅលើឯកភាព ។ សុភាសិតថា៖ "បំបែកដើម្បីសោយរាជ្យ" ។ បើអ្នកចង់ត្រួតត្រាមនុស្សក្រុមនីមួយ អ្នកត្រូវចាប់ផ្ដើមដោយធ្វើឲ្យពួកគេបែកបាក់គ្នាដោយធ្វើឲ្យពួកគេឈ្លោះគ្នា ។ ពិភពលោកខាងលិចធ្វើបែបនេះទៅលើសហគមន៍អ៊ីស្លាមក្នុងពិភពលោកទាំងមូល ។ យើងត្រូវដកស្រង់យកមេរៀនពីទង្វើទាំងនេះនិងត្រូវងើបឡើងដើម្បីការពារបណ្ដាអ្នកកាន់សាសនាយើង ។

យើងអាចសម្របសម្រួលបាន តែដោយយោលទៅតាមការអនុញ្ញាតរបស់ច្បាប់ស្ហារីអ៊ាស់អ៊ីស្លាម ។ យើងមិនត្រូវសម្របសម្រួលគោលការណ៍និងជំនឿយើងជាដាច់ខាត ។ ជាគំរូ យើងត្រូវនឹករលឹកដល់មេរៀនដែលព្រះសន្តអ៊ីម៉ាំហ៊្វូសែន៍ صلوات الله عليه والسلام បានបន្សល់ទុកឲ្យយើងនៅឯវាលការបាឡាអ៊ ។

សហគមន៍ជាការល្បងពិសោធន៍ តែសហគមន៍ជារង្វាន់ដែរ ពីព្រោះបុគ្គលអាចមានមិត្តស្មោះត្រង់ចោមរោមច្រើនដែលនឹងជួយជ្រោមជ្រែងខ្លួន ពេលមានអាសន្ន ។ អល់ឡោះហ្ 
عَزَّ وَجَلَّ មានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ អាល់-ហ៊្វូយូរ៉ាត អាយ៉ាស់ 13 (49:13) ថា៖

يَٰٓأَيُّهَا ٱلنَّاسُ إِنَّا خَلَقۡنَٰكُم مِّن ذَكَرٖ وَأُنثَىٰ وَجَعَلۡنَٰكُمۡ شُعُوبٗا وَقَبَآئِلَ لِتَعَارَفُوٓاْۚ إِنَّ أَكۡرَمَكُمۡ عِندَ ٱللَّهِ أَتۡقَىٰكُمۡۚ ... ١٣

*13. មនុស្សអើយ យើងបានបង្កើតពួកអ្នកពីមនុស្សប្រុសម្នាក់និងមនុស្សស្រីម្នាក់ ហើយយើងបានបែងចែកពួកអ្នកជាប្រជាជាតិនិងជាកុលសម្ព័ន្ធ ដើម្បីនឹងឲ្យពួកអ្នកស្គាល់គ្នា ។ ការពិត សម្រាប់អល់ឡោះហ្ អ្នកថ្លៃថ្នូរបំផុតក្នុងចំណោមពួកអ្នកគឺអ្នកដែលត្រឹមត្រូវបំផុតក្នុងចំណោមពួកអ្នក ។"*

បែបបទដែលសហគមន៍ត្រូវជ្រើសយកមកអនុវត្តិក្នុងការរស់នៅនោះ នៅក្នុងចំណោមប្រការដែលអ៊ីស្លាមគាំទ្រ ដែលមាននៅក្នុងច្បាប់រស់នៅក្នុងសង្គមអ៊ីស្លាមដែលយើងអធិប្បាយខាងក្រោមនេះ ។

## ច្បាប់រស់នៅក្នុងសង្គមអ៊ីស្លាម

ច្បាប់សង្គមអ៊ីស្លាមគឺឧត្តមគតិដែលត្រូវព្យាយាមឈានទៅរក ក្នុងការរស់ក្នុង

សង្គមអ៊ីស្លាម ។

យើងរាល់គ្នាមានភារកិច្ចទទួលខុសត្រូវលើអ្នកឯទៀត ដើម្បីរក្សាយុត្តិធម៌និងគោរពសិទ្ធិអ្នកដទៃ ។

នៅក្នុងព្រះគម្ពីរគួរអាន (ស៊ូរ៉ោះត៍ 49 អាយ៉ាស់ 11-12) អល់ឡោះហ្ទ៍ﷻពន្យល់ប្រាប់យើងអំពីរបៀបប្រព្រឹត្តខ្លួនថា៖

يَـٰٓأَيُّهَا ٱلَّذِينَ ءَامَنُوا۟ لَا يَسْخَرْ قَوْمٌ مِّن قَوْمٍ عَسَىٰٓ أَن يَكُونُوا۟ خَيْرًا مِّنْهُمْ وَلَا نِسَآءٌ مِّن نِّسَآءٍ ... ﴿١١﴾ يَـٰٓأَيُّهَا ٱلَّذِينَ ءَامَنُوا۟ ٱجْتَنِبُوا۟ كَثِيرًا مِّنَ ٱلظَّنِّ إِنَّ بَعْضَ ٱلظَّنِّ إِثْمٌ ۖ وَ لَا تَجَسَّسُوا۟ وَلَا يَغْتَب بَّعْضُكُم بَعْضًا ۚ أَيُحِبُّ أَحَدُكُمْ أَن يَأْكُلَ لَحْمَ أَخِيهِ مَيْتًا ... ﴿١٢﴾

*11. បណ្តាអ្នកមានសទ្ធាអើយ ចូរកុំឲ្យមនុស្សក្រុមណាមួយចំអកឲ្យមនុស្សមួយក្រុមទៀត ។ ជួនកាលពួកគេអាចប្រសើរជាងពួកគេទាំងនោះ ។ ចូរកុំឲ្យបណ្តាស្ត្រីចំអកឲ្យបណ្តាស្ត្រីឯទៀត... 12 បណ្តាអ្នកមានសទ្ធាអើយ ចូរពួកអ្នកចៀសវាងប៉ាន់ស្មាន ព្រោះការពិត ក្នុងករណីខ្លះ ប៉ាន់ស្មានជាបាប ។ ចូរពួកអ្នកកុំលបយកការណ៍ ។ ចូរពួកអ្នកកុំនិយាយបង្កាច់អ្នកឯទៀត ។ តើមានអ្នកណាម្នាក់ក្នុងចំណោមពួកអ្នកចូលចិត្តស៊ីសាច់បងប្អូនឯងដែលស្លាប់នោះទេ ?*

របៀបប្រព្រឹត្តខ្លួនក្នុងសហគមន៍នោះមានច្រើនរាប់មិនអស់ ប្រការសំខាន់បំផុតគឺការចេះគិតដល់អ្នកដទៃ ។ បើបុគ្គលណាមួយគិតដល់សុខទុក្ខរបស់បងប្អូនខ្លួន បុគ្គលនោះនឹងប្រព្រឹត្តស្របតាមហេតុផល ។

ព្រះសាស្តាមូហាំម៉ាដ់ﷺមានព្រះវចនៈថា៖ "ចូរលោកចង់ឲ្យអ្នកដទៃបាន ឲ្យដូចខ្លួនលោកចង់បានដែរ ។"

នៅក្នុងស៊ូរ៉ោះត៍ខ្លីបំផុត អាល់-អុស្វ៍រ អាយ៉ាស់ 2 (103:2) អល់ឡោះហ្ទ៍ﷻ ថែងច្បាប់សង្គមសម្រាប់មនុស្សជាតិទាំងអស់ថា៖

إِنَّ ٱلْإِنسَـٰنَ لَفِى خُسْرٍ ﴿٢﴾

*2. ពិតណាស់ មនុស្សនៅក្នុងសេចក្តីវិនាស ។*

អាយ៉ាស់នេះផ្តោតទៅលើថ្ងៃជំនុំជម្រះ ។ ពេលអល់ឡោះហ្ទ៍ﷻនឹងឲ្យមនុស្សងើបឡើងពីក្នុងផ្នូរដើម្បីសាកសួរដល់ជីវិតមនុស្សនោះ មនុស្សខ្លះនឹងថាខ្លួនពុំបាន

ធ្វើប្រការល្អសោះ មនុស្សទាំងនេះនឹងវិនាស ។ មនុស្សខ្លះទៀតនឹងឆ្លើយថាខ្លួនជាមនុស្សល្អ បានធ្វើសក្ការៈទៀងទាត់ មនុស្សទាំងនេះក៏នឹងវិនាសដែរ ។

អាយ៉ាស់ 3 ៖

إِلَّا ٱلَّذِينَ ءَامَنُواْ وَعَمِلُواْ ٱلصَّٰلِحَٰتِ وَتَوَاصَوْاْ بِٱلْحَقِّ وَتَوَاصَوْاْ بِٱلصَّبْرِ ٣

*3. លើកលែងតែបណ្ដាអ្នកដែលមានសទ្ធា សាងអំពើល្អ ដាស់តឿន[គ្នាទៅវិញទៅមក]ឲ្យទៅកាន់សេចក្ដីពិត ដាស់តឿន[គ្នាទៅវិញទៅមក]ឲ្យអត់ធ្មត់[នៅលើមាគ៌ាអល់ឡោះហ៍] ។*

សឲ្យឃើញថាជាមនុស្សល្អមិនគ្រប់គ្រាន់ទេ ត្រូវបម្រើសហគមន៍ដែរដោយណែនាំគេទៅរកសេចក្ដីពិតនិងដោយដាក់បង្គាប់ឲ្យគេធ្វើល្អ ។

ដូច្នេះ ច្បាប់សង្គមដ៏សំខាន់មួយទៀតគឺ អាំរ៉ូ ប៊ិល ម៉ាក់រុហ្វ វ៉ា អាន់ណាស្ហ៉យ៉ា អ៊ុនីល-មុនការ (اَلْأَمْرَ بِالْمَعْرُوفِ وَ النَّهْيَ عَنِ الْمُنْكَرِ - បង្គាប់ឲ្យធ្វើល្អនិងហាមធ្វើអាក្រក់) ។

អ៊ីស្លាមជាសាសនាមួយគត់ដែលអាចអះអាងបាន ថាបានបង្កើតវិទ្យាសាស្ត្រវិស័យឥរិយាបថមនុស្ស វិស័យសុជីវធម៌និងសិល្បសម្រិតសម្រាំងចិត្ត ។ ក្រៅពីជាមុស្លីម បុគ្គលដែលបានអនុវត្តិតាមសិក្ខាបទរបស់អ៊ីម៉ាំទាំង ១២ អង្គនិងជឿយុត្តិធម៌របស់អល់ឡោះហ៍ﷻ គេហៅបុគ្គលនោះថាមុមីន (អ្នកមានសទ្ធា) ។

ថ្ងៃមួយគេបានសួរព្រះសន្តអ៊ីម៉ាំអ៊ុលីعليه السلام ថា៖ "អ្វីទៅអ្នកមានសទ្ធា ?" ព្រះអង្គعليه السلام បានឆ្លើយដោយរៀបរាប់លក្ខណៈរបស់អ្នកមានសទ្ធាថា៖ "អ្នកមានសទ្ធាគឺបុគ្គលដែលមិនធ្វើឲ្យមនុស្សខ្លាចបាត់បង់អាយុជីវិតទេ ដែលមិនធ្វើឲ្យមនុស្សខ្លាចបាត់បង់ទ្រព្យទេ ដែលមិនធ្វើឲ្យមនុស្សខ្លាចបាត់បង់សេចក្ដីថ្លៃថ្នូរទេ ។ ពេលបុគ្គលនោះមានប្រៀបលើគេ បុគ្គលនោះងាយអត់ឱនឲ្យគេ ។ បុគ្គលនោះមានចិត្តទូលំទូលាយដោយសមហេតុផល ។ បុគ្គលនោះមានឥរិយាបថស្លូតបូត ។ ទង្វើនិងដំណើររបស់បុគ្គលនោះសឲ្យឃើញនូវសេចក្ដីសុភាពរម្យទម ។ មនុស្សស្រឡាញ់មិត្តភាពនិងសេចក្ដីស្ងប់ស្ងាត់របស់បុគ្គលនោះ ។ បុគ្គលនោះត្រៀមខ្លួនអត់ទ្រាំការលំបាកជាស្រេចដើម្បីជួយសម្រាលទុក្ខអ្នកដទៃ ។ បុគ្គលនោះជាមិត្តស្មោះត្រង់ ។

បុគ្គលនោះគោរពពាក្យសន្យា ។ បុគ្គលនោះជួយជនរងការសង្កត់សង្កិននិងបារម្ភ ជនគ្មានពំនាក់អាស្រ័យ ។ បុគ្គលនោះមិនបោះបង់ជនមានអាសន្នទេ បុគ្គលនោះព្យាយាមជួយសម្រាលទុក្ខជនទាំងនោះ ។ បុគ្គលនោះគោរពសិទ្ធិអ្នកអវត្តិមាន ។ បុគ្គលនោះព្រមទទួលការសូមខមាទោសរបស់ជនមានកំហុស ។ បុគ្គលនោះជួយឧបត្ថម្ភបណ្តាអ្នកដែលបានជួយឧបត្ថម្ភខ្លួន ។ បុគ្គលនោះមិនបរិហារអាថ៌កំបាំងរបស់អ្នកដទៃទេ ។ បុគ្គលនោះមិនជ្រៀតជ្រែកក្នុងរឿងសម្ងាត់ដែលមិនទាក់ទងនឹងខ្លួនទេ ។ បុគ្គលនោះជាគំរូល្អសម្រាប់បណ្តាអ្នកដែលនឹងតាមខ្លួន ។ បុគ្គលនោះធ្វើល្អមិនមែនដើម្បីអួតគេទេ ។ បុគ្គលនោះមិនពើបពះបញ្ហាតែមួយពីរដងទេ ។"

## លំហាត់

ចូរអានសាឡើងវិញចម្លើយរបស់ព្រះសន្តអ៊ីម៉ាំអាលី صلوات الله عليه والسلام ពេលគេសួរព្រះអង្គ صلوات الله عليه والسلام ថា៖ "អ្វីទៅអ្នកមានសទ្ធា ?" ហើយចូរពន្យល់ប្រាប់ឪពុកម្ដាយអ្នកដោយពាក្យផ្ទាល់ខ្លួនរបស់អ្នកថាសំណួរនេះមានន័យថាអ្វី ។

## មេរៀនទី ៧

# វប្បធម៌អ៊ីស្លាម

វប្បធម៌ជាឈុតទម្លាប់ ច្បាប់និងវិន័យនានារបស់មនុស្សមួយក្រុម ។

វប្បធម៌អ៊ីស្លាមគឺរបៀបប្រព្រឹត្តខ្លួនរបស់យើង ។ វាជារបៀបដែលគេបង្ហាត់បង្រៀនមុស្លីមឲ្យចេះរស់នៅ ដោយផ្អែកទៅលើគួរអាននិងហាឌីស្ហ ។ បុគ្គលមុស្លីមត្រូវយល់និងអនុវត្តិវិជ្ជានេះ ពីព្រោះពេលប្រភពវិជ្ជាទាំងពីរនេះផ្សំគ្នា យើងនឹងមានមធ្យោបាយដឹកនាំជីវិតយើងទៅរកសុក្រឹតភាពនិងសេចក្តីស្កប់ស្កល់ចិត្ត ។

មានគំរូរាប់មិនអស់នៃប្រការដែលយើងគប្បីធ្វើនិងប្រព្រឹត្តិខ្លួន តែប្រការសំខាន់បំផុតក្នុងទង្វើទាំងនេះគឺការមានសីលធម៌ ។

ដើម្បីនឹងមានសីលធម៌ ត្រូវអនុវត្តិតាមច្បាប់ងាយមួយដែលមានចែងនៅក្នុងសម្ពីរបស់ព្រះសាស្តាមូហាំម៉ាដ្ឋ ﷺ ក្នុងសម្ពីរបស់ព្រះសាស្តាអ៊ីសា عليه السلام និងក្នុងសម្ពីរបស់ព្រះសន្តអ៊ីមុាំអាលី صلوات الله عليه والسلام គឺ៖

**ចូរអស់លោកប្រព្រឹត្តចំពោះអ្នកដទៃ ដូចអស់លោកចង់ឲ្យគេប្រព្រឹត្តចំពោះអស់លោកដែរ ។**

បានសេចក្តីថាគិតដល់អ្នកដទៃ ទោះជាគ្រួសារអ្នកក្តី ទោះជាសាច់ញាតិឬមិត្តអ្នកក្តី ។

រាល់ពេលដែលអ្នកជួបអ្នកដទៃ អ្នកជាខ្នាន់ទង់អ៊ីស្លាម ។ ដូច្នេះ ពេលគេឃើញអ្នកគេនឹងថា៖ "មុស្លីមធ្វើបែបនេះឯង ។"

គ្រាមួយ សាលារៀនមួយមានសិស្សមុស្លីមពេញ ។ គេបានសួរចាងហ្វាងសាលាថាតើលោកយល់ឃើញយ៉ាងណាអំពីខែរ៉ម៉ាដ្ឋន ។ លោកបានតបថាវាជាខែអាក្រក់លើសខែទាំងអស់ ។ ពេលគេសួរលោករកមូលហេតុ លោកបានឆ្លើយថា៖ "សិស្សទាំងអស់គ្នាកាន់សីលត្រណម ស្តោះទឹកមាត់ដាក់ជញ្ជាំងនិងដាក់កម្រាលមិនឈប់ ព្រោះពួកគេមិនចង់លេបទឹកមាត់ទេ ។"

នេះគឺគំរូដែលពួកសិស្សបានបន្សល់ទុកឲ្យចាងហ្វាងសាលារៀន ។ សម្រាប់លោក មុស្លីមទាំងអស់ស្តោះទឹកមាត់ពាសពេញក្នុងខែរ៉ម៉ាដ្ហន ។ នេះគឺកេរ្តិ៍ឈ្មោះអាក្រក់និងមិនត្រឹមត្រូវរបស់អ៊ីស្លាមដែលគេបន្សល់ទុកឲ្យជនមិនមែនមុស្លីម ។

រាល់ពេលដែលអ្នកធ្វើអំពើនីមួយ ចូរអ្នកសួរខ្លួនឯងថា៖ "តើព្រះសន្តអ៊ីមុាំអាុលី صلوات الله عليه والسلام ធ្វើបែបនេះទេ ?" ចូរអ្នករិះគិតអំពីចម្លើយសំណួរនេះមុនធ្វើ ។

ថ្ងៃមួយគេបានសួរព្រះសាស្តាមូហុាំម៉ាដ្ ﷺ ថា ហេតុអ្វីព្រះអង្គ ﷺ មកកាន់ផែនដីនេះ តើព្រះអង្គ ﷺ មានគោលដៅអ្វី ? ព្រះអង្គ ﷺ បានឆ្លើយថា៖ "ខ្ញុំ ﷺ ត្រូវចាត់បញ្ជូនមកដើម្បីដុសខាត់ចរិយាមារយាទ (គឺសីលធម៌) អស់លោកឲ្យសុក្រឹតឥតខ្ចោះ ។"

បានសេចក្តីថាគោលដៅចម្បងរបស់ព្រះសាស្តាមូហុាំម៉ាដ្ ﷺ គឺធ្វើឲ្យវប្បធម៌ធ្វើឲ្យចរិយារបស់បុគ្គលក៏ដូចចរិយារបស់ហាសគមន៍ដែរ ទៅជាប្រសើរឡើងនិងទៅជាសុក្រឹតឥតខ្ចោះ ។

មានវប្បធម៌អ៊ីស្លាមល្អនៅឯផ្ទះជាប្រការសំខាន់ណាស់សម្រាប់យើង ព្រោះគ្រឹះនៃការអប់រំកូនៗនៅក្នុងផ្ទះនោះឯង ។ យើងត្រូវធានាការធ្វើសក្ការៈ (ស្វ៊ូឡាត្ត៍) ឲ្យទាន់ពេលវេលា ។ បើអាចធ្វើបាន យើងត្រូវស្វ៊ូឡាត្ត៍យ៉ាម៉ាអាុស្វ៍នៅផ្ទះ ដឹកនាំដោយឪពុក កូនៗតាមពីក្រោយ ។ ម្តាយត្រូវប្រាប់កូនស្រីឲ្យដឹងអំពីសារៈសំខាន់របស់ការទទួលហុីយ៉ាប់ ឪពុកម្តាយត្រូវពន្យល់ប្រាប់កូនៗអំពីប្រការនានាដែលអ៊ីស្លាមហាមឃាត់ដូចជាស្តាប់ចំរៀង ទៅរាំរែកឯរង្គសាលជាដើម ។

ឪពុកម្តាយខ្លះប្រាប់កូនមិនឲ្យកាន់សីលត្រណមទេពេលប្រលង ។ កូនៗគិតថាគេអនុញ្ញាតឲ្យខានកាន់សីលត្រណមដោយសារមូលហេតុបែបនេះ បណ្តាលឲ្យកាត់បន្ថយសារៈសំខាន់របស់ការកាន់សីលត្រណម ។ តើស្តីបន្ទោសកូនក្មេងដូចម្តេចបើឪពុកម្តាយជម្រុញឲ្យធ្វើបែបនេះ ? អ្វីដែលអ្នកត្រូវដឹងគឺ បើអ្នកធ្វើតាមអល់ឡោះហ៍ عزّ وجلّ អល់ឡោះហ៍ عزّ وجلّ នឹងជួយអ្នក ។ អល់ឡោះហ៍ عزّ وجلّ មានព្រះបន្ទូលថាសម្រាប់ជំហាននីមួយដែលអ្នកឈានទៅរកព្រះអង្គ عزّ وجلّ ព្រះអង្គ عزّ وجلّ នឹងឈានមករកអ្នក ១០ ជំហាន ។ ដូច្នេះ ចូរអ្នកនៀតហើយកាន់សីលត្រណមចុះ ។ ចូរកុំចាត់ទុកការកាន់សីលត្រណមជាប្រការមួយដែលធ្វើឲ្យអ្នកខូចខាត តែចូរគិតថាវាជួយឲ្យអ្នកអាចប្រមូលផ្តុំអារម្មណ៍បាន ជួយឲ្យអ្នកសិក្សាបាន មិនយូរទេអ្នកនឹងឃើញថា

អ្នកធ្វើបានល្អ ។

ត្រូវទុកវប្បធម៌អ៊ីស្លាមជាប៉ែកមួយក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់យើង វាមិនគ្រាន់តែជាអ្វីដែលគេសម្តែងឲ្យគេឃើញនៅឯម៉ាស់យ៊ិដ្ឋ ឬនៅសាលានោះទេ ។ មានតែធ្វើដូច្នេះទេដែលយើងនឹងបានទទួលផលប្រយោជន៍ក្នុងលោកនេះ និងក្នុងលោកមុខ ។

**មេរៀនទី ៨**

# អភិវឌ្ឍន៍អំណាចចិត្ត

អ្វីទៅអំណាចចិត្ត ?

និយាយឲ្យស្រួលស្តាប់ មានន័យថាសមត្ថភាពគ្រប់គ្រងចំណង់ខ្លួនឯង ។

អំណាចចិត្តមានសារៈសំខាន់ណាស់ព្រោះ ដូចយើងបានឃើញរួចមកហើយក្នុងមេរៀនមុន ជំណាក់ការខ្ពស់បំផុតក្នុងជីវិតលោកនេះគឺទៅដល់ជំណាក់ការគាប់ចិត្តអល់ឡោះហ្ ﷻ សេចក្តីស្កប់ស្កល់ (គឺសមបំណង) ។ ទាល់តែចេះគ្រប់គ្រងនិងចេះអភិវឌ្ឍអំណាចចិត្តទើបអាចទៅដល់ជំណាក់ការនេះបាន ។

នៅក្នុងលោកជុំវិញខ្លួនយើង យើងជួបប្រទះវត្ថុមានគ្រោះថ្នាក់ច្រើនដូចជាគ្រឿងញៀន ស្រា រូបចំអេសចំអាស ជាដើម ។ បើបណ្តោយខ្លួនទៅតាមអំពើទាក់ទាញទាំងនេះយើងនឹងធ្វើឲ្យជីវិតយើងវិនាស ។

មានអំណាចចិត្ត គឺមានសមត្ថភាពការពារខ្លួនពីទម្លាប់អាក្រក់ទាំងនេះ ចាប់ពីការដេកយប់ជ្រៅពេកដែលជាទង្វើសាមញ្ញនោះ ដល់ទៅទង្វើអាក្រក់លើសនេះដូចជាធ្វើសក្ការៈ (ស្វ៉ឡាត្ទ) មិនទាន់ពេលឬមិនធ្វើសក្ការៈតែម្តងនោះជាដើម !

ពេញមួយខែរ៉ម៉ាឌ្ហនជាឱកាសអនុវត្តអំណាចចិត្ត ។ មិនបរិភោគជាប្រការងាយធ្វើជាងគេក្នុងខែរ៉ម៉ាឌ្ហន ។ ងាយតមអាហារណាស់ បើប្រៀបធៀបនឹងទង្វើច្រើនទៀតដែលយើងត្រូវធ្វើនោះ ។ យើងត្រូវចៀសវាងមើលឬស្តាប់អ្វីដែលហ៊ារ៉ាំ ។ យើងត្រូវទប់ចិត្តនិងសម្តីយើង ។ ចុងខែ យើងត្រូវឈ្នះសម្លេងមួយនៅក្នុងចិត្តយើងនោះដែលបបួលយើងធ្វើប្រការអាក្រក់ គឺសម្លេងរបស់ណាហ្វ៍ស៍យើង ។

គ្រាមួយ គេបានសួរព្រះសាស្តាមូហាំម៉ាដ់ ﷺ ថា៖ "ព្រះអង្គ ﷺ មិនឮសម្លេងមួយនៅក្នុងខ្លួនព្រះអង្គ ﷺ ទេ (ស្ហៃតន لعنه الله) ដែលណែនាំព្រះអង្គ ﷺ ឲ្យធ្វើប្រការអាក្រក់ ?" ព្រះអង្គ ﷺ បានតបថា៖ "ឮ ! តែខ្ញុំ ﷺ ចង់វាជាប់ ។"

ណាហ្វ៍ស៍មិនត្រូវចងដោយច្រវាក់ដែកទេ តែដោយច្រវាក់នៃអំណាចចិត្ត ។

ដូច្នេះ អាវុធខ្លាំងបំផុតសម្រាប់ប្រឆាំងប្រការអាក្រក់ដែលអ៊ីស្លាមឲ្យយើងប្រើនិងអភិវឌ្ឍនោះ គឺអំណាចចិត្ត ។

ដែលអ៊ីស្លាមបង្ហាត់បង្រៀនយើងធ្វើសក្ការៈ (ស៊្ហូឡាត់) ទាន់ពេលនោះ ព្រោះអ៊ីស្លាមបង្ហាត់យើងឲ្យស្គាល់វិន័យដែលពង្រឹងអំណាចចិត្តយើង ។ ដូចគ្នាដែរ ម្ដាយបង្ហាត់កូនឲ្យចេះចូលដំណេកម៉ោង ៧:០០ យប់ត្រឹម ដូច្នេះកូនស្គាល់វិន័យនឹងចេះចូលដេកដោយខ្លួនឯងមុនយប់ជ្រៅ ។ អ៊ីស្លាមបង្ហាត់យើងថាទាល់តែមានវិន័យក្នុងខ្លួនទើបយើងអាចគ្រប់គ្រងណាហ្វ៍ស៍យើងបាន ។

## មេរៀនទី ៩

# សេចក្តីទៀងត្រង់

ទាំងអស់គ្នាដឹងថាសេចក្តីទៀងត្រង់ជាប្រការសំខាន់ តែវាជាគុណសម្បត្តិមួយដែលពិបាកទទួលបានមកជាទម្លាប់បំផុត ។

យើងនិយាយកុហកប៉ុន្មានដងក្នុងមួយថ្ងៃ ? ជួនកាលដើម្បីគេចវេះមនុស្សឬមុខងារ ជួនកាលដើម្បីដោះខ្លួនពីបញ្ហា ជួនកាលដើម្បីឲ្យគេអួតតែម្យ៉ាង និងដើម្បីឲ្យគេចាប់អារម្មណ៍ខ្លួន ។

ព្រះសាស្តាមូហាំម៉ាដ់ﷺមានព្រះវចនៈថា៖ "ចូរអស់លោកលែងនិយាយកុហក ចូរទម្លាប់ខ្លួននិយាយការពិត ។"

"អ្នកណាធ្លាប់តែនិយាយកុហក អ្នកនោះជាមនុស្សមានពុតត្បុតរហូតដល់ពេលអ្នកនោះជម្រុះចោលទម្លាប់នេះ ។"

មិនត្រូវមានហេតុផលចៀសវាងសេចក្តីទៀងត្រង់ទេ ។ បើអ្នកត្រង់ចំពោះគេឯង បើអ្នកមិនមានអ្វីលាក់បាំងទេ អ្នកប្រាកដជាអាចនិយាយការពិតបានដោយឥតខ្លាច ។

គួរអាន ស៊ូរ៉ោះត៍ អាល់-បាក៏រ៉ោះត៍ អាយ៉ាស់ 42 (2:42) ចែងប្រាប់យើងឲ្យនិយាយការពិត កុំលាក់បាំងវាដោយពាក្យមុសា ថា៖

وَلَا تَلْبِسُواْ ٱلْحَقَّ بِٱلْبَٰطِلِ وَتَكْتُمُواْ ٱلْحَقَّ وَأَنتُمْ تَعْلَمُونَ ﴿٤٢﴾

*42. ចូរពួកអ្នកកុំលាយឡំសេចក្តីពិតជាមួយសេចក្តីមុសាឡើយ ចូរពួកអ្នកកុំបិទបាំងសេចក្តីពិតឡើយ ខណៈដែលពួកអ្នកដឹង ។*

លើសពីនេះទៀត ព្រះសាស្តាមូហាំម៉ាដ់ﷺបានពន្យល់យើងថា៖ "ចូរអស់លោកប្រយ័តទំនាក់ទំនងជាមួយមនុស្សភូតភរ ព្រោះវាដូចមរិចិកា (គឺរូបបំភាន់ភ្នែក) ដែលទាញអ្វីដែលឆ្ងាយមកជិតអស់លោក ទាញអ្វីដែលជិតទៅឆ្ងាយពីអស់

លោក[2] ។"

បើអ្នកមានទម្លាប់និយាយកុហក អ្នកនឹងនិយាយកុហកជាញឹកញយដោយមិនដឹងខ្លួន ។ អ្នកនឹងកុហកគ្រួសារអ្នក មិត្តអ្នកនិងបណ្តាអ្នកដែលអ្នកជួបប្រទះ ។ ក្រោយមក ថ្ងៃមួយ គេនឹងចាប់ថ្នាក់អ្នកបាន អ្នកនឹងទាល់ មិនអាចដោះខ្លួនបានទេ ។ ម្យ៉ាងទៀត បើអ្នកមានទម្លាប់និយាយកុហក អ្នកនឹងធ្វើប្រការអាក្រក់លើសនេះ ។ អំពើអាក្រក់មួយដឹកនាំអ្នកទៅធ្វើអំពើអាក្រក់មួយទៀត ។

[2] មើលសៀវភៅសិក្សាសីលធម៌ថ្នាក់ទី ៦ មេរៀនទី ១៥ ។

## មេរៀនទី ១០

# អៀស្សាន - ស៊ុក្រ៍

إحسان ، شكر

និយាយសរុប មានន័យថាអរព្រះគុណអល់ឡោះហ៊្វ៍ﷻដែលមានព្រះគុណដល់យើង ។

ដឹងព្រះគុណអល់ឡោះហ៊្វ៍ﷻជាប្រការសំខាន់មួយក្នុងពិធីគោរពសាសនា ឬក្នុងជំនឿអ៊ីស្លាម ។ ព្រះសន្តអ៊ីម៉ាំអ៊ុលីعليه السلامមានវចនៈថា៖ "អ៊ីម៉ាន់ (ជំនឿ) ចែកជាពីរប៉ែក មួយប៉ែកនៅលើអំណត់ មួយប៉ែកទៀតនៅលើការដឹងគុណ ។"

គេច្រើនតែសួរថាម្តេចបានជាគេហៅការដឹងគុណនោះ ជាពិធីគោរពសាសនា ។ ព្រះសាស្តាមូហាំម៉ាដ់ﷺបានពន្យល់យើងដោយងាយស្តាប់ថា៖ "មានមនុស្សខ្លះគោរពអល់ឡោះហ៊្វ៍ﷻដើម្បីចង់បានអ្វីដែលខ្លួនប្រាថ្នាចង់បាន នេះគឺការគោរពរបស់អ្នកធ្វើជំនួញ ។ មានមនុស្សខ្លះដែរដែលគោរពអល់ឡោះហ៊្វ៍ﷻព្រោះពួកគេខ្លាចព្រះអង្គﷻ នេះគឺការគោរពរបស់ទាសៈ ។ តែមានអ្នកគោរពអល់ឡោះហ៊្វ៍ﷻដើម្បីអរព្រះគុណព្រះអង្គﷻ នេះគឺការគោរពរបស់បណ្តាអ្នកមានសេរីភាពក្នុងចិត្ត ជាការគោរពប្រសើរបំផុត ។"

អល់ឡោះហ៊្វ៍ﷻមិនទាមទារឲ្យយើងអរគុណព្រះអង្គﷻទេ ។ ព្រះអង្គﷻមិនបានផលប្រយោជន៍នីមួយពីការអរគុណនេះសោះ ។ ជានិច្ចកាល ដែលអ៊ីស្លាមឲ្យយើងធ្វើទង្វើនីមួយនោះព្រោះយើងបានអ្វីមួយពីទង្វើនោះ ។ ដែលយើងអរព្រះគុណអល់ឡោះហ៊្វ៍ﷻនោះ ព្រោះយើងរំលឹកខ្លួនឯងថាព្រះអង្គﷻជាអ្នកផ្តត់ផ្គង់យើង មិនមែនខ្លួនយើងតែម្នាក់ឯងទេ ។

ព្រះអង្គﷻថែងនៅក្នុងគូរអាន ស៊ូរ៉ោះត៍ អាន់-ណាំល៍ អាយ៉ាស់ 40 (27:40) ថា៖

...وَمَن شَكَرَ فَإِنَّمَا يَشْكُرُ لِنَفْسِهِۦ ۖ وَمَن كَفَرَ فَإِنَّ رَبِّى غَنِىٌّ كَرِيمٌ ﴿٤٠﴾

*40. ...អ្នកណាដឹងគុណ អ្នកនោះដឹងគុណសម្រាប់ខ្លួនឯង ។ អ្នកណានិរគុណ ព្រះម្ចាស់ខ្ញុំទ្រង់គ្រប់គ្រាន់សម្រាប់ព្រះអង្គឯងណាស់ (ព្រះអង្គមិនត្រូវការអ្វីឡើយ ។*

*ព្រះអង្គទេជាអ្នកធ្វើឲ្យសព្វសារពើមានបាន) ព្រះអង្គទ្រង់មហាថ្កុំថ្កើង ។"*

អ្នកដឹងគុណនឹងបាននូវផលប្រយោជន៍ពីអល់ឡោះហ៍ﷻជានិច្ច បណ្ដាអ្នកដែលអ្នកនោះនៅជាមួយក៏នឹងបាននូវផលប្រយោជន៍ដែរ ដោយមានហាឌីស្ហខាងក្រោមនេះជាភ័ស្តុតាងគឺៈ "អ្នកដែលសមនឹងបានសេចក្ដីល្អជាងគេគឺបុគ្គលដែលចេះអត់ធ្មត់ពេលប្រាសចាកសេចក្ដីល្អ ដែលចេះអត់ឱនឲ្យគេពេលត្រូវគេបដិសេធសេចក្ដីល្អ ដែលដឹងគុណពេលបានទទួលសេចក្ដីល្អ ។"

បើយើងអរព្រះគុណអល់ឡោះហ៍ﷻ មានកតញ្ញូតាធម៌ចំពោះព្រះអង្គﷻ ព្រះអង្គﷻ ដែលប្រកបដោយព្រះការុញ្ញហឫទ័យលើសលុបនោះ នឹងព្រះរាជទានឲ្យយើងច្រើនទៀត ។ គួរអាន ស៊ូរ៉ោះត៍ អ៊ីបរ៉ហ៊ីម អាយ៉ាស់ 7 (14:7) ចែងថាៈ

وَإِذْ تَأَذَّنَ رَبُّكُمْ لَئِن شَكَرْتُمْ لَأَزِيدَنَّكُمْ ۖ وَلَئِن كَفَرْتُمْ إِنَّ عَذَابِي لَشَدِيدٌ ﴿٧﴾

*7. កាលព្រះម្ចាស់ពួកអ្នកបានប្រកាសថាៈ "បើពួកអ្នកដឹងគុណ យើងនឹងបន្ថែមឲ្យពួកអ្នក[នូវអំណោយផ្សេងៗនៃយើង]ទៀត តែបើពួកអ្នកនិរគុណ ការធ្វើទោសរបស់អញតឹងរ៉ឹងណាស់ ។"*

គួរតែធ្វើបែបនេះ តែមនុស្សបែរជាមានទម្លាប់អាក្រក់ គិតថាអ្វីៗដែលខ្លួនរកបាននោះសុទ្ធតែបានមកដោយការខិតខំរក មិនមែនដោយសារអល់ឡោះហ៍ﷻទេ ។

ពេលយើងប្រាប់គេថាអល់ឡោះហ៍ﷻទេជាអ្នកប្រទានសព្វសារពើឲ្យយើង គេសើចឲ្យយើងដោយតបវិញថាៈ "ប្រាក់ដែលខ្ញុំមានជាប់ខ្លួននិងប្រាក់ដែលខ្ញុំមាននៅក្នុងគណកាធនាគារនោះ អ្នកណាឲ្យខ្ញុំ ? មិនមានអ្នកណាឲ្យខ្ញុំទេ ខ្ញុំរកបានដោយសារខ្ញុំខិតខំធ្វើការ ។"

សឲ្យឃើញថាគេមិនយល់ទេ ។ សូមលើកឡើងនូវឧទាហរណ៍ងាយយល់មួយ ។ ក្មេងប្រុសម្នាក់អង្គុយក្នុងផ្ទះថ្ងៃបុណ្យខួបកំណើតវា ។ មានគេចុចកណ្ដឹងទ្វារផ្ទះ ក្មេងប្រុសនោះក្រោកទៅបើកទ្វារ ។ ពេលបើកទ្វារវាឃើញភ្នាក់ងារប្រៃសណីយ៍ជាមួយកញ្ចប់ធំមួយ ។ ភ្នាក់ងារប្រៃសណីយ៍ឲ្យកញ្ចប់នោះទៅក្មេងប្រុសហើយចាកចេញទៅបន្តការងារទៀត ។ កញ្ចប់នោះធំណាស់ ស្ទើរតែប៉ុនខ្លួនក្មេងប្រុសនោះ ។ វាប្រញាប់បើកកញ្ចប់នោះ ពេលកញ្ចប់បើកឡើងវាឃើញមានទោចក្រយានថ្មីចែសមួយ ។ វាត្រេកអរណាស់ ។ ក្រោយមក ពេល្ងាច ទូរស័ព្ទ រោទ៍ក្មេងប្រុសលើកទូរស័ព្ទ ។ ពេលស្ដាប់ទូរស័ព្ទ វាឮសម្លេងយាយវានិយាយ សួរវាថាៈ "ចៅឯងស្រឡាញ់កង់ដែលយាយផ្ញើទៅឲ្យទេ ?" ក្មេងប្រុសឆ្លើយថាៈ "មិន

មែនយាយទេដែលធ្វើឲ្យកង់ឲ្យខ្ញុំនោះ ! ភ្នាក់ងារប្រៃសណីយ៍ទេ !"

សឲ្យឃើញថាក្មេងប្រុសនេះមិនយល់ទេថា ភ្នាក់ងារប្រៃសណីយ៍គ្រាន់តែយកទោចក្រយានមកឲ្យវាទេ មិនបានធ្វើទោចក្រយាននោះមកឲ្យវាទេ ។

ដូច្នេះ ពេលយើងធ្វើប្រការល្អនីមួយ ឬជាប់លេខមួយ ឬបានរង្វាន់ យើងត្រូវអរព្រះគុណអល់ឡោះហ្ជ៏ ព្រោះព្រះអង្គជាអ្នកបញ្ជូនប្រការល្អៗទាំងនេះមកឲ្យយើង ។

## តើយើងត្រូវមានកតញ្ញូតាធម៌ដូចម្ដេច ?

ពេលបុគ្គលណាមួយបានសម្រេចឬបានជោគជ័យដោយប្រការនីមួយ បុគ្គលនោះត្រូវអរព្រះគុណអល់ឡោះហ្ជ៏ដែលបានធ្វើឲ្យខ្លួនបានសម្រេច ឬបានជោគជ័យ ។

មិនត្រូវសម្ដែងការដឹងគុណនេះដោយការបួងសួង ឬដោយពាក្យសម្ដីតែម្យ៉ាងទេ តែត្រូវសម្ដែងការដឹងគុណនេះដោយទង្វើដែរ ។ មធ្យោបាយប្រសើរបំផុតដើម្បីអរព្រះគុណអល់ឡោះហ្ជ៏ គឺធ្វើប្រការនីមួយដែលមានផលប្រយោជន៍ដល់អ្នកដទៃ ព្រោះអល់ឡោះហ្ជ៏មិនត្រូវការអ្វីសោះឡើយ ។

តែ ទោះបីក្រោយពីបានទទួលឧបការពីអល់ឡោះហ្ជ៏ហើយក៏ដោយ ក៏យើងនៅតែភ្លេចនិងនៅតែថាអ្វីៗទាំងអស់សុទ្ធតែបានមកពីទង្វើរបស់យើងតែម្យ៉ាង ។

អល់ឡោះហ្ជ៏មានព្រះបន្ទូលនៅក្នុងគួរអាន ស៊ូរ៉ោះត៍ អាល់-អ៊ុឌីយ៉ាត់ អាយ៉ាស់ 6-8 (100:6-8) ថា៖

إِنَّ ٱلْإِنسَٰنَ لِرَبِّهِۦ لَكَنُودٌ ۝٦ وَإِنَّهُۥ عَلَىٰ ذَٰلِكَ لَشَهِيدٌ ۝٧ وَإِنَّهُۥ لِحُبِّ ٱلْخَيْرِ لَشَدِيدٌ ۝٨

*6. មនុស្ស[ដែលគ្មានការចេះដឹង]អកតញ្ញូចំពោះព្រះម្ចាស់ខ្លួនមែន 7. ខ្លួនគេផ្ទាល់ជាសាក្សីនៃរឿងនោះ 8. ពិតណាស់ ខ្លួនគេស្រឡាញ់ទ្រព្យសម្បត្តិណាស់ [ទោះបីទ្រព្យទាំងនោះជាទ្រព្យខុសច្បាប់ក៏ដោយ] ។*

ក្រោយពីបានស្វ៊ឡាត់រួច យើងគប្បីក្រាបប្រណិប័តន៍ស៊ូយ៉ូដ្ និយាយត្រង់ៗដាក់អល់ឡោះហ្ជ៏និងអរព្រះគុណព្រះអង្គត្រង់ៗ ក្នុងពេលក្រាបប្រណិប័តន៍នេះ

ដែលព្រះអង្គ عزّ وجلّ មានព្រះឧបការគុណដល់យើងក្នុងថ្ងៃនោះ អរព្រះគុណព្រះអង្គ عزّ وجلّ ដែលយើងពុំបានជួបប្រទះគ្រោះថ្នាក់ និងដែលព្រះអង្គ عزّ وجلّ បានឲ្យយើងរស់រានមានជីវិតមួយថ្ងៃទៀត ។

## មេរៀនទី ១១

# សប្បុរសធម៌

មានន័យថាត្រូវស្រឡាញ់មនុស្សដូចគ្នា ត្រូវជួយជ្រោមជ្រែងជនដែលត្រូវការជំនួយ ។

សប្បុរសធម៌មានសារៈសំខាន់កំពូលក្នុងសាសនាអ៊ីស្លាម ។ ជួយបណ្ដាជនរងគ្រោះជាប្រការសំខាន់បំផុតមួយក្នុងការរស់នៅក្នុងសហគមន៍ និងក្នុងសីលធម៌អ៊ីស្លាម ។

### ហេតុអ្វីយើងត្រូវជួយសង្គ្រោះជនរងគ្រោះ ?

អល់ឡោះហ្ជ៏ជួយយើងពេលយើងជួបប្រទះការលំបាក យើងស្ទើរតែមិនមានពេលអរព្រះគុណព្រះអង្គ ទេ ។ ហេតុអ្វីយើងមិនព្រមជួយមនុស្សដូចគ្នា ថ្វីបើអល់ឡោះហ្ជ៏មិនដែលបដិសេធជួយយើងសោះនោះ ?

អល់ឡោះហ្ជ៏បានប្រាប់ព្រះសាស្ដាមូសា ﷺ នៅក្នុង ហាឌីស្ហ អាល់-គុដ្ស៊ី (الحديث القدسي) ថា៖ "មូសា ﷺ អើយ ពេលអ្នក ﷺ ធ្វើល្អចំពោះបណ្ដាសត្វលោករបស់អញ (គឺមនុស្សទាំងឡាយ) អញពេញចិត្តណាស់ ដូចអ្នក ﷺ បានធ្វើល្អមកលើខ្លួនអញអញ្ចឹង ។"

សឲ្យឃើញថាលើសពីធ្វើទង្វើប្រកបដោយសប្បុរសធម៌ អល់ឡោះហ្ជ៏ថែមទាំងគាប់ចិត្តអ្នក ។

ដើម្បីជាមនុស្សសប្បុរស អ្នកមិនចាំបាច់មានប្រាក់ទេ ។ ផ្ទុយទៅវិញ ទង្វើសប្បុរសធម៌មួយប្រភេទដែលជាទីស្រឡាញ់និងប្រសើរបំផុត គឺបរិច្ចាគពេលវេលាសម្រាប់ផ្ដល់ផលប្រយោជន៍ល្អប្រពៃ ។

ពេលបុគ្គលណាមួយបរិច្ចាគអ្វីមួយ ទោះបីប្រាក់ក្ដី ពេលវេលាក្ដី បុគ្គលនោះមានអារម្មណ៍ដូចជាបានបាត់បង់អ្វីមួយ ។ តែអល់ឡោះហ្ជ៏បានសន្យានៅក្នុងគួរអាន ស៊ូរ៉ោះត៍ អាល់-បាក៏រ៉ោះត៍ អាយ៉ាស់ 261 (2:261) ថា៖

مَّثَلُ ٱلَّذِينَ يُنفِقُونَ أَمْوَٰلَهُمْ فِى سَبِيلِ ٱللَّهِ كَمَثَلِ حَبَّةٍ أَنۢبَتَتْ سَبْعَ سَنَابِلَ فِى كُلِّ سُنۢبُلَةٍ مِّا۟ئَةُ حَبَّةٍ ۗ وَٱللَّهُ يُضَٰعِفُ لِمَن يَشَآءُ ۗ وَٱللَّهُ وَٰسِعٌ عَلِيمٌ ﴿٢٦١﴾

*261. បណ្ដាអ្នកចាយវាយទ្រព្យរបស់ខ្លួនលើមាគ៌ាអល់ឡោះហ្ 3 ប្រៀបបាននឹងគ្រាប់ពូជដែលដុះប្រាំពីរកួរក្នុងមួយគ្រាប់ មួយកួរៗមានមួយរយគ្រាប់ ។ អល់ឡោះហ្ 3 មានព្រះបំណង បង្កើនឲ្យអ្នកណាមួយស្រេចតែលើព្រះអង្គ ។ អល់ឡោះហ្ 3 មានព្រះហឫទ័យទូលំទូលាយ ព្រះអង្គទ្រង់ញាណសព្វសារពើ ។*

បានសេចក្ដីថាអល់ឡោះហ្ 3 ﷻ នឹងបន្ថែមគ្រឿងទ្រទ្រង់ជីវិតឲ្យអ្នក ពេលអ្នកបរិច្ចាគឲ្យអ្នកដទៃមួយចំណែកនៃអ្វីដែលអ្នករកបានមកនោះ ។

អល់ឡោះហ្ 3 ﷻ មានព្រះបន្ទូលដែរថាឲ្យបរិច្ចាគដោយស្ងាត់ៗ និងដោយឲ្យគេឃើញ ។

យើងគប្បីបរិច្ចាគដោយស្ងាត់ៗដើម្បីនឹងឲ្យនៀត (បំណង) យើងបរិសុទ្ធ ក្នុងនាមសេចក្ដីស្រឡាញ់អល់ឡោះហ្ 3 ﷻ ។ ធ្វើដូច្នេះដើម្បីនឹងកុំឲ្យខ្លួនយើងបានចិត្តពេលបរិច្ចាគនៅពីមុខមនុស្សនោះ ។

តែបើយើងគិតថាបរិច្ចាគឲ្យគេឃើញនោះ នឹងធ្វើឲ្យអ្នកផងយកតម្រាប់តាមយើង យើងគប្បីបរិច្ចាគដោយឲ្យគេឃើញ ។ គ្មានសប្បុរសធម៌ សង្គមដែលយើងរស់នោះនឹងទៅជាសង្គមអាត្មានិយម គ្មានការអើពើ ។

ចូរកុំភ្លេចសោះថាអល់ឡោះហ្ 3 ﷻ ឲ្យអ្នកមានបានដើម្បីសាកល្បងអ្នក ។ ថ្ងៃជំនុំជម្រះ អល់ឡោះហ្ 3 ﷻ នឹងសួរអ្នកថា៖ "អ្នកបានធ្វើខ្លះជាមួយទ្រព្យដែលអញ ﷻ បានប្រទានឲ្យអ្នក ? អ្នកបានចាយវាយវាសម្រាប់ខ្លួនឯងឬក៏អ្នកបានបែងចែកវាជាមួយសត្វលោកឯទៀតរបស់អញ ﷻ ?"

**ទ្រព្យសម្បត្តិទាមទារឲ្យមានការទទួលខុសត្រូវច្រើន** ព្រោះមនុស្សសម្បូរទ្រព្យមានឱកាសច្រើនជាងអ្នកក្រសម្រាប់ប្រព្រឹត្តខ្លួនជាអ្នកមានសប្បុរសធម៌ (គឺមានចិត្តទូលាយ) ។ ថ្ងៃគ្គីយ៉ាម៉ាត់ អល់ឡោះហ្ 3 ﷻ នឹងសួរថាអ្នកណាជាមូលហេតុធ្វើឲ្យអ្នកក្រវេទនា ។ ចូរបកុំបណ្ដោយឲ្យទង្វើអ្នកធ្វើឲ្យអ្នកមានទោសក្នុងថ្ងៃនោះ ។

## ការប្រមូលទុក

ការប្រមូលទុកគឺការសន្សំវត្ថុផ្សេងៗទុកមួយកន្លែង មិនប្រើប្រាស់វាទេ ។ ធ្វើដូច្នេះអាក្រក់ណាស់ ព្រោះអ្នកមិនអើពើអ្នកផងទេដោយទុកសម្រាប់តែខ្លួនឯង ។

បុគ្គលដែលប្រមូលវត្ថុទុកជាមនុស្សលោភនិងជាមនុស្សកំណាញ់ ។ លោភព្រោះបុគ្គលនោះសន្សំទុកសព្វសារពើដែលខ្លួនប្រទះ ។ កំណាញ់ព្រោះបុគ្គលនោះមិនប្រើប្រាស់អ្វីដែលខ្លួនមានទេ តែរក្សាអ្វីៗទាំងនោះទុកព្រោះតែចូលចិត្តរក្សាទុក ។

## ហេតុអ្វីប្រមូលទុកអ្វីៗដែលអ្នកស្រឡាញ់នោះជាប្រការមិនត្រឹមត្រូវ ?

បើអ្នកស្រឡាញ់វត្ថុ អ្នកអាចទុកវាបានឲ្យតែប្រើប្រាស់វា ។ បើអ្នកមិនប្រើវាទេ អ្នកឃើញប្រយោជន៍ផ្ទាល់ខ្លួនច្រើនជាងគិតដល់អ្នកដទៃដែលអាចត្រូវការអ្វីដែលអ្នកមាននោះតែមិនមានសមត្ថភាពរកវត្ថុនោះបានទេ ។

សន្សំនិងប្រមូលទុកមិនដូចគ្នាទេ ។ បើអ្នកសន្សំតែមឬសៀវភៅ អ្នកស្រឡាញ់វត្ថុទាំងនេះណាស់ វាជាការកំសាន្តដែលអាចអត់ឱនឲ្យបាន ។ តែបើអ្នកសន្សំវត្ថុព្រោះអ្នកមិនចង់ឲ្យអ្នកដទៃប្រើប្រាស់វាទេ ចង់ទុកវាសម្រាប់តែខ្លួនអ្នកនេះគឺការប្រមូលទុក ។

## អ្វីទៅការប្រមូលទុកដែលអាក្រក់បំផុត ?

ការប្រមូលទុកដែលអាក្រក់បំផុត គឺការប្រមូលទុកវត្ថុត្រូវការចាំបាច់បំផុតសម្រាប់ការរស់នៅ ។ ឧទាហរណ៍ ខ្ញុំមានអណ្តូងទឹកមួយនៅក្នុងចម្ការខ្ញុំ ។ បើខ្ញុំផឹកទឹកតែបន្តិចបន្តួច មិនឲ្យទឹកនោះទៅអ្នកជិតខាងខ្ញុំទេដែលកំពុងស្រេកនោះ វាជាការប្រមូលទុកនូវរបស់ត្រូវការចាំបាច់បំផុត ។

បុគ្គលកំណាញ់អាចគិតថាប្រាក់និងទ្រព្យដែលខ្លួនប្រមូលទុកនោះ មានតម្លៃណាស់ តែមិនដូច្នេះទេ ។ សម្រាប់អល់ឡោះ ﷻ វាពុំមានតម្លៃសោះ ។

ព្រះសន្ដអ៊ីម៉ាំអាលីصلوات الله عليه والسلامមានវចនៈថា៖ "កាក់របស់បុគ្គលកំណាញ់មិនមានតម្លៃជាងដុំថ្មទេ ។"

អល់ឡោះហ្ជ័លពន្យល់ប្រាប់យើងនៅក្នុងគួរអាន ស៊ូរ៉ោះត៍ យូនុស អាយ៉ាត់ 57-58 (10:57-58) ថា៖

يَـٰٓأَيُّهَا ٱلنَّاسُ قَدْ جَآءَتْكُم مَّوْعِظَةٌ مِّن رَّبِّكُمْ وَشِفَآءٌ لِّمَا فِى ٱلصُّدُورِ وَهُدًى وَرَحْمَةٌ لِّلْمُؤْمِنِينَ ۝٥٧ قُلْ بِفَضْلِ ٱللَّهِ وَبِرَحْمَتِهِۦ فَبِذَٰلِكَ فَلْيَفْرَحُوا۟ هُوَ خَيْرٌ مِّمَّا يَجْمَعُونَ ۝٥٨

*57. មនុស្សអើយ មានការណែនាំ (គឺគួរអាន) ដែលមកពីព្រះម្ចាស់ពួកអ្នក [មាន]ការព្យាបាល[ឲ្យជាសះស្បើយ]សម្រាប់អ្វីដែលនៅក្នុងទ្រូង [មាន]មគ្គទេសក៍ដឹកនាំ និងព្រះមេត្តាធម៌សម្រាប់អ្នកមានសទ្ធាទាំងឡាយ មកដល់ពួកអ្នកហើយ ។ 58. ចូរអ្នកថ្លែងថា៖ "អាស្រ័យព្រះករុណាប្រណីរបស់អល់ឡោះហ្វ៍និងអាស្រ័យព្រះមេត្តាធម៌របស់ព្រះអង្គ ចូរពួកគេត្រេកត្រអាលក្នុងអ្វីទាំងនេះចុះ [ដើម្បីកែតម្រង់ខ្លួនឲ្យកាន់តែល្អឡើងនិងធានាបាននូវសុភមង្គលលោកនេះនិងលោកមុខ] ។ វាប្រសើរជាងអ្វីដែលពួកគេប្រមូលទុក ។"*

សឲ្យឃើញថា អល់ឡោះហ្ជ័លប្រទានព្រះធម៌មេត្តានិងមគ្គទេសក៍ដឹកនាំមកឲ្យយើងតាមរយៈអ៊ីស្លាម ដើម្បីព្យាបាលយើងឲ្យជាសះស្បើយពីជម្ងឺនៅក្នុងចិត្តយើង យើងគប្បីរីករាយ ។ ព្រះគុណទាំងនេះរបស់អល់ឡោះហ្ជ័លសំខាន់និងមានតម្លៃជាងវត្ថុលោកិយដែលយើងប្រមូលទុកនោះណាស់ ។

លោកនេះមានមែននិងពិតប្រាកដមែន ។ ពុំមានអ្នកណាមួយបដិសេធប្រការនេះទេ ។ តែលោកមុខក៏មានមែនដែរ យើងនឹងរស់នៅក្នុងលោកមុខនោះរហូតតរៀងទៅ ។ ប្រសើរបំផុតគឺត្រូវលះបង់ប្រណិតភាពខ្លះនៃលោកនេះដើម្បីសន្សំនូវប្រណិតភាពសម្រាប់លោកមុខ ។

បើអ្នកធ្វើការ អ្នកចង់ទិញផ្ទះមួយ អ្នកត្រូវសន្សំប្រាក់ដែលអ្នករកបានមកនោះលុះត្រាមានថវិកាគ្រប់ ។ អ្នកដឹងថាអ្នកនឹងរស់នៅក្នុងផ្ទះអ្នកមួយរយៈពេលដ៏យូរ

ថាអ្នកសុខចិត្តអត់ទ្រាំការលំបាកខ្លះពីឥឡូវ ដើម្បីនឹងបានរស់នៅដោយសេចក្តីសុខសាន្តពេលអនាគតក្នុងផ្ទះថ្មី ។

ស្រដៀងគ្នាដែរ អ្នកសន្សំក្នុងលោកនេះដើម្បីអ្នកនឹងអាចរស់នៅបានយ៉ាងស្រណុកក្នុងលោកមុខ ។ អ្នកមិនចាំបាច់សន្សំប្រាក់ឬទ្រព្យទាំងអស់ដូចបុគ្គលកំណាញ់នោះទេ តែអ្នកត្រូវសន្សំស្វាប៉ប់ (រង្វាន់) និងទង្វើល្អដោយប្រើទ្រព្យសម្បត្តិអ្នកសម្រាប់ជួយអ្នកដទៃ ។

## មេរៀនទី ១២

# មានយុត្តិធម៌ក្នុងខ្លួន វិនិច្ឆ័យប្រឆាំងអ៊ីស្លាម

មនុស្សទាំងអស់ មានក្តី ក្រក្តី សក្តី ខ្មៅក្តី សុទ្ធតែស្មើភាពគ្នា ។ នេះគឺគោលសីលធម៌សំខាន់មួយដែលអ៊ីស្លាមដាក់ឲ្យអនុវត្តិជានិច្ច ។ បើមនុស្សទូទៅស្មើភាពគ្នាសម្រាប់អល់ឡោះហ៏ عزّ وجلّ គេត្រូវប្រព្រឹត្តចំពោះមនុស្សទូទៅស្មើគ្នាដែរ (ដោយសមភាព) ។ ដូច្នេះឯងបានជាសំខាន់ណាស់ដែលអ្នកត្រូវមានយុត្តិធម៌និងសមធម៌ក្នុងខ្លួនពេលអ្នកធ្វើការវិនិច្ឆ័យដែលជាប់ទាក់ទិននឹងអ្នកដទៃនោះ ។

សូមលើកឡើងនូវរឿងមួយជាឧទាហរណ៍ ។

មានបុរសម្នាក់ធ្វើដំណើរទៅកាន់គូហ្វាស់ ។ ពេលទៅដល់គូហ្វាស់ គាត់សម្រេចចិត្តទៅសូមស្នាក់នៅឯផ្ទះព្រះសន្តអ៊ីម៉ាំអ៊ីអ្នាលី صلوات الله عليه والسلام ។ គាត់បានស្នាក់ឯផ្ទះអ៊ីម៉ាំអ្នាលី صلوات الله عليه والسلام ពីរបីថ្ងៃដោយមិនប្រាប់ឲ្យដឹងគោលបំណងទេ ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام ក៏មិនសួរគាត់ដែរ ។ ទីបំផុត បុរសនេះបានថា៖ "ទូលបង្គំមានជម្លោះជាមួយគេនៅស្រុកនេះ ។ ទូលបង្គំមកនេះដើម្បីដោះស្រាយបញ្ហានេះ ។ តើព្រះអង្គ صلوات الله عليه والسلام យល់ព្រមធ្វើអាជ្ញាកណ្តាលទេ ?" ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام បានសួរគាត់ថា៖ "លោកជាភាគីក្តីក្នុងជម្លោះនេះ មែនទេ ?" បុរសបានតបថា៖ "មែន ។" ព្រះសន្តអ៊ីម៉ាំ صلوات الله عليه والسلام មានវចនៈថា៖ "ដូច្នេះ លោកមិនត្រូវយកខ្ញុំ صلوات الله عليه والسلام ធ្វើជាអាជ្ញាកណ្តាលរបស់លោកទេ ។ បើលោកចង់ឲ្យខ្ញុំ صلوات الله عليه والسلام កាត់ក្តីឲ្យលោក លោកមិនត្រូវស្នាក់នៅឯផ្ទះខ្ញុំ صلوات الله عليه والسلام ទេ ។ ព្រះសាស្តាមូហ៊ាំម៉ាដ់ صلى الله عليه وآله وسلم មានព្រះវចនៈថា៖ "ពេលបុគ្គលណាម្នាក់ត្រូវជ្រើសរើសជាអ្នកកាត់ក្តីឬជាអាជ្ញាកណ្តាលក្នុងបណ្តឹងនីមួយ បុគ្គលនោះមិនត្រូវទទួលភាគីក្តីណាមួយឲ្យស្នាក់នៅឯផ្ទះខ្លួនទេ លើកលែងតែភាគីក្តីទាំងពីរនេះត្រូវគេអញ្ជើញឲ្យស្នាក់នៅ ។""

យុត្តិធម៌ចាប់ផ្តើមពីខ្លួនឯងទៅ ។ អ្នកមិនអាចកុហកខ្លួនឯងបានទេ ។ បើអ្នកអាចត្រឹមត្រូវចំពោះខ្លួនឯងបាន ត្រឹមត្រូវចំពោះអ្នកដទៃក៏ជាការងាយស្រួល ។

ព្រះសន្ដអ៊ីម៉ាំអាលី عليه السلام មានវចនៈថា៖ "បុគ្គលប្រកបដោយយុត្តិធម៌ដាច់គេ គឺបុគ្គលដែលកាត់ក្ដីមកលើខ្លួនឯងដោយគ្មានអ្នកដទៃកាត់ក្ដីឲ្យខ្លួនទេ ។"

ពេលយើងធ្វើការវិនិច្ឆ័យដែលទាក់ទិននឹងអ្នកដទៃ យើងត្រូវវិនិច្ឆ័យដោយគិតដល់ប្រការល្អនិងប្រការអាក្រក់ មិនមែនយោគយល់ដល់មិត្តឬសត្រូវយើងទេ ។ ទោះបីទាក់ទិននឹងគ្រួសារយើងក៏ដោយ សំខាន់បំផុតគឺត្រូវនិយាយតែការពិត ។

ព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ អាន់-នីសាអ៍ អាយ៉ាស់ 135 (4:135) ពន្យល់ប្រាប់យើងថា៖

۞يَٰٓأَيُّهَا ٱلَّذِينَ ءَامَنُواْ كُونُواْ قَوَّٰمِينَ بِٱلۡقِسۡطِ شُهَدَآءَ لِلَّهِ وَلَوۡ عَلَىٰٓ أَنفُسِكُمۡ أَوِ ٱلۡوَٰلِدَيۡنِ وَٱلۡأَقۡرَبِينَۚ إِن يَكُنۡ غَنِيًّا أَوۡ فَقِيرٗا فَٱللَّهُ أَوۡلَىٰ بِهِمَاۖ فَلَا تَتَّبِعُواْ ٱلۡهَوَىٰٓ أَن تَعۡدِلُواْۚ وَإِن تَلۡوُۥٓاْ أَوۡ تُعۡرِضُواْ فَإِنَّ ٱللَّهَ كَانَ بِمَا تَعۡمَلُونَ خَبِيرٗا ١٣٥

*135. បណ្ដាអ្នកមានសទ្ធាអើយ ចូរពួកអ្នករក្សាយុត្តិធម៌ ចូរជាសាក្សី[ដ៏ស្មោះ]ដើម្បីអល់ឡោះហ៍ ទោះជាជំទាស់នឹងខ្លួនពួកអ្នកក្ដី [ជំទាស់នឹង]ឪពុកម្ដាយ[ពួកអ្នក]ក្ដី ឬ[ជំទាស់នឹង]សាច់ញាតិក្ដី ទោះជា[អ្នកត្រូវចោទជា]អ្នកមានឬជាអ្នកក្រក្ដី អល់ឡោះហ៍មានព្រះធម៌មេត្តាជាងគេចំពោះទាំងពីរនេះ ។ ដូច្នេះចូរពួកអ្នកកុំតាមចំណង់[របស់ពួកអ្នក]ឡើយ ក្រែងលោពួកអ្នកនឹងលំអៀង[ពីយុត្តិធម៌] ។ បើពួកអ្នកបែរក្រោយ (គឺផ្លាស់ប្ដូរសម្ដី) ឬពួកអ្នកគេចវេះ អល់ឡោះហ៍ទ្រង់ញាណច្បាស់បំផុតនូវអំពើដែលពួកអ្នកសាង ។*

បើអ្នកដឹងខ្លួនថាមិនអាចជាអ្នកកណ្ដាលបានទេ (គឺគ្មានអព្យាក្រឹតភាព) ក្នុងការវិនិច្ឆ័យ ចូរអ្នកសូមឲ្យគេផ្សេងជាអ្នកកាត់ក្ដី ។

អ៊ីស្លាមពន្យល់ប្រាប់យើងថា មានយុត្តិធម៌ក្នុងខ្លួនជាប្រការសំខាន់ណាស់ ។ មានតែបុគ្គលដែលមិនជឿអល់ឡោះហ៍ عز وجل ទេ ឬដែលមិនយកចិត្តទុកដាក់នឹងព្រះបន្ទូលអល់ឡោះហ៍ عز وجل ទេដែលប្រព្រឹត្តអំពើអយុត្តិធម៌នោះ ។

ٱلْمُنَٰفِقُونَ وَٱلْمُنَٰفِقَٰتُ بَعْضُهُم مِّنۢ بَعْضٍۚ يَأْمُرُونَ بِٱلْمُنكَرِ وَيَنْهَوْنَ عَنِ ٱلْمَعْرُوفِ وَيَقْبِضُونَ أَيْدِيَهُمْۚ نَسُوا۟ ٱللَّهَ فَنَسِيَهُمْۗ إِنَّ ٱلْمُنَٰفِقِينَ هُمُ ٱلْفَٰسِقُونَ ﴿٦٧﴾

*67. ពួកលាក់ពុតប្រុសនិងពួកលាក់ពុតស្រីជាពួកតែមួយ ។ ពួកគេបញ្ជាឲ្យប្រព្រឹត្តអាក្រក់ ហាមប្រព្រឹត្តអំពើល្អ ហើយពួកគេក្តាប់ដៃជិត (គឺមិនព្រមបរិច្ចាគចាយវាយលើមាគ៌ាអល់ឡោះហ៍ទេ) ។ ពួកគេភ្លេចអល់ឡោះហ៍ ដូច្នេះព្រះអង្គភ្លេចពួកគេ ។ ពិតណាស់ ពួកលាក់ពុតជាជនកំណាច ។* (ស៊ូរ៉ោះត្ទ័ អាត់-តៅបាស្ទ៉ អាយ៉ាស្ទ៉ 67 (9:67))

អល់ឡោះហ្ទ៍ﷻដាក់ព្រះរាជបញ្ជាឲ្យយើងមានយុត្តិធម៌ក្នុងខ្លួន ។ បើយើងបំភាន់គេឬប្រព្រឹត្តិខ្លួនមិនត្រឹមត្រូវ តើយើងអាចសង្ឃឹមថាអល់ឡោះហ្ទ៍ﷻនឹងប្រព្រឹត្តត្រឹមត្រូវដាក់យើងបានដូចម្តេចទៅក្នុងថ្ងៃជំនុំជម្រះនោះ ?

۞إِنَّ ٱللَّهَ يَأْمُرُ بِٱلْعَدْلِ وَٱلْإِحْسَٰنِ وَإِيتَآئِ ذِى ٱلْقُرْبَىٰ وَيَنْهَىٰ عَنِ ٱلْفَحْشَآءِ وَٱلْمُنكَرِ وَٱلْبَغْىِۚ يَعِظُكُمْ لَعَلَّكُمْ تَذَكَّرُونَ ﴿٩٠﴾

*90. អល់ឡោះហ៍ដាក់បញ្ជាឲ្យប្រព្រឹត្តដោយយុត្តិធម៌ ឲ្យធ្វើអំពើល្អ[ចំពោះអ្នកដទៃ] និងឲ្យប្រគល់ឲ្យញាតិសន្តាន[នូវសិទ្ធិពួកគេ] ។ ព្រះអង្គហាមប្រព្រឹត្តអសីលធម៌ អំពើអាក្រក់និងអំពើកំណាច ។ ព្រះអង្គដាស់តឿនពួកអ្នកដើម្បីពួកអ្នកនឹងយកចិត្តទុកដាក់ ។*(ស៊ូរ៉ោះត្ទ័ អាន់-ណាស្ទ៉ល៍ អាយ៉ាស្ទ៉ 90 (16:90))

អល់ឡោះហ្ទ៍ﷻប្រាប់យើងថា មានយុត្តិធម៌ក្នុងខ្លួនដូចខ្លាចក្រែងអល់ឡោះហ្ទ៍ﷻដែរ អល់ឡោះហ្ទ៍ﷻចូលចិត្តប្រការទាំងពីរនេះ ។

يَٰٓأَيُّهَا ٱلَّذِينَ ءَامَنُوا۟ كُونُوا۟ قَوَّٰمِينَ لِلَّهِ شُهَدَآءَ بِٱلْقِسْطِۖ وَلَا يَجْرِمَنَّكُمْ شَنَـَٔانُ قَوْمٍ عَلَىٰٓ أَلَّا تَعْدِلُوا۟ۚ ٱعْدِلُوا۟ هُوَ أَقْرَبُ لِلتَّقْوَىٰۖ وَٱتَّقُوا۟ ٱللَّهَۚ إِنَّ ٱللَّهَ خَبِيرٌۢ بِمَا تَعْمَلُونَ ﴿٨﴾

*8. បណ្តាអ្នកមានសទ្ធាអីយ ចូរពួកអ្នកម៉ឹងម៉ាត់ដើម្បីអល់ឡោះហ៍ ជាសាក្សីប្រកបដោយសមធម៌ ។ ចូរកុំបណ្តោយឲ្យកំហឹងដែលមានចំពោះជនមួយក្រុមញ៉ាំងពួកអ្នកឲ្យប្រព្រឹត្តខុសគន្លងធម៌[និងលំអៀង]ឡើយ ។ ចូរពួកអ្នកប្រព្រឹត្តដោយយុត្តិធម៌ ព្រោះវានៅជិតជំនឿស៊ប់ចិត្ត[ចំពោះអល់ឡោះហ៍] ចូរពួកអ្នកខ្លាចក្រែងអល់ឡោះហ៍ ។ អល់ឡោះហ៍ទ្រង់ញាណទង្វើរបស់ពួកអ្នក ។* (ស៊ូរ៉ោះត្ទ័ អាល់-

ម៉ាអ៊ីដាស់ អាយ៉ាស់ 9 (5:8))

## មេរៀនទី ១៣

# ស្រឡាញ់អំណាច កិត្តិយសនិងទ្រព្យសម្បត្តិ

សេចក្ដីស្រឡាញ់ដែលបុគ្គលនីមួយមានចំពោះសេចក្ដីល្បីឈ្មោះនោះ កើតមកពីការចង់ប្រសើរជាងអ្នកដទៃ និងកើតមកពីការចង់ឲ្យគេកោតសរសើរខ្លួន ។

បើអ្នកមើលជុំវិញខ្លួនអ្នក អ្នកនឹងឃើញមនុស្សខិតខំធ្វើប្រការនីមួយជានិច្ច ប្រការនោះអាចជាមុខរបរដើម្បីបានមកនូវប្រាក់ចំណូល អាចជាការធ្វើកីឡា ឬអាចជាការសិក្សាដើម្បីប្រលង ។ បើអ្នកសួរពួកគេនោះខ្លះថាហេតុអ្វីខិតខំម្ល៉េះ ពួកគេនឹងឆ្លើយអ្នកថាដើម្បីឲ្យគេចាប់អារម្មណ៍ខ្លួន ។

គំនិតបែបនេះផ្ទុយពីទ្រឹស្ដីអ៊ីស្លាម ។ អ្វីៗដែលគេធ្វើ សព្វទង្វើត្រូវធ្វើដើម្បីផ្គាប់ចិត្តអល់ឡោះហ៍ﷻ (ﷲ-លិលឡាស្ស៊) ។ មិនបានសេចក្ដីថាយើងត្រូវអង្គុយមួយកន្លែង ធ្វើសក្ការៈស៊្វឡាត់ ២៤ ម៉ោងក្នុងមួយថ្ងៃនោះទេ តែបានសេចក្ដីថាយើងត្រូវប្រកបកិច្ចការដើម្បីអភិវឌ្ឍខ្លួនឲ្យកាន់តែប្រសើរឡើង គ្រប់វិស័យ ដើម្បីយើងនឹងអាចយកចំណេះយើងទៅជួយអ្នកដទៃបាន ។

សេចក្ដីស្រឡាញ់អំណាចនិងទ្រព្យសម្បត្តិនេះនៅក្នុងចំណង់ឥតខ្លឹមសារ នៅក្នុងខ្លួនមនុស្ស ។ សហាគមន៍ច្រើនបានច្បាំងគ្នា គ្រួសារច្រើនបានបែកបាក់ ដោយសារមនុស្សដែលប្រយុទ្ធគ្នាដើម្បីឋានៈខ្ពស់ជាងមនុស្សឯទៀត ។

ព្រះសន្ទអ៊ីម៉ាំអាលីصلوات الله عليه والسلامមានវចនៈថា៖ "ចំណង់ទេរទៅរកការបំផ្លិចបំផ្លាញការយល់ដឹង ។"

គេអាចឃើញបានប្រការនេះនៅក្នុងជីវិតពិត ពេលមនុស្សប្រព្រឹត្តអំពើមិនសមហេតុផលដើម្បីចង់បានអំណាចនិងទ្រព្យសម្បត្តិ ។ ពួកគេអាចបោកប្រាស់និងមិនយល់ទេថាអ្វីដែលខ្លួនធ្វើនោះជាប្រការអាក្រក់ ។ ពួកគេបាត់បង់វិចារណញ្ញាណទៅជាមានះ ។

ជាមេគេមិនមែនជាប្រការអាក្រក់ទេ មានបានឬល្បីល្បាញឈ្មោះឬមានវត្ថុ

មានតម្លៃនោះមិនមែនជាប្រការអាក្រក់ទេ ។ តែចាំបាច់ត្រូវមានលក្ខខណ្ឌមួយគត់ គឺ បុគ្គលត្រូវមានតាក់វ៉ា (تقوى ដឹងជានិច្ចថាមានអល់ឡោះហ៊្ញ عزّ وجلّ) ។ យើងត្រូវចងចាំជានិច្ចថាអ្វីៗដែលយើងមាននោះ អល់ឡោះហ៊្ញ عزّ وجلّជាអ្នកប្រទានឲ្យយើង ហើយដែលព្រះអង្គ عزّ وجلّឲ្យយើងនោះដើម្បីនឹងឲ្យយើងអាចជួយអ្នកដទៃបាន ។

ត្រូវអនុវត្តិប្រការនេះចាប់ពីយើងនៅរៀន រហូតដល់យើងទៅជាមនុស្សចាស់ ។ យើងមិនត្រូវព្យាយាមឡើងទៅដល់កំពូលឬមានបានដើម្បីនឹងឲ្យគេកោតសរសើរយើងតែម្យ៉ាងទេ ។

ចំណុចសំខាន់មួយដែលមនុស្សភាគច្រើនមិនយល់គឺ បើអ្នកនៅក្នុងចំណោមមនុស្សដែលមានគុណសម្បត្តិ ប្រាក់ក្ដី កេរ្តិ៍ឈ្មោះក្ដី អ្នកទៅជាមេគេជាស្វ័យប្រវត្តបើអ្នកប្រកបដោយតាក់វ៉ាផង ។ អ្នកមិនចាំបាច់ដេញតាមអំណាចទេ អំណាចទេដែលដេញតាមរកអ្នក ។

ព្រះសន្តអ៊ីម៉ាំអាលី صلوات الله عليه والسلامមានវចនៈថា៖ "សេចក្ដីស្រឡាញ់លោកិយជាមេរបស់ប្រការអាក្រក់ទាំងអស់ ។"

បានសេចក្ដីថា បើអ្នកប្រកបកិច្ចការដោយមានតែលោកនេះទេនៅក្នុងអារម្មណ៍ ចំណង់របស់អ្នកនឹងឈ្នះអ្នក អ្នកនឹងសាងបាបមួយហើយមួយទៀត ។

ព្រះអង្គ صلوات الله عليه والسلامមានវចនៈដែរថា៖ "សេចក្ដីស្រឡាញ់លោកនេះជាដើមហេតុរបស់ទុក្ខវេទនា ។"

បានសេចក្ដីថា អារម្មណ៍ទាំងមូលរបស់អ្នកផ្ដោតតែលើការបានទៅជាអ្នកធំដោយមធ្យោបាយគ្រប់បែប (ដោយប្រាក់ ដោយអំណាច ដោយកិត្តិយស) ក្នុងលោកនេះតែម្យ៉ាង យើងអាចបានប្រការទាំងអស់នេះសម្រាប់លោកនេះមែន តែយើងនឹងពុំមានសុភមង្គលពិតទេ ។

"មានមនុស្សខ្លះគោរពអល់ឡោះហ៊្ញ عزّ وجلّដើម្បីចង់បានអ្វី ដែលខ្លួនប្រាថ្នាចង់បាននេះគឺការគោរពរបស់អ្នកធ្វើជំនួញ ។ មានមនុស្សខ្លះដែរដែលគោរពអល់ឡោះហ៊្ញ عزّ وجلّព្រោះពួកគេខ្លាចព្រះអង្គ عزّ وجلّ នេះគឺការគោរពរបស់ទាសៈ ។ តែមានអ្នកគោរពអល់ឡោះហ៊្ញ عزّ وجلّដើម្បីអរព្រះគុណព្រះអង្គ عزّ وجلّ នេះគឺការគោរពរបស់បណ្ដាអ្នកមាន

សេរីភាពក្នុងចិត្ត ជាការគោរពប្រសើរបំផុត ។"

ទោះបីយើងមានទ្រព្យសម្បើមប៉ុណ្ណាក៏ដោយ ក៏យើងមិនអាចទិញសុភមង្គល ឬសេចក្ដីស្រឡាញ់បានទេ ។

យើងត្រូវដឹងថា វត្ថុដែលមានតម្លៃបំផុតគឺសេចក្ដីស្កប់ស្កល់ ។ មានតែផ្លូវមួយគត់ដែលអាចនាំយើងទៅដល់អាការនេះបាន គឺធ្វើតាមព្រះរាជបញ្ជារបស់អល់ឡោះហ៊្វ៏ﷻដោយនៅក្បែរព្រះអង្គﷻ ។

**មេរៀនទី ១៤**

# ទុស្ហម៉ាស់ (ចោទគេ)

تُهْمَة

ទុស្ហម៉ាស់ (تُهْمَة)[3] គឺបទចោទប្រកាន់គេថាបានធ្វើប្រការនីមួយដោយគ្មានភ័ស្តុតាងច្បាស់លាស់ ។ នេះជាការនិយាយបង្ខូចគេដ៏អាក្រក់មួយប្រភេទ ។

មានពាក្យពីរសម្រាប់ហៅការនិយាយអាក្រក់អំពីគេ មួយគឺ គ៊ីបាស់ (غِيبَة) មួយទៀតគឺ ទុស្ហម៉ាស់ (تُهْمَة) ។

ពេលអ្នកនិយាយអំពីបុគ្គលណាម្នាក់ ដោយនិយាយការពិត គេហៅថា គ៊ីបាស់ ។

ពេលអ្នកនិយាយអំពីបុគ្គលណាម្នាក់ ដោយនិយាយការមិនពិត គេហៅថា ទុស្ហម៉ាស់ ។

## គ៊ីបាស់ និង ទុស្ហម៉ាស់ ជាប្រការហារ៉ាំពីរ (ត្រូវហាម) ។

ព្រះសាស្តាមូហ៊ាំម៉ាដ់ﷺមានព្រះវចនៈថា៖ "អាប៊ូ ស្ទារ អឺយ ចូរចៀសឆ្ងាយពីការនិយាយអាក្រក់អំពីគេ ព្រោះវាអាក្រក់លើសកំហុសផ្លូវភេទ ។ បន្ទាប់ពីបានប្រព្រឹត្តខុសផ្លូវភេទបើលោកស្តាយក្រោយលែងធ្វើទៀត អល់ឡោះហ៊្ជ លើកលែងទោសឲ្យលោក តែអ្នកនិយាយបង្ខូចគេមិនត្រូវលើកលែងទោសឲ្យទេដរាបណាបុគ្គលដែលត្រូវគាត់និយាយបង្ខូចនោះមិនលើកលែងទោសឲ្យគាត់ទេនោះ ។"

ឧទាហរណ៍អ្នកឃើញអ្នកណាម្នាក់ដែលអ្នកស្គាល់ ចូលទៅក្នុងហាងលក់ស្រា ។ បើអ្នកថាគាត់ផឹកស្រា អ្នកប្រព្រឹត្តកំហុស ទុស្ហម៉ាស់ ។ អ្នកអាចដឹងបានដូចម្តេចថាគាត់ផឹកស្រា ? រថយន្តគាត់អាចខូច គាត់ចូលទៅក្នុងហាងលក់ស្រាដើម្បីប្រើទូរស័ព្ទ ឬគាត់ចូលទៅសួរផ្លូវគេ ។

[3] មើលសៀវភៅសិក្សា សីលធម៌ថ្នាក់ទី ៦ មេរៀនទី ១៩ ។

ក្នុងសាសនាអ៊ីស្លាម គេត្រូវខិតខំយល់មូលហេតុដែលអ្នកដទៃប្រព្រឹត្តទង្វើនីមួយ ។ ទោះបីអ្នកណាមួយធ្វើប្រការអាក្រក់មែនក៏ដោយ អ្នកត្រូវបិទបាំងកុំឲ្យគេដឹង កុំផ្សាយប្រាប់គេ ។ តើអ្នកចូលចិត្តទេបើអល់ឡោះហ៍ ﷻ ប្រាប់ឲ្យពិភពលោកដឹងពួប្រការអាក្រក់ដែលអ្នកឬខ្ញុំបានប្រព្រឹត្តនោះ ? យើងរាល់គ្នាប្រព្រឹត្តបាបប្រការនីមួយពេលនីមួយ ។ បើអល់ឡោះហ៍ ﷻ អាចបិទបាំងកំហុសយើងបាន យើងក៏ត្រូវបិទបាំងកំហុសអ្នកដទៃដែរ ។

នៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ អាល់-ហ៊្វូយូរ៉ត អាយ៉ាស្ល៍ 12 (49:12) អល់ឡោះហ៍ ﷻ មានព្រះបន្ទូលថា៖

... وَلَا تَجَسَّسُواْ وَلَا يَغْتَب بَّعْضُكُم بَعْضًاۚ أَيُحِبُّ أَحَدُكُمْ أَن يَأْكُلَ لَحْمَ أَخِيهِ مَيْتًا ... ﴿١٢﴾

*12. ...ចូរពួកអ្នកកុំលបយកការណ៍ ។ ចូរពួកអ្នកកុំនិយាយបង្កាច់អ្នកឯទៀត ។ តើមានអ្នកណាម្នាក់ក្នុងចំណោមពួកអ្នក ចូលចិត្តស៊ីសាច់បងប្អូនឯងដែលស្លាប់នោះទេ ?...*

សឲ្យឃើញថា និយាយបង្កាច់គេអាក្រក់ដូចស៊ីសាច់បងប្អូនខ្លួនឯងដែលបានស្លាប់ទៅហើយដែរ ។ ពេលអ្នកណាម្នាក់ដែលអ្នកស្គាល់ ពោលគឺ បងប្អូនរួមសាសនាអ៊ីស្លាមប្រុស/ស្រីរបស់អ្នកបានធ្វើប្រការអាក្រក់ណាមួយ គាត់ប្រុស/ស្រីនោះបានធ្វើឲ្យខូចកេរ្តិ៍ឈ្មោះខ្លួនឯងរួចស្រាប់ហើយ ។ ពេលអ្នកនិយាយប្រាប់គេឯទៀតឲ្យដឹងទង្វើដែលគាត់បានធ្វើនោះ អ្នកសប្បាយនិងទាញយកផលប្រយោជន៍ពីការខូចខាតរបស់គាត់ ។ ហាក់ដូចជាអ្នកស៊ីផឹកយ៉ាងសប្បាយលើកេរ្តិ៍ឈ្មោះដែលគេប្រុស/ស្រីនោះបានធ្វើឲ្យខូចហើយនោះ ។

សម័យព្រះសន្តអ៊ីម៉ាំមុនៗរបស់យើង عليهم السلام មានបុរសពីរនាក់ឈ្មោះហ្វារូននិងខ៏លីដ្វ ។

ថ្ងៃមួយ ខ៏លីដ្វបាននិយាយអាក្រក់អំពីហ្វារូនប្រាប់គេអស់ ។ គាត់និយាយមុសាជុំវិញខ្លួនគាត់ ។ ច្រើនថ្ងៃក្រោយមក ហ្វារូនដឹងរឿងនេះ ។ ពេលគាត់ទៅដល់ផ្ទះ គាត់បានយកប្រាក់និងមាសគាត់ទាំងអស់ដាក់ក្នុងថង់ធំមួយហើយយកទៅផ្ទះខ៏លីដ្វ ។

ពេលឃើញហ្វារូនមកដល់ ខ៊៍លីដ្វភ័យរន្ធត់ព្រោះគាត់គិតថាហ្វារូនប្រុងមកវាយគាត់ ។ ខ៊៍លីដ្វចេញពីក្នុងផ្ទះ លុតជង្គង់អង្វរហ្វារូនថា៖ "ហ្វារូនអឺយ ខ្ញុំសោកស្តាយណាស់ ខ្ញុំមិនមានចេតនានិយាយមុសាអំពីលោកទេ ។ ខ្ញុំសូមអង្វរ កុំវាយខ្ញុំអី !"

ហ្វារូនបានថា៖ "ខ្ញុំមិនមកវាយលោកទេ ។ ខ្ញុំមកនេះដើម្បីយកប្រាក់នេះមកឲ្យលោក ។" ខ៊៍លីដ្វតក់ស្លុតស្ទើរស្លាប់ ។

ហ្វារូននិយាយបន្តទៀតថា៖ "ខ៊៍លីដ្វអឺយ ខ្ញុំមកដើម្បីអរគុណលោក សូមលោកទទួលយកទ្រព្យទាំងអស់របស់ខ្ញុំទៅ ។"

ខ៊៍លីដ្វងើបឡើង សួរថា៖ "ហេតុអ្វីលោកឲ្យទ្រព្យទាំងអស់របស់លោកមកខ្ញុំ ខ្ញុំបានប្រមាថលោក បានបង្ខូចឈ្មោះលោកប្រាប់គេទាំងអស់គ្នា ?"

ហ្វារូនតបថា៖ "ព្រះសាស្តាﷺមានព្រះវចនៈថាអ្នកណានិយាយអាក្រក់ពីគេពីក្រោយខ្នង រង្វាន់របស់អ្នកនិយាយបង្កាច់គេនោះត្រូវផ្ទេរឲ្យទៅអ្នកដែលត្រូវគេនិយាយបង្ខូច ។" ហ្វារូននិយាយបន្តទៀតថា៖ "ដូច្នេះ ពេលនេះ ដែលលោកបាននិយាយអាក្រក់អំពីខ្ញុំពីក្រោយខ្នងខ្ញុំ ខ្ញុំសូមអរគុណលោកដែលបានឲ្យរង្វាន់ទាំងអស់របស់លោកមកខ្ញុំ ។ ទ្រព្យទាំងនេះតិចណាស់ប្រៀបធៀបនឹងរង្វាន់ទាំងអស់ដែលលោកបានឲ្យមកខ្ញុំនោះ ។"

សឲ្យឃើញ "គ៊ីបាស់" និង "ទុស្សម៉ាស់" ជាប្រការអាក្រក់ ។

ថ្ងៃមួយ បុរសម្នាក់និយាយទុស្សម៉ាស់ដាក់អ៊ីម៉ាំទី ៦ របស់យើងصلوات الله عليه والسلام ។ អ៊ីម៉ាំصلوات الله عليه والسلامមិនដឹងខ្លួនទេ ច្រើនថ្ងៃក្រោយមក "មិត្ត" ព្រះអង្គصلوات الله عليه والسلامម្នាក់បានមករកព្រះអង្គصلوات الله عليه والسلام ទូលព្រះអង្គصلوات الله عليه والسلامថា៖ "អ៊ីម៉ាំصلوات الله عليه والسلامអឺយ ទូលបង្គំបានទទួលដំណឹងគួរឲ្យខ្លាច ។ បុគ្គលនេះបាននិយាយអាក្រក់អំពីព្រះអង្គصلوات الله عليه والسلام ។" អ៊ីម៉ាំصلوات الله عليه والسلامក្រោធ "មិត្ត" ព្រះអង្គصلوات الله عليه والسلام ។ ព្រះអង្គصلوات الله عليه والسلامមានវចនៈថា៖ "ចូរគិតដល់អ្នកដែលនិយាយបង្កាច់ខ្ញុំصلوات الله عليه والسلام ដូចជាអ្នកនោះបាញ់ព្រួញមកលើខ្លួនខ្ញុំصلوات الله عليه والسلام ។ ព្រោះតែខ្ញុំصلوات الله عليه والسلامមិនបានឮ វាដូចជាគ្រាប់ព្រួញនោះបាញ់ខុសខ្ញុំصلوات الله عليه والسلام ។ តែពេលលោកនាំដំណឹងនេះមកប្រាប់ខ្ញុំصلوات الله عليه والسلام វាដូចលោករើសយកគ្រាប់ព្រួញនោះពីដីមកចាក់លើខ្លួនខ្ញុំصلوات الله عليه والسلام ។"

មុស្លីមល្អមានករណីយកិច្ចហាមគេមិនឲ្យនិយាយអាក្រក់អំពីអ្នកណាម្នាក់ បើមិនអាចធ្វើបានទេ ត្រូវចៀសចេញពីបណ្ដាអ្នកដែលនិយាយអាក្រក់អំពីគេ ។

## ហេតុអ្វី "គ៊ីបាស្ន៎" និង "ទុស្ស៊ម៉ាស្ស៎" ជាប្រការហ៊ារ៉ាំ ?

វាជាប្រការហ៊ារ៉ាំព្រោះវាបង្ខូចឈ្មោះនិងកិត្តិយសរបស់មនុស្ស ។ បើអ្នកនិយាយអាក្រក់អំពីអ្នកណាម្នាក់ អ្នកធ្វើឲ្យអ្នកដទៃគិតថាអ្នកនោះអាក្រក់ ។

មូលហេតុមួយទៀតដែលថាវាជាប្រការអាក្រក់នោះគឺ បណ្ដាអ្នកដែលត្រូវគេនិយាយបង្ខូចនោះមិនបាននៅកន្លែងនោះទេ ដើម្បីនឹងអាចនិយាយការពារខ្លួនបាន ។ បើអ្នកបានឮគេនិយាយអាក្រក់អំពីអ្នកដទៃ អ្នកត្រូវបើកផ្លូវឲ្យគេដើម្បីនឹងឲ្យគេអាចអធិប្បាយបំភ្លឺអំពីទង្វើរបស់ខ្លួនបាន មុននឹងជឿអ្វីដែលអ្នកបានឮនោះ ។

គ៊ីបាស្ន៎ និង ទុស្ស៊ម៉ាស្ស៎ កើតចេញមកពីការច្រណែនឈ្នានីស ។ ពេលមនុស្សម្នាក់មានគេគោរពច្រើន បានធ្វើប្រការល្អ បានជួយអ្នកដទៃ វានឹងធ្វើឲ្យបុគ្គលមួយចំនួនក្រោធជានិច្ច មិនអាចទ្រាំមើលគេគោរពមនុស្សនោះបានទេ ។ លទ្ធផលគឺបុគ្គលនោះព្យាយាមនិយាយអាក្រក់អំពីមនុស្សនោះ និងខិតខំបង្ខូចកេរ្តិ៍ឈ្មោះរបស់មនុស្សនោះ ដោយសាបព្រោះពិសពុលទៅលើចរិយាមារយាទរបស់មនុស្សនោះ ដោយនិយាយមុសាអំពីមនុស្សនោះ ដើម្បីនឹងធ្វើឲ្យសេចក្ដីគោរពប្រែទៅជាសេចក្ដីប្រមាថនិងសេចក្ដីខ្មាស ។ បុគ្គលប្រភេទនេះត្រូវអល់ឡោះហ្ ﷻ ដាក់បណ្ដាសានិងត្រូវហៅថាពួកលបខ្សឹបខ្សៀវអាក្រក់ក្នុងចំណោមពួកមនុស្ស (មើលស៊ូរ៉ោះត៍ អាន់-ណាស់) ។

## មេរៀនទី ១៥

# តាកាប់ប៊ូរ (ឫកឡឺត)

تَكَبُّر

តាកាប់ប៊ូរគឺឫកឡឺត (តម្លើងឫកឬលេងឫកហួសភាពខ្លួន) គិតថាខ្លួនខ្ពស់ឬធំជាងអ្នកដទៃ ។ នេះគឺចរិយាមារយាទដែលប្រកបដោយគ្រោះថ្នាក់ណាស់ វានាំទៅរកសេចក្ដីវិនាសតែម្យ៉ាង ។

បើអ្នកប៉ិនប្រសប់វិស័យនីមួយ ឬបើអ្នកបានទទួលលទ្ធផលល្អក្នុងប្រការនីមួយ ចូរអ្នកកុំវាយតម្លៃខ្លួនឯងខ្ពស់ពេក ។

ពេលអ្នកបានធ្វើប្រការល្អនីមួយ ណាហ្វ់ស៍របស់អ្នកចាប់ផ្ដើមប្រាប់អ្នកថាអ្នកឆ្នើម អ្នកប្រសើរលើសអ្នកផងទាំងពួង ។ វាធ្វើឲ្យអ្នកគិតថាពុំមានគេស្មើអ្នកទេ ថាអ្នកបានដល់កម្រិតកំពូល ។

ពេលរឿងនេះកើតឡើង អ្នកនឹងគិតថាខ្លួនអ្នកឆ្នើមបំផុត អ្នកនឹងខិតខំខ្លាំងឡើងដើម្បីនឹងទៅជាអ្នកប្រសើរផុតលេខ ។

តាកាប់ប៊ូរនឹងជ្រៀតចូលទៅក្នុងចិត្តយើងដោយស្ងៀមស្ងាត់ ។ វាព្យាយាមលាក់បាំងខ្លួនពីយើងនិងចាប់យកគំនិតយ៉ាងរហ័ស ដូច្នេះហើយបានជាព្រះសាស្ដាមូហាំម៉ាដ់ﷺបានប្រាប់យើងថា៖ "ឫកឡឺតចូលទៅក្នុងចិត្តដូចស្រមោចខ្មៅវារលើដុំថ្មខ្មៅពេលយប់[4] ។"

ប្រការដំបូងបង្អស់ដែលត្រូវធ្វើ ពេលអ្នកបានសម្រេចថ្វីដៃនីមួយ គឺអរព្រះគុណអល់ឡោះហ្ជ័ﷻ ។ ដោយថាតែ "អាល់-ហ្បាំឌូលិលឡាស្ញ៉" អ្នកនឹងឃាត់ណាហ្វ់ស៍អ្នកមិនឲ្យវាសរសើរលើកជើងអ្នកទេ ។ ចូរចងចាំថាដែលអ្នកបានជោគជ័យនោះព្រោះតែអល់ឡោះហ្ជ័ﷻជួយអ្នក ដូច្នេះចូរអ្នកអរព្រះគុណអល់ឡោះហ្ជ័ﷻ ចូរកុំភ្លេចខ្លួននិងកុំគិតថាអ្នកបានធ្វើអ្វីៗទាំងអស់ដោយខ្លួនឯង ។ ដោយអរព្រះគុណអល់ឡោះហ្ជ័ﷻ យើងយកព្រះអង្គﷻមកចូលរួមក្នុងគ្រប់វិស័យនៃជីវិតយើង

[4] មើលសៀវភៅសិក្សា សីលធម៌ ថ្នាក់ទី ៧ មេរៀនទី ៨ ។

ដោយរំលែកសេចក្តីត្រេកអរនិងសុភមង្គលរបស់យើងជាមួយព្រះអង្គ عزّ وجلّ និងដោយទទួលស្គាល់ថាព្រោះតែព្រះអង្គ عزّ وجلّ ប្រោសប្រណីបានជាយើងជោគជ័យ ។

នៅក្នុងឌូអាុអ៍ពេលស្វ៊ឡាត់អាុស្វារ យើងទូលអល់ឡោះហ្វ៍ عزّ وجلّ ថា៖ "اَللَّهُمَّ مَا بِنَا مِنْ نِعْمَةٍ فَمِنْكَ - អល់ឡ៉ហ៊ុមម៉ា ម៉ា ប៊ីណា នៀក្មម៉ាទិន ហ្វា មិនកា (ព្រះម្ចាស់ عزّ وجلّ អើយ កោសល្យទាំងអំបាលម៉ានដែលទូលព្រះបង្គំជាខ្ញុំមាននោះ វាសុទ្ធតែមកពីព្រះអង្គ عزّ وجلّ មួយគត់)" ។

កាលអល់ឡោះហ្វ៍ عزّ وجلّ បង្កើតអាដាំ عَلَيْهِ السَّلَامُ ព្រះអង្គ عزّ وجلّ ឲ្យសត្វលោកទាំងអស់ឯទៀតក្រាបប្រណិប័តន៍អាដាំ عَلَيْهِ السَّلَامُ ។ អ៊ីប្លីស لعنه الله បានបដិសេធដោយថា៖ "ទូលព្រះបង្គំជាខ្ញុំ لعنه الله ប្រសើរជាងគេ عَلَيْهِ السَّلَامُ ។" នេះគឺតាកាប់ប៊ូរដំបូងបង្អស់ ឬកឡឹតដំបូងបង្អស់ ដោយសារទង្វើនេះឯងដែលអ៊ីប្លីស لعنه الله ត្រូវហៅថាស្ហៃតន្លនោះ មានន័យថា បុគ្គលដែលត្រូវដកចេញពីសេចក្តីស្រឡាញ់របស់អល់ឡោះហ្វ៍ عزّ وجلّ ។

យើងទាំងអស់គ្នាសុទ្ធតែបានធ្វើប្រការល្អនីមួយក្នុងជីវិតយើង ។ មិនបានសេចក្តីថាយើងមិនត្រូវត្រេកអរនោះទេ ។ យើងត្រូវត្រេកអរ យើងត្រូវរីករាយ យើងត្រូវសើចនិងគាប់ចិត្តទង្វើនេះ តែយើងត្រូវចាំទុកក្នុងចិត្តថាអល់ឡោះហ្វ៍ عزّ وجلّ បានជួយយើង ដូច្នេះយើងត្រូវអរព្រះគុណព្រះអង្គ عزّ وجلّ ។ អ្វីដែលអ៊ីស្លាមមិនអនុលោម គឺយើងគិតថា "ខ្លួនអញអស្ចារ្យណាស់ ។ មិនមានគេដូចអញទេក្នុងលោកនេះ ។ អញប៉ិនប្រសប់មែន !" ពេលគិតបែបនេះ អល់ឡោះហ្វ៍ عزّ وجلّ នឹងដកយើងចេញពីសេចក្តីស្រឡាញ់របស់ព្រះអង្គ عزّ وجلّ ដែរ ដូច្នេះយើងនឹងធ្លាក់ដូចស្ហៃតន្ល لعنه الله ។

អល់ឡោះហ្វ៍ عزّ وجلّ បង្កើតយើងមកស្មើភាពគ្នា ។ គេអាចថាខ្លួនប្រសើរជាងអ្នកដទៃបានដូចម្តេចទៅ ?

## អភិមាន

អភិមានគឺការគិតខុសថាខ្លួនធំុថ្កើង គិតខុសអំពីអាការក្រៅរបស់ខ្លួនឬអំពីខ្លួន

ឯង ។

មនុស្សអភិមានប្រើពេលច្រើនណាស់ សម្រាប់រៀបចំខ្លួនឲ្យមានអាការក្រៅស្អាតស្អំ មិនឲ្យសក់មួយសរសៃខុសកន្លែងទេ សំលៀកបំពាក់សុទ្ធតែស្អាតនិងថ្មី ។ ទង្វើទាំងនេះសម្រាប់ធ្វើឲ្យអ្នកផងគិតថា "អ្នកនេះពិតជាអ្នកធុរកិច្ច" ។

អភិមានប្រកបដោយគ្រោះថ្នាក់ ព្រោះវានាំទៅរកសេចក្ដីឡើត វាឃាត់អ្នកមិនឲ្យទៅជាមនុស្សប្រសើរទេ ។ បើអ្នកចំណាយពេលច្រើនសម្រាប់អាការក្រៅរបស់អ្នកដោយគ្មានហេតុផល វាទៅជាទង្វើខ្វះសីលធម៌ វានឹងធ្វើឲ្យអ្នកលើកតម្កើងខ្លួនឯង ។ អ្នកនឹងយកចិត្តទុកដាក់ខ្លាំងណាស់អំពីសំលៀកបំពាក់អ្នកនិងរូបរាងអ្នក (ប៉ែកក្រៅ) បណ្ដាលឲ្យអ្នកភ្លេចគិតអភិវឌ្ឍចរិយាមារយាទ (ប៉ែកក្នុង) អ្នកភ្លេចអល់ឡោះហ៍ﷻ ព្រះដែលប្រទានគុណសម្បត្តិឲ្យអ្នក ។

ព្រះសាស្ដាមូហាំម៉ាដ់ﷺមានព្រះវចនៈថា៖ "នឹងមានថ្ងៃមួយមនុស្សនឹងកខ្វក់ខាងក្នុងតែស្អាតខាងក្រៅ ។ ពួកគេនឹងស្រេកឃ្លានទ្រព្យលោកិយ មិនចង់បានអ្វីដែលនៅឯអល់ឡោះហ៍ﷻទេ ។ ពួកគេប្រតិបត្តិសាសនាសម្រាប់តែបង្ហាញគេទេ ។ ពួកគេនឹងធ្វើសក្ការៈអល់ឡោះហ៍ﷻដូចបុគ្គលដែលកំពុងលង់ទឹក អល់ឡោះហ៍ﷻនឹងមិនស្ដាប់ការធ្វើសក្ការៈរបស់ពួកគេទេ ។"

មិនខុសទេដែលមានអាការក្រៅស្អាតស្អំ ដែលស្លៀកពាក់ស្អាតនោះ តែត្រូវមានព្រំដែនក្នុងការយកចិត្តទុកដាក់អំពីរឿងនេះ ។ បើអ្នកប្រើទឹកសម្រាប់លាបសក់ ប្រើក្រែមឬម្សៅសម្រាប់ឱកាសសាមញ្ញ ដូចជាទៅសាលារៀនឬជួបមិត្តភ័ក្ដិជាដើម ហើយបើអ្នកប្រើពេលច្រើន អ្នកគប្បីខិតខំចៀសវាង ។ តែបើអ្នកមានណាត់ជួបគេ ឬមានកិច្ចសម្ភាសន៍ ឬឱកាសនីមួយដែលតម្រូវឲ្យអ្នកមានអាការក្រៅស្អាតស្អំជាពិសេស គេអនុញ្ញាតឲ្យអ្នកចំណាយពេលច្រើនជាងសព្វមួយដងដើម្បីស្លៀកពាក់ ។

ប្រការសំខាន់បំផុតដែលត្រូវចងចាំនោះ គឺអ្នកមិនត្រូវស្លៀកពាក់ដើម្បីឲ្យគេស្ញើចទេ មិនត្រូវស្លៀកពាក់ដើម្បីអួតគេឬឲ្យគេឃើញអ្នកជាមនុស្សផ្សេងទេ ។ ធ្វើ

បែបនេះនឹងបានត្រឹមតែធ្វើឲ្យអ្នកគិតថាខ្លួនអ្នកថ្កុំថ្កើងទេ អ្នកនឹងបោកប្រាស់ខ្លួនឯងនិងអ្នកដទៃ ។ ចូរអ្នករីករាយចំពោះខ្លួនឯង គេរាល់គ្នានឹងរីករាយជាមួយអ្នកដែរ ។

**មេរៀនទី ១៦**

# ការបោកបញ្ឆោត និង កលល្បិច

មូលដ្ឋានសំខាន់បំផុតមួយក្នុងការរស់នៅគឺសហប្រតិបត្តិការ និងចូលរួមជាមួយគេដើម្បីនឹងឲ្យក្រុមទាំងពីរបានទទួលផលប្រយោជន៍ទៅវិញទៅមក និងសមបំណង ។

យើងទាំងអស់គ្នាមានគោលដៅតែមួយ គឺទទួលបាននូវសេចក្ដីស្រឡាញ់ពីអល់ឡោះហ្ ﷻ អ៊ីនស្សាអល់ឡោះហ្ និងបានចូលឋានសួគ៌អនន្តរបស់ព្រះអង្គ ﷻ ។ អាស្រ័យហេតុនេះ យើងទាំងអស់គ្នាជាដៃគូគ្នា រួមដៃគ្នាប្រតិបត្តិការដើម្បីទៅដល់គោលដៅតែមួយ ។



បោកបញ្ឆោតនិងមានកលល្បិច មានន័យថា អ្នកមានស្ថានភាពប្រសើរដោយបំភ័ន្តគេឬដោយកុហកគេ ព្រមទាំងធ្វើឲ្យគេជឿថាអ្នកជួយជ្រោមជ្រែងគេ ។ ហេតុដូច្នេះឯងបានជាទង្វើនេះជាទង្វើអាក្រក់បំផុត ដែលមិនត្រូវអត់ឱនដោយអ្នកដទៃឡើយ លើកលែងតែដោយបុគ្គលរងគ្រោះផ្ទាល់តែម្យ៉ាង ។

អ៊ីស្លាមមិនអនុញ្ញាតដាច់ខាត ឲ្យទាញយកផលប្រយោជន៍ដោយធ្វើឲ្យអ្នកដទៃខូចខាតនោះ ។

ដើម្បីបោកប្រាស់ អ្នកត្រូវធ្វើឲ្យគេជឿថារបស់មិនពិតជារបស់ពិត ។

ឧទាហរណ៍ បើខ្ញុំធ្វើឲ្យអ្នកជឿថាតែមមួយនេះជាតែមកម្រណាស់ តម្លៃវា ៥០០០€ លក់ឲ្យអ្នកតែ ២៥០០€ ទេ ។ បើអ្នកទិញតែមនេះ ហើយដឹងថាវាថ្លៃតែ ៥€ ទេនោះ អ្នកត្រូវខ្ញុំបោក ។

មនុស្សភាគច្រើនធ្វើបែបនេះក្នុងជីវិតពិត ដោយសំអាងថាក្នុងជំនួញរកស៊ី គេអាចធ្វើអ្វីៗបានទាំងអស់ ។

ជំនួញប្រភេទនេះនឹងនាំទៅរកសេចក្ដីវិនាស ។ អ្នកនឹងខូចឈ្មោះ អ្នកនឹង

ក្លាយទៅជាមនុស្សកំណាច គេនឹងលែងជឿអ្នក ។

លុះគេឈប់ទុកចិត្តអ្នក អ្នកនឹងមិនមានសេចក្ដីសុខឡើយទាំងក្នុងលោកនេះ ទាំងក្នុងថ្ងៃជំនុំជម្រះពេលអ្នកងើបឡើង ។

យើងមិនត្រឹមតែត្រូវមានយុត្តិធម៌និងទៀងត្រង់ទេ តែយើងត្រូវប្រយ័តខ្លួនដែរ អំពីមនុស្សដែលប៉ងបោកប្រាស់យើងនោះ ។

មានមនុស្សខ្លះថាខ្លួនប្រតិបត្តិតាមសាសនាអ៊ីស្លាម តែបំបែរយើងចេញពីមាគ៌ាត្រូវ ។ ពេលប្រការល្អនីមួយកើតមានដល់យើង ពួកគេថាខ្លួនត្រេកអរឲ្យយើង តែការពិតពួកគេច្រណែនឈ្នានីស ។ មនុស្សប្រភេទនេះព្យាយាមបញ្ឆោតអ្នកទេ ដោយធ្វើឲ្យអ្នកជឿថាខ្លួនជាមនុស្សល្អ ។ អល់ឡោះហ្ ﷻពន្យល់ប្រាប់យើងនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ អាលី-អ៊ីមរ៉ន អាយ៉ាស្ 120 (3:120) ថា៖

إِن تَمْسَسْكُمْ حَسَنَةٌ تَسُؤْهُمْ وَإِن تُصِبْكُمْ سَيِّئَةٌ يَفْرَحُوا۟ بِهَا ۖ وَإِن تَصْبِرُوا۟ وَتَتَّقُوا۟ لَا يَضُرُّكُمْ كَيْدُهُمْ شَيْـًٔا ۗ إِنَّ ٱللَّهَ بِمَا يَعْمَلُونَ مُحِيطٌ ﴿١٢٠﴾

*120. បើសេចក្ដីល្អកើតមានដល់ពួកអ្នក វាធ្វើឲ្យពួកគេឈឺចាប់ ។ បើអកុសលកើតមានដល់ពួកអ្នក វាធ្វើឲ្យពួកគេសប្បាយចិត្ត ។ បើពួកអ្នកអត់ធ្មត់[លើមាគ៌ាអល់ឡោះហ្] ខ្លាចក្រែង[អល់ឡោះហ្] ឧបាយកលរបស់ពួកគេពុំអាចធ្វើឲ្យពួកអ្នកអន្តរាយបានឡើយ ។ អល់ឡោះហ្ក្តាប់អំពើរបស់ពួកគេ ។*

ស្ហៃតន ﷺព្យាយាមបោកប្រាស់យើងជានិច្ច ។ វា ﷺធ្វើឲ្យយើងគិតតែអំពីលោកនេះច្រើនពេក បណ្ដាលឲ្យយើងភ្លេចខ្លួនថាយើងត្រឹមតែស្នាក់នៅឯលោកនេះជាបណ្ដោះអាសន្នទេ ។ តែអល់ឡោះហ្ ﷻពន្យល់ប្រាប់យើងក្នុងអាយ៉ាស្មុននិងក្នុងអាយ៉ាស្ខាងក្រោមនេះ (ស៊ូរ៉ោះត៍ អាន់-នីសាអ៍ អាយ៉ាស្ 76 (4:76)) ថាបើយើងជឿជាក់ពិតប្រាកដ ពុំមានអ្នកណាមួយអាចបោកបញ្ឆោតយើងបានឡើយ គឺ៖

ٱلَّذِينَ ءَامَنُوا۟ يُقَـٰتِلُونَ فِى سَبِيلِ ٱللَّهِ ۖ وَٱلَّذِينَ كَفَرُوا۟ يُقَـٰتِلُونَ فِى سَبِيلِ ٱلطَّـٰغُوتِ فَقَـٰتِلُوٓا۟ أَوْلِيَآءَ ٱلشَّيْطَـٰنِ ۖ إِنَّ كَيْدَ ٱلشَّيْطَـٰنِ كَانَ ضَعِيفًا ﴿٧٦﴾

*76. បណ្ដាអ្នកមានសទ្ធាប្រយុទ្ធ[និងប្រកបកិច្ចការ]លើមាគ៌ាអល់ឡោះហ្ (គឺដើម្បីមូលហេតុអល់ឡោះហ្) រីឯបណ្ដាអ្នកបដិសេធសទ្ធាប្រយុទ្ធ[និងប្រកបកិច្ចការ]លើ*

*មាគ៌ាត្រឹមត្រូវ (គឺដើម្បីព្រាយបិសាច រូបបដិមា មនុស្សដែលកាចសាហាវ) ។ ដូច្នេះចូរពួកអ្នកប្រយុទ្ធតទល់បណ្តាអ្នកគាំទ្រស្ហៃតន ។ ពិតណាស់ឧបាយកលរបស់ស្ហៃតន វមែងខ្សោយ [ប្រៀបធៀបនឹងសក្តានុភាពបុគ្គលដែលមានសទ្ធានិងជឿអល់ឡោះហ្ទ៍សិប់ចិត្ត] ។*

រឿងអាក្រក់បំផុតដែលគេអាចបោកបញ្ឆោតអ្នកគឺរឿងជំនឿអ្នក ។ ពេលមានគេមករកអ្នក ប្រាប់អ្នកថាអ្នកដើរលើមាគ៌ាខុស ចូរអ្នកយកសម្តីអ្នកនោះមកគិត ។ ចូរកុំតាមគេទាំងបិទភ្នែក តែចូរអ្នកសួរខ្លួនឯងនិងចូរយល់ជំនឿអ្នក ។ អល់ឡោះហ្ទ៍ ﷻ ប្រាប់យើងថានឹងមានគេធ្វើឲ្យយើងដើរខុសផ្លូវជានិច្ច ។ យើងត្រូវប្រយ័តខ្លួននិងចៀសវាងមនុស្សប្រភេទនេះ (ស៊ូរ៉ោះត៍ អាល់-អាន់អ៊ុំ អាយ៉ាស់ 112-113 (6:112-113))

وَكَذَٰلِكَ جَعَلْنَا لِكُلِّ نَبِيٍّ عَدُوًّا شَيَٰطِينَ ٱلْإِنسِ وَٱلْجِنِّ يُوحِى بَعْضُهُمْ إِلَىٰ بَعْضٍ زُخْرُفَ ٱلْقَوْلِ غُرُورًا ۚ وَلَوْ شَآءَ رَبُّكَ مَا فَعَلُوهُ ۖ فَذَرْهُمْ وَمَا يَفْتَرُونَ ﴿١١٢﴾ وَلِتَصْغَىٰٓ إِلَيْهِ أَفْـِٔدَةُ ٱلَّذِينَ لَا يُؤْمِنُونَ بِٱلْءَاخِرَةِ وَلِيَرْضَوْهُ وَلِيَقْتَرِفُوا۟ مَا هُم مُّقْتَرِفُونَ ﴿١١٣﴾

*112. យើងបានធ្វើឲ្យរាល់សាស្តាមានសត្រូវដូច្នេះឯង ពួកស្ហៃតនក្នុងចំណោមមនុស្ស (គឺមនុស្សសាហាវយង់ឃ្នង) និងពួកយ៉ិន[អាក្រក់]ដែលបញ្ចេះគ្នាទៅវិញទៅមកដោយសំដីល្អបោកបញ្ឆោត ។ បើព្រះម្ចាស់អ្នកមានព្រះបំណង (គឺមានព្រះបំណងបង្ខំពួកគេ) ពួកគេនឹងមិនធ្វើដូច្នោះទេ ។ ចូរអ្នកបណ្តោយពួកគេនិងអ្វីដែលពួកគេប្រឌិតនោះចុះ ។ 113. ដើម្បីនឹងឲ្យដួងចិត្តរបស់ពួកដែលពុំមានជំនឿចំពោះលោកមុខទេនោះទេរទៅរកវា (គឺពាក្យពេចន៍បោកបញ្ឆោតនិងមូលបង្កាច់) ដើម្បីនឹងឲ្យពួកគេស្រឡាញ់ងប់អ្វីទាំងនោះ និងដើម្បីនឹងឲ្យពួកគេប្រព្រឹត្ត[ក្នុងលោកនេះ]អ្វីដែលពួកគេប្រព្រឹត្ត ។*

អាយ៉ាស់នេះបញ្ជាក់ប្រាប់យើងថា មានតែបុគ្គលដែលមិនជឿលោកមុខនិងថ្ងៃជំនុំជម្រះទេដែលនឹងត្រូវបោកបញ្ឆោតនោះ ។ បើយើងរឹងមាំ ខ្ជាប់ខ្ជួននៅលើមាគ៌ាយើង អល់ឡោះហ្ទ៍ ﷻ នឹងដឹកនាំយើងពេលនៅក្នុងគ្រោះថ្នាក់និងឧបាយកលគេ ។

មនុស្សដែលបោកបញ្ឆោតគេអាចនឹងឈ្នះមួយពេលក្នុងលោកនេះ ។ ពួកគេ

អាចឈ្នះបានប្រាក់ បានកេរ្តិ៍ឈ្មោះ តែទីបំផុតពួកគេនឹងចាញ់ព្រោះថ្ងៃជំនុំជម្រះ អ្នកដែលត្រូវពួកគេបោកបញ្ឆោតនឹងប្រឈមពីមុខពួកគេ ពេលនោះឯងដែលពួកគេនឹងសោកស្តាយ តែវានឹងហួសពេលហើយ ។

ស៊ូរ៉ោះត៍ អាល់-អាន់អ៊ុំ អាយ៉ាស់ 123 (6:123)) ចែងថា៖

وَكَذَٰلِكَ جَعَلْنَا فِي كُلِّ قَرْيَةٍ أَكَٰبِرَ مُجْرِمِيهَا لِيَمْكُرُواْ فِيهَاۖ وَمَا يَمْكُرُونَ إِلَّا بِأَنفُسِهِمْ وَمَا يَشْعُرُونَ ﴿١٢٣﴾

*123. ដូច្នេះឯងដែលយើងធ្វើឲ្យមានអ្នកធំជាជនឧក្រិដ្ឋនៅក្នុងស្រុកនីមួយៗ ដើម្បីនឹងឲ្យពួកគេធ្វើកលឧបាយនៅក្នុងស្រុកនោះ ។ តែពួកគេបានត្រឹមតែធ្វើកលឧបាយដាក់ខ្លួនឯងប៉ុណ្ណោះ ពួកគេមិនដឹងខ្លួនទេ ។*

អ្វីដែលត្រូវចងចាំ គឺពេលអ្នកបោកប្រាស់គេ អ្នកធ្វើឲ្យខ្លួនឯងខូចខាតនៅទីបំផុត ។ អ្នកមិនត្រូវបណ្តោយឲ្យអ្នកដទៃរងទុក្ខជាដាច់ខាតដើម្បីអ្នកនឹងបានឈ្នះ ។ បើអ្នកធ្វើបែបនេះ អ្នកគិតតែផលប្រយោជន៍ខ្លួនឯង អ្នកនឹងប្រឆាំងសត្វលោករបស់អល់ឡោះហ៍ﷻ ដូច្នេះអ្នកប្រឆាំងអល់ឡោះហ៍ﷻផ្ទាល់តែម្តង ។

**មេរៀនទី ១៧**

# សេចក្ដីស្មោះត្រង់ និង ការល្មើសកិច្ចសន្យា

សេចក្ដីស្មោះត្រង់គឺមានសច្ចៈចំពោះករណីយកិច្ចខ្លួន (ការសន្យា) ។

សេចក្ដីស្មោះត្រង់ជាពាក្យដែលគេប្រើជាញឹកញយ យើងច្រើនតែមិនសូវយកចិត្តទុកដាក់ទេ ថ្វីដ្បិតវាមានសារៈសំខាន់ក្នុងអ៊ីស្លាមដោយផ្អែកលើហាឌីស្សរបស់ព្រះសាស្ដាមូហាំម៉ាដ់ﷺតទៅនេះគឺ៖ "អ្នកណាដែលគេទុកចិត្តមិនបាន អ្នកនោះពុំមានជំនឿទេ ។"

សេចក្ដីស្មោះត្រង់ជាប៉ែកមួយរបស់សីលធម៌ដែលអ៊ីស្លាមដាក់ឲ្យអនុវត្ត មានសេចក្ដីស្មោះត្រង់ធ្វើឲ្យបុគ្គលថ្កុំថ្កើង (មានសេចក្ដីថ្លៃថ្នូរ) សម្រាប់អល់ឡោះហ៍ﷻ ។

ផ្ទុយពីសេចក្ដីស្មោះត្រង់គឺសេចក្ដីក្បត់ ។ ក្បត់គឺអ្នកល្មើសពាក្យសន្យា ឬចោលគេនីមួយ ។ ព្រះសាស្ដាមូហាំម៉ាដ់ﷺមានព្រះវចនៈដែរថា៖ "ពុំមានសេចក្ដីក្បត់ដែលអាក្រក់ ជាងការថ្លែងព្រឹត្តិការណ៍កុហកប្រាប់បងប្អូនរួមសាសនារបស់លោកនោះឡើយ ។"

សឲ្យឃើញថាប្រយ័តអណ្ដាត (គឺពាក្យសម្ដី) ជាប៉ែកធំមួយរបស់សេចក្ដីស្មោះត្រង់ ។ តែសេចក្ដីស្មោះត្រង់តម្រូវឲ្យមានទង្វើដែរ ។

ពេលអ្នកសន្យា អ្នកត្រូវគោរពពាក្យសន្យានោះ ។ អ្នកដទៃពឹងផ្អែកលើអ្នក អ្នកមិនអាចចោលពួកគេបានទេ ។ បើអ្នកមិនជាក់ទេថាអាចធ្វើតាមសម្ដីបាននោះចូរកុំសន្យា ។ ចូរគ្រាន់តែថាអ្នកនឹងសាកល្បងធ្វើ ។

ជាញឹកញយមនុស្សសន្យាតែមិនគោរពពាក្យសន្យានោះទេ ឬមិនអាចរក្សាពាក្យសន្យានោះបានទេ ។ តើអ្នកដឹងទេថាមកពីមូលហេតុអ្វី ? ហេតុអ្វីគេសន្យា ? អ្នកអាចលើកឡើងនូវឧទាហរណ៍បានទេ ?

## យ៉ាគ៊ីន (يَقِين សេចក្ដីជាក់)

យើងបានអធិប្បាយអំពីជំនឿនិងអ៊ីម៉ាន់ (إيمان) រួចមកហើយ ។

យ៉ាគ្វីនគឺការមានសេចក្តីជាក់ច្បាស់ ការមានសេចក្តីប្រាកដ វាខ្ពស់ជាងអ៊ីម៉ាន់មួយកម្រិត ។

គេប្រាប់យើងថាមានព្រះមួយ ។ យើងបានឃើញព្រះនោះទេ ? ពេលយើងព្យាយាមអាន ព្យាយាមសិក្សា ពេលគេព្យាយាមពន្យល់យើង យើងបាននូវជំនឿ យើងជឿថាមានព្រះមែន ។ បន្ទាប់មក យើងប្រើការពិចារណា (តក្កសាស្ត្រ) យើងឃើញថាត្រូវតែមានព្រះ មិនមានមិនបាន ។ យើងឃើញមានសញ្ញារបស់ព្រះអង្គនៅជុំវិញខ្លួនយើង ហើយអាស្រ័យប្រាជ្ញាយើង យើងដឹងថាមានតែព្រះមួយគត់ ត្រូវតែមានព្រះអង្គ ។ នេះគឺជំនឿ ។

ពេលយើងមានជំនឿ យើងខិតខំក្រែលឡើងដើម្បីបាននូវសេចក្តីស្រឡាញ់របស់អល់ឡោះហ្វ៍ عز وجل ។ យើងនិយាយរកព្រះអង្គ عز وجل ពេលយើងធ្វើសក្ការៈព្រះអង្គ عز وجل យើងនិយាយរកព្រះអង្គ عز وجل ពេលយើងរងការលំបាក បើយើងស្មោះ បើសម្តីយើងពិតអស់ពីចិត្ត យើងនឹងបានឮចម្លើយព្រះអង្គ عز وجل ។ អល់ឡោះហ្វ៍ عز وجل នឹងនិយាយរកយើង ។ ព្រះអង្គ عز وجل នឹងមិននិយាយដាក់ត្រចៀកយើងទេ តែព្រះអង្គ عز وجل នឹងនិយាយដាក់ទៅក្នុងចិត្តយើង ។

ហេតុដូច្នេះឯងបានជាគេសួរព្រះសន្តអ៊ីម៉ាំអាលី صلوات الله عليه والسلام ថា៖ "ព្រះអង្គ صلوات الله عليه والسلام ធ្វើសក្ការៈព្រះដែលព្រះអង្គ صلوات الله عليه والسلام មើលមិនឃើញ ?" ព្រះអង្គ صلوات الله عليه والسلام តបថា៖ "ទេ ខ្ញុំ صلوات الله عليه والسلام មិនធ្វើសក្ការៈដាច់ខាតអ្វីដែលខ្ញុំ صلوات الله عليه والسلام មើលមិនឃើញ ។ ខ្ញុំ صلوات الله عليه والسلام មើលឃើញអល់ឡោះហ្វ៍ عز وجل អាស្រ័យចិត្តខ្ញុំ صلوات الله عليه والسلام មិនអាស្រ័យអារម្មណ៍ទេ ។"

សឲ្យឃើញថាពេលបានទៅដល់ដំណាក់ការយ៉ាគ្វីន (អ៊ីនស្សាអល់ឡោះហ្វ៍) យើងនឹងដឹងមែនថាអល់ឡោះហ្វ៍ عز وجل នឹងនៅត្រង់នោះ ។ យើងនឹងដឹងវត្តមានព្រះអង្គ عز وجل ដោយចិត្តគ្រប់ទីកន្លែង ពុំសង្ស័យបន្តិចឡើយ ។ ដូច្នេះ ស្សៃតន لعنه الله នឹងមិនអាចធ្វើឲ្យយើងមានមន្ទិលសង្ស័យនៅក្នុងចិត្តបានទៀតឡើយ ។

អាស្រ័យហេតុនេះឯងបានជាយ៉ាគ្វីនស្ថិតនៅក្នុងដំណាក់ការខ្ពស់ ដំណាក់ការដែលគេអាចទៅដល់បានអាស្រ័យតែសេចក្តីព្យាយាមអត់ធ្មត់ និងការយល់ដឹង ។

**មេរៀនទី ១៨**

# ខ្ជះខ្ជាយ

ខ្ជះខ្ជាយគឺការប្រើប្រាស់អ្វីៗច្រើនពេកដែលមិនចាំបាច់ ។ នេះគឺការប្រើប្រាស់ហួសកម្រិតដោយឥតប្រយោជន៍ ។

ភាសាអារ៉ាប់ហៅពាក្យនេះថា អ៊ីសរ៉ហ្វ (إِسْرَاف) ។

អល់ឡោះហ្ ﷻ ពន្យល់យើងនៅក្នុងព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ អាល់-ម៉ាអ៊ីដាស៊ អាយ៉ាស៊ 87 (5:87) ថា៖

يَٰٓأَيُّهَا ٱلَّذِينَ ءَامَنُواْ لَا تُحَرِّمُواْ طَيِّبَٰتِ مَآ أَحَلَّ ٱللَّهُ لَكُمْ وَلَا تَعْتَدُوٓاْۚ إِنَّ ٱللَّهَ لَا يُحِبُّ ٱلْمُعْتَدِينَ ﴿٨٧﴾

*87. បណ្ដាអ្នកមានសទ្ធាអើយ ចូរពួកអ្នកកុំហាម[លើខ្លួនឯង]ឡើយនូវអ្វីដែលល្អប្រសើរដែលអល់ឡោះហ្ បានអនុញ្ញាតឲ្យពួកអ្នក ។ ចូរពួកអ្នកកុំប្រព្រឹត្តបំពារបំពាន[ក្របខ័ណ្ឌ]ឡើយ ដ្បិតអល់ឡោះហ្ មិនសព្វព្រះហឫទ័យអ្នកប្រព្រឹត្តិបំពារបំពាន[ក្របខ័ណ្ឌដែលព្រះអង្គបានចែងហើយនោះ]ទេ ។*

កម្ចាត់ការខ្ជះខ្ជាយជាប្រការសំខាន់ណាស់ក្នុងសាសនាអ៊ីស្លាម ។ កូនក្មេងប្រហែលជានឹកឃើញកាលខ្លួនបរិភោគអាហារមិនអស់ពីចាន គេប្រាប់ខ្លួនថាចូរកុំខ្ជះខ្ជាយ ។ តែ អ៊ីសរ៉ហ្វ មិនពាក់ព័ន្ធតែនឹងចំណីទេ ថ្វីបើវាជាប្រការសំខាន់មួយដែរ ។

ពេលបុគ្គលមិនមែនមុស្លីមឃើញជនមុស្លីមបរិភោគចំណីអស់រលីងពីចាន គេគិតថាជនមុស្លីមនោះល្មោភបរិភោគឬត្បិតត្បៀតពេក ។ នេះសឲ្យឃើញនូវការខ្វះការយល់ដឹងពីសំណាក់ជនមិនមែនមុស្លីម ។

អ៊ីស្លាមអប់រំយើងឲ្យចេះគោរពសព្វសារពើ ដែលអល់ឡោះហ្ ﷻ ប្រទានឲ្យយើង ។ មានអ្វីគួរឲ្យគោរពជាងជីវព្រឹត្ត (អាហារ) ដែលអល់ឡោះហ្ ﷻ ឲ្យមកយើងជាអំណោយនោះ ?

ដូច្នេះ យើងត្រូវគោរពចំណីអាហារ ដោយមិនរំលោភបំពាន ។ យើងមិនត្រូវ

លេងជាមួយចំណីអាហារទេ ទោះបីលេងសើចក៏ដោយ ។ យើងមិនត្រូវរំលោភបំពានលើចំណីអាហារដោយទង្វើណាមួយទេ យើងមិនត្រូវចោលវាជាដាច់ខាតលើកលែងតែវាខូច ។ ពេលចោលចំណីអាហារដោយគ្មានហេតុផល យើងបោះចោលអំណោយរបស់អល់ឡោះហ៍ﷻ ។ ធ្វើបែបនេះសឲ្យឃើញថាយើងអកតញ្ញូមិនដឹងគុណអល់ឡោះហ៍ﷻទេ ។

បើអ្នកឲ្យអំណោយមួយមកខ្ញុំ ដោយបោះវាពីមុខ អ្នកសម្តែងឲ្យឃើញថាអ្នកពុំមានសេចក្តីគោរពចំពោះរូបខ្ញុំនិងអំណោយខ្ញុំទេ ។ សម្រាប់ចំណីអាហារក៏ដូចគ្នាដែរ ។

ពេលឃ្លាន គេមិនហាមយើងបរិភោគទេ ។ តែយើងត្រូវដួសចំណីមកបរិភោគល្មមតែអាចបរិភោគអស់ ។ បើយើងនៅឃ្លានក្រោយពីបានបរិភោគអស់ពីចានយើងដួសមកបរិភោគទៀត ។ យើងបានឃើញច្រើនលើកហើយ មនុស្សឃ្លានដួសចំណីដាក់ចាន តែទីបំផុតបរិភោគតែពាក់កណ្តាល បោះចោលចំណីដែលនៅសល់ ។

យើងត្រូវដឹងថាមានមនុស្សច្រើនដែលពុំមានបាយហូបគ្រប់គ្រាន់ ហើយមិនដឹងនឹងបានបាយហូបមកពីណាទេពេលក្រោយ ។ តើយើងមានសិទ្ធិអ្វីថាយើងបានចំណីដោយទទេៗដើម្បីនឹងយកវាទៅចោលដូចសំរាមនោះ ។

ការខ្ជះខ្ជាយបែបនេះមានជាញឹកញយ ក្នុងការរស់នៅប្រចាំថ្ងៃរបស់យើង ។ ទិញចំណីក្រៅផ្ទះមកបរិភោគថ្វីដ្បិតអ្នកដឹងថាមានអាហារនៅឯផ្ទះ ក៏ជាទង្វើខ្ជះខ្ជាយមួយបែបដែរ ។

អ៊ីស្លាមបញ្ជាក់ប្រាប់យើងថាមិនអនុញ្ញាតឲ្យខ្ជះខ្ជាយទេ ។ អល់ឡោះហ៍ﷻប្រទានទ្រព្យសម្បត្តិឲ្យយើង ។ គេមិនហាមយើងចាយវាយទ្រព្យសម្បត្តិនោះទេ ។ គេមិនហាមយើងទិញរបស់ថ្លៃៗ រថយន្ត សំលៀកបំពាក់ ចំណីនោះទេ ។

គេមិនហាមយើងទិញរបស់ស្អាតៗ សំលៀកបំពាក់ស្អាតៗ ឬចំណីឆ្ងាញ់ៗទេ ។

ព្រះគម្ពីរគួរអាន ស៊ូរ៉ោះត៍ អាល់-អាក់រ៉ហ្វ៍ អាយ៉ាស់ 31 (7:31) ចែងថា៖

۞يَٰبَنِيٓ ءَادَمَ خُذُواْ زِينَتَكُمۡ عِندَ كُلِّ مَسۡجِدٖ وَكُلُواْ وَٱشۡرَبُواْ وَلَا تُسۡرِفُوٓاْۚ إِنَّهُۥ لَا يُحِبُّ ٱلۡمُسۡرِفِينَ ٣١

*31. ម្នាលកូនចៅអាដាំអើយ ចូរពួកអ្នកស្លៀកពាក់ល្អនាគ្រប់ទីកន្លែងធ្វើនមស្ការ*

*[ប្ជាអល់ឡោះហ្ម៍]។ ចូរពួកអ្នកបរិភោគនិងផឹក[អាហារណាដែលត្រូវអនុញ្ញាតឲ្យបរិភោគ] [តែ]ចូរកុំប្រព្រឹត្តហួសហេតុ ព្រោះអល់ឡោះហ្ម៍មិនសព្វព្រះហឫទ័យ[មនុស្សខ្ជះខ្ជាយនិង]អ្នកប្រព្រឹត្តិហួសហេតុទេ ។*

ទិញរបស់ថ្លៃៗមិនមែនប្រការខុសឆ្គងទេបើយើងប្រើប្រាស់វា ។ តែខ្ជះខ្ជាយប្រាក់ដើម្បីទិញរបស់ឥតប្រយោជន៍នោះ ច្បាប់មិនអនុញ្ញាតទេ ។

ហេតុអ្វីមានមនុស្សខ្លះចាយវាយខ្ជះខ្ជាយដោយចេតនា ? ពួកគេនោះមានមូលហេតុអ្វី ?

មូលហេតុខ្ជះខ្ជាយនោះគឺ៖

- ចង់បង្ហាញអ្នកផងទាំងឡាយ ។
- ចង់ទិញរបស់នីមួយព្រោះតែអ្នកជិតខាងអ្នកមានរបស់នោះ ។
- មិនឲ្យតម្លៃទៅលើទ្រព្យសម្បត្តិ ទិញដើម្បីទិញតែម្យ៉ាង ។

មូលហេតុទាំងនេះអាក្រក់ណាស់ សឲ្យឃើញថាបុគ្គលពុំមានការទទួលខុសត្រូវទេអំពីទ្រព្យរបស់ខ្លួននោះ ។ ថ្ងៃជំនុំជម្រះអល់ឡោះហ្ម៍ﷻនឹងសួរអ្នកថា៖ "អ្នកឯងបានចាយវាយដូចម្ដេចខ្លះ ទ្រព្យដែលបានឲ្យទៅអ្នកនោះ ?" មនុស្សដែលបានចាយវាយខ្ជះខ្ជាយនោះនឹងពុំអាចឆ្លើយដោះសាបានទេ អល់ឡោះហ្ម៍ﷻនឹងក្រោធអ្នកនោះ ។

បើយើងគិតដល់អល់ឡោះហ្ម៍ﷻ រាល់ពេលដែលយើងចាយវាយប្រាក់ដែលព្រះអង្គﷻប្រទានឲ្យយើង បើយើងសួរខ្លួនឯងថាតើព្រះអង្គﷻយល់ស្របឬទេអំពីការទិញរបស់យើងនោះ យើងប្រាកដជាមិនខ្ជះខ្ជាយឡើយ ។

**មេរៀនទី ១៩**

# រោងកុន មើលកុន

នៅក្នុងសង្គមយើង គេយល់ខុសអំពីរោងកុននិងរោងល្ខោន ។

នៅឯរោងកុន គេបញ្ចាំងកុន (ឬភាពយន្ត) ឲ្យសាធារណជនមើល ។ ប្រជារាស្ត្រនិយាយជាញឹកញយថារោងកុនហ៊ារ៉ាំ ហ៊ារ៉ាំ ហ៊ារ៉ាំ ។

មូលហេតុដែលគេនិយាយដូច្នេះ គឺកាលពីសម័យឪពុកម្ដាយអ្នក គេបញ្ចាំងកុនដែលច្រើនតែមានតន្ត្រីនិងការរាំរែក ។ ដោយសារមូលហេតុនេះ រោងកុនត្រូវគេចាត់ទុកថាហ៊ារ៉ាំ គេណែនាំបណ្ដាអ្នកដែលទៅមើលកុនឯរោងកុននោះកុំឲ្យទៅ ។

សព្វថ្ងៃនេះ យើងមានទូរទស្សន៍នៅក្នុងផ្ទះយើង យើងអាចមើលអ្វីៗបានតាមចិត្ត ។ បញ្ហាមិននៅលើការមើលឬមិនមើលនោះទេ ។ តែបញ្ហានៅលើអ្វីដែលយើងមើល ។

យើងសូមលើកយកភោជនីយដ្ឋានជាឧទាហរណ៍ ។ ទៅបរិភោគឯភោជនីយដ្ឋានជាប្រការហ៊ារ៉ាំទាល់តែចំណីដែលគេយកមកឲ្យបរិភោគនៅទីនោះ ជាចំណីហ៊ារ៉ាំ ។ តែបើភោជនីយដ្ឋានដាក់ចំណីហាឡាល់ឲ្យបរិភោគ ទៅទីនោះពុំមានបញ្ហាទេ ។ ដូច្នេះ ទៅឬមិនទៅភោជនីយដ្ឋានមិនសំខាន់ទេ តែអ្វីដែលគេបរិភោគនៅទីនោះទេដែលសំខាន់ ។

ដូចគ្នាដែរ មិនសំខាន់ទេដែលយើងទៅរោងកុនឬមិនទៅនោះ ។ សំខាន់គឺកុនដែលយើងមើលនៅទីនោះ ។

បើយើងទៅមើលកុនដែលមានឆាកមិនគប្បី ដូចជាមានមនុស្សប្រព្រឹត្តគ្មានការអៀនខ្មាស មិនស្លៀកពាក់មិនជិតខ្លួន ឬមានការវាយតប់ទទេៗ ជាដើម វាជាប្រការហ៊ារ៉ាំមែន ។

បើយើងទៅមើលកុនដែលផ្ដល់ផលប្រយោជន៍ផ្នែកអប់រំ ឬដើម្បីសប្បាយរីករាយ ដែលផ្ដល់ឲ្យយើងនូវផលប្រយោជន៍នីមួយដោយមិនឃើញអ្វីដែលហ៊ារ៉ាំ គេអនុញ្ញាតឲ្យយើងមើលកុននោះ ។

យើងក៏មិនត្រូវញៀនកុនទេដែរ ដល់ថ្នាក់ចំណាយពេលទាំងអស់នៅឯរោង

កុន បណ្ដាលឲ្យខ្ជះខ្ជាយពេលវេលា ។

គួរឲ្យស្ដាយ កុនភាគច្រើនសម័យនេះផ្ដោតទៅលើចំណង់របស់យុវជន ។ កុនទាំងនេះបង្ហាញឆាកដែលញុះញង់យុវជនឲ្យគិត និងឲ្យអនុវត្តិគំនិតដែលត្រូវនៅក្រោមអំណាចចិត្តពួកគេ ។ កុនទាំងនេះហាក់ព្រោះវាជំរុញអ្នកមើលឲ្យប្រព្រឹត្ត ។ វាធ្វើឲ្យណាប់ស័កម្រើកខ្លាំងទៅជាពិបាកគ្រប់គ្រង ទីបំផុតអារម្មណ៍អាចចាញ់ ទៅជាទាសៈរបស់តណ្ហា លែងនៅក្រោមប្រាជ្ញា ។

ចំណុចសំខាន់មួយដែលប្រជារាស្ត្រច្រើនលើកឡើងនោះគឺ នៅក្នុងកុន និងកម្មវិធីទូរទស្សន៍សម័យឥឡូវសុទ្ធតែមានតន្ត្រី ។ បើតន្ត្រីជាប៉ែកសំខាន់បំផុតរបស់កុននិងកម្មវិធីទូរទស្សន៍ ត្រូវចៀសវាងមើលកុននិងកម្មវិធីនោះ ។ តែបើតន្ត្រីនៅពីខាងក្រោយ (តន្ត្រីកំដរ) មិនមែនជាប្រធានឬជាមូលបទទេ គេអនុញ្ញាតឲ្យមើលបាន ។ ពីព្រោះយោលតាមហ្វាត់វ៉ា (នីតិសាស្ត្រ) របស់អាយ៉ាទុលឡោះហ៍ អាល់-ស៊ីសតានី របស់អាយ៉ាទុលឡោះហ៍ អាល់-យូមែនី និងរបស់អាយ៉ាទុលឡោះហ៍ អាល់-យូអ៊ី (الخوئي) តន្ត្រីដែលមាននៅពីខាងក្រោយនោះ (តន្ត្រីបន្លឺនៅពីក្រោយកុនឬកម្មវិធីដែលមិនឮខ្លាំង) ច្បាប់អនុញ្ញាតឲ្យមើលបាន ។

ការមើលទូរទស្សន៍នៅឯផ្ទះយើងក៏នៅក្រោមច្បាប់ខាងលើនេះដែរ ។

ពេលល្ងាច ពេលយើងចង់ទៅមើលកុន យើងត្រូវសួរខ្លួនឯងថាហេតុអ្វី ។ បើកុនកំប្លែងតែមានឆាកមិនសមស្របនឹងទ្រឹស្ដីសីលធម៌យើង ចូរចៀសវាង ។ នៅឯរោងកុន អ្នកនៅទល់មុខនឹងអ្វីៗដែលបញ្ចាំងនៅលើសំពត់ស អ្នកមិនអាចបិទវាបានដូចទូរទស្សន៍ឬបង្ហួសវាទៅមុខបានដូចវីឌីអូទេ ។ កម្រមានណាស់កុនដែលពុំមានឆាកដែលត្រូវចៀសវាងនោះ ។

អ្នកមិនអាចកុហកខ្លួនឯងបានទេដោយថាមិនដឹងនោះ ។ មានកុនខ្លះដែលគេឃើញច្បាស់ថាវាកំប្លែង តែពាក្យសម្ដីកំប្លែងនោះចំអេសចំអាសឬឆៅៗ ។ អ្នកមិនត្រូវមើលកុនប្រភេទនេះទេដែលអាចជះឥទ្ធិពលអាក្រក់មកលើអ្នក ។

មានកុនសមរម្យ ត្រឹមត្រូវ ដែលបង្ហាត់បង្រៀនអ្នកឲ្យចេះដឹងនូវចរិយាមារយាទមនុស្ស ដែលធ្វើឲ្យអ្នកចម្រុងចម្រើនផ្នែកមនោគតិ ឬដែលអប់រំអ្នកព្រមទាំងធ្វើឲ្យអ្នកសប្បាយរីករាយដែរ ។ គេអនុញ្ញាតឲ្យមើលកុនប្រភេទនេះព្រោះវាជះឥទ្ធិពលល្អមកលើខ្លួនអ្នក ។

អល់ឡោះហ៍ﷻល្បងពិសោធន៍អ្នកបែបនេះឯង ។ តើអ្នកអាចគ្រប់គ្រង

ណាហ្វ៍ស៍របស់អ្នកបានទេ កុំឲ្យវាទាក់ទាញអ្នកឲ្យមើលកុនចំអេសចំអាស ឬកុនចំអេសចំអាសនោះគ្រប់គ្រងអ្នក ?

ពុំមានទេ កុនដែលហាមមនុស្សអាយុក្រោម ១៨ ឆ្នាំមើល ឬកុនសម្រាប់តែមនុស្សធំនោះ ។ បើកុនចំអេសចំអាស មិនសមរម្យ ឬមានឆាកអាសគ្រាម កុននោះហារ៉ាំសម្រាប់មនុសទាំងអស់ ទោះបីអាយុ ៥ ឆ្នាំក៏ដោយ អាយុ ៥០ ឆ្នាំក៏ដោយ ។

អ្នកនឹងសម្គាល់ឃើញថាពីដំបូងពិបាកទប់ខ្លួនណាស់ តែពេលអ្នកប្តេជ្ញាចិត្តអ្នកនឹងដឹងខ្លួនថា ចរិតលក្ខណៈរបស់អ្នកដូចជាបានចម្រើនប្រសើរឡើងមួយរយដង ហើយអ្នកនឹងលែងត្រូវទាក់ទាញទៀត ។ អ្នកនឹងសួរខ្លួនឯងថាហេតុអ្វីអ្នកបានបណ្តោយឲ្យណាហ្វ៍ស៍អ្នកអាចឈ្នះអ្នកបានក្នុងរឿងមិនបានការដូចកូនក្មេង និងវត្ថុនិយមនោះ ។

**មេរៀនទី ២០**

# តន្ត្រីនិងផលវិបត្តិ

អ៊ីស្លាមមិនគាំទ្រតន្ត្រី មិនដាក់បង្គាប់ឲ្យមានតន្ត្រីក្នុងសហគមន៍ទេ ។ ដំណាក់ការនេះដូចជាតឹងខ្លាំងពេកសម្រាប់អនុវត្តិ តែយើងនឹងផ្តល់មូលហេតុនៅពេលខាងមុខ ។

ហេតុអ្វីមនុស្សស្តាប់តន្ត្រី? ព្រោះគេប្រាកដជាចូលចិត្តតន្ត្រី ដោយមានមូលហេតុអាចជាការចំណាយពេលវេលា អាចជាការបន្ធូរសម្រាលខ្លួន អាចជាការនិយមទាន់សម័យ ។

ប្រការនេះដូចជាមិនខុសទេ តែបើយើងពិនិត្យច្បាស់លាស់ យើងនឹងឃើញមូលហេតុច្បាស់ឡើង ។

ដំបូងយើងត្រូវស្វែងយល់ទ្រឹស្តីហ្ហាឡាល់និងហ្ហារ៉ាំ ។

មនុស្សពូកែបត់បែនណាស់ អាចសម្របខ្លួនបានទៅតាមស្ថានការណ៍ផ្សេងៗយ៉ាងងាយ កម្រណាស់ដែលមនុស្សទាំងអស់គ្នាមានប្រតិកម្មដូចគ្នាចំពោះឥទ្ធិពលនីមួយ ។ ដូច្នេះ ស្រាតិចតួចឬតន្ត្រីបន្តិចបន្តួចមិនធ្វើឲ្យមនុស្សទាំងអស់រងឥទ្ធពលដូចគ្នាទេ ។

តែអ៊ីស្លាមជាសាសនាសម្រាប់មនុស្សទាំងអស់គ្នា ក៏ដូចបុគ្គលម្នាក់ៗដែរ ។ ដូច្នេះ បើអ្វីមួយធ្វើឲ្យមនុស្សភាគច្រើនរងផលវិបត្តិដែលមិនគួរឲ្យចង់បាន ដូចជាស្រាធ្វើឲ្យស្រវឹងឬធ្វើឲ្យខូចសណ្តាប់ធ្នាប់ជាដើមនោះ អ៊ីស្លាមនឹងដាក់បម្រាមហ្ហារ៉ាំតាំងពីពេលដំបូងដោយឈរលើមូលដ្ឋាន **"ការពារប្រសើរជាងព្យាបាល"** ។ បានសេចក្តីថា ទប់ស្កាត់ប្រការអាក្រក់តាំងពីដើមប្រសើរជាងទប់ស្កាត់ប្រការអាក្រក់នោះពេលវាកើតឡើងហើយ ។ របៀបដោះស្រាយនេះសមហេតុផល ។

អល់ឡោះហ្វ៍ﷻមានព្រះបន្ទូលនៅក្នុងព្រះគម្ពីរគួរអានថា វត្ថុនីមួយតែបន្តិចអាចធ្វើឲ្យយើងបានផលប្រយោជន៍ តែព្រោះតែផលអាក្រក់ធ្ងន់លើសផលល្អ គេចាត់ទុកវត្ថុនោះជាវត្ថុគ្រោះថ្នាក់ ដូច្នេះវាជាវត្ថុដែលត្រូវហាម ។

﴿يَسْـَٔلُونَكَ عَنِ ٱلْخَمْرِ وَٱلْمَيْسِرِ ۖ قُلْ فِيهِمَآ إِثْمٌ كَبِيرٌ وَمَنَـٰفِعُ لِلنَّاسِ وَإِثْمُهُمَآ أَكْبَرُ مِن نَّفْعِهِمَا ۗ وَيَسْـَٔلُونَكَ مَاذَا يُنفِقُونَ قُلِ ٱلْعَفْوَ ۗ كَذَٰلِكَ يُبَيِّنُ ٱللَّهُ لَكُمُ ٱلْـَٔايَـٰتِ لَعَلَّكُمْ تَتَفَكَّرُونَ ﴿٢١٩﴾

*219. ពួកគេសួរអ្នករឿងគ្រឿងស្រវឹង (គឺស្រា...) និងល្បែងស៊ីសង ។ ចូរអ្នកថ្លែង [ប្រាប់ពួកគេ]ថា៖ "ទាំងពីរនេះមានបាបធំ ហើយមានប្រយោជន៍ខ្លះសម្រាប់បណ្តាមនុស្ស តែបាបរបស់វាទាំងពីរនេះធំជាងផលប្រយោជន៍របស់វាទាំងពីរ ។" ពួកគេសួរអ្នកអំពីអ្វីដែលពួកគេត្រូវចាយវាយ ។ ចូរអ្នកប្រាប់ថា៖ "អ្វីដែលលើស[ពីត្រូវការ]" ។ បែបនេះឯងដែលអល់ឡោះប្រាប់អធិប្បាយបំភ្លឺអំពីបណ្តាសញ្ញា [និងបណ្តាឱង្ការ] ដល់ពួកអ្នក ដើម្បីពួកអ្នកនឹងត្រិះរិះ ។* (ស៊ូរ៉ោះត៍ អាល់-បាក៏រ៉ោះត៍ អាយ៉ាស់ 219 (2:219))

និយាយអំពីតន្ត្រីវិញ ។ មានផលអាក្រក់អ្វីក្នុងតន្ត្រីនោះ ?

តន្ត្រីប៉ះពាល់ដល់ខ្លួននិងដល់អារម្មណ៍ ។ ឥទ្ធិពលវានៅលើប្រភេទតន្ត្រី ។

ពេលស្តាប់តន្ត្រីមួយប្រភេទ ផ្អែមល្ហែម ធ្វើឲ្យស្រាកស្រាន្ត គេបណ្តោយខ្លួនបណ្តែតអារម្មណ៍ គេបិទភ្នែក បណ្តោយឲ្យតន្ត្រីជ្រាបចូលទៅក្នុងខ្លួន ។ ធ្វើឲ្យបេះបូងលោត សញ្ញាចរន្តអគ្គិសនីក្នុងខ្លួនចាប់ផ្តើមរត់តាមចង្វាក់តន្ត្រី វាអាចធ្វើឲ្យខូចសណ្តាប់ធ្នាប់បាន ។

ដោយសារតន្ត្រីច្រើនប្រភេទទៀត អារម្មណ៍ស្ទើរតែត្រូវសណ្តំ ។ ញឹកញយណាស់ ពេលនៅក្រោមឥទ្ធិពលតន្ត្រីខ្លាំងៗដែលគេឮនៅក្នុងរង្គសាលនិងក្នុងបុណ្យមនុស្សរាំនិងកម្រើករាងកាយតាមចង្វាក់តន្ត្រី ។ ទីបំផុតវាធ្វើឲ្យពួកគេលែងគ្រប់គ្រងណាហ្វ៊ស៍ខ្លួនឯងបាន ដូច្នេះពួកគេរាំជាមួយគ្នា ខ្លួនប្រកិតគ្នា បាត់បង់ការខ្មាសអៀន ដោយគិតដល់ទង្វើផ្សេងៗនិងដោយចង់ប្រព្រឹត្តអំពើផ្សេងៗតាមចំណង់មិនគប្បី ។

តន្ត្រីប្រភេទនេះដែរដែលធ្វើឲ្យមនុស្សផ្តុំគ្នាជាក្រុម លែងគ្រប់គ្រងទង្វើនិងចិត្តខ្លួនឯងបានព្រោះតែនៅក្រោមឥទ្ធិពលតន្ត្រី ។

តន្ត្រីក្លាយទៅជាគ្រឿងញៀន ។ គេត្រូវការវាកាន់តែខ្លាំងឡើង ពិបាកផ្តាច់ណាស់ ។ ដើម្បីឲ្យវាមានប្រសិទ្ធភាពដូចគ្នា គេស្តាប់តន្ត្រីខ្លាំងឡើងៗ បណ្តាលឲ្យជះឥទ្ធិពលអាក្រក់ទៅលើត្រចៀក ថែមទាំងអាចមានផលវិបត្តិធ្ងន់ទៅដល់ប្រព័ន្ធ

សរសៃប្រសាទ ។

មូលហេតុធំបំផុតមួយគឺឥទ្ធិពលដែលតន្ត្រីជះទៅលើសង្គម ។ យុវជនច្រើនដែលធំនៅឯប៉ែកខាងលិចយកក្រុមតន្ត្រីករជាតម្រាប់ ។ គេឃើញពួកគេបិទរូបថតក្រុមតន្ត្រីករទាំងនេះនៅក្នុងបន្ទប់ដេក នៅលើសំលៀកបំពាក់ ពួកគេផ្លាស់ប្តូរអាកប្បកិរិយាដើម្បីធ្វើតាមបុគ្គលជាទីសក្ការៈទាំងនេះ ។ ពេលគេឃើញទិដ្ឋភាពនៅឯកន្លែងប្រជុំតន្ត្រី (មនុស្សស្រែកនិងរាំ) គេគិតដល់អំណាចតន្ត្រីលើចិត្តនិងខ្លួនប្រាណរបស់មនុស្ស ។

អកុសល សង្គមដែលយើងរស់នៅប្រៀបធៀបសេចក្តីរីករាយនឹងអ្វីដែលធ្វើឲ្យអ្នកភ្លេចពិភពលោក ។ តន្ត្រី គ្រឿងស្រវឹង គ្រឿងញៀន ។ វត្ថុទាំងអស់នេះមានកត្តារួមពីរគឺៈ

១) វាជាផ្លូវរត់គេចពីការពិត ។

២) វាធ្វើឲ្យញៀន ។ តើវាចង់ប្រាប់អ្នកថាអ្វីអំពីកម្រិតសំណព្វចិត្តក្នុងជីវិតសាមញ្ញ ?

អ្នកច្រៀងនិងក្រុមតន្ត្រីករច្រើន ប្រើតន្ត្រីដើម្បីដាស់ចំណង់ដែលត្រូវនៅក្រោមការគ្រប់គ្រង ។ ពេលសម្តែង ក្រុមតន្ត្រីករច្រើនធ្វើកាយវិការមិនសមរម្យបង្ហាញបុរសនិងស្ត្រីស្លៀកពាក់ធ្វើឲ្យស្រើបនៅលើឆាកឬនៅក្នុងវីឌីអូ ។ ទាំងអស់នេះកើតមកពីតន្ត្រី ។

តន្ត្រីតែម្យ៉ាងមានផលវិបត្តិច្រើន ពេលវាប្រើគោលគំនិតនិងឧបករណ៍ច្រើនផ្សំជាមួយផងនោះ ។ តន្ត្រីធ្វើឲ្យមានផលវិបត្តិដូចស្រាដែរ វាធ្វើឲ្យយើងលែងដឹងខ្លួនថាយើងកំពុងធ្វើអ្វី ។ យើងអាចទៅជាជ្រួលជ្រើមបើតន្ត្រីនៅជុំវិញខ្លួនយើងនោះខ្លាំងនិងសន្ធប់ ។

តន្ត្រីមិនប៉ះពាល់ទៅលើមនុស្សទាំងអស់គ្នាដូចគ្នាទេ តែវាជះផលអាក្រក់ទៅលើមនុស្សច្រើនដោយមានអត្រាភាគរយច្រើន ដូច្នេះត្រូវចាត់ទុកវាជាប្រការហាមឃាត់ ។ ទៅកាន់កន្លែងនីមួយដើម្បីស្តាប់តន្ត្រីតែម្យ៉ាងក៏ជាប្រការហាមឃាត់ដែរ ដូចជារង្គសាលជាដើម ។

ជាញឹកញយ អ្នកខ្លះថាខ្លួនស្តាប់តន្ត្រីតិចណាស់ មិនបណ្តោយខ្លួនទៅតាមតន្ត្រីនោះទេ ។ តែ ដូចគ្រឿងញៀនដែរ តន្ត្រីធ្វើឲ្យញៀន ។ បើអ្នកចាប់ផ្តើមតែបន្តិចបន្តួច ទីបំផុតអ្នកនឹងមិនអាចផ្តាច់ខ្លួនពីតន្ត្រីបានទេ ។

សំណួរបន្ទាប់ទាក់ទងនឹងតន្ត្រីដែលនៅពីក្រោយទស្សនីយភាព ឬតន្ត្រីកំដរដែលយើងឮរៀងរាល់ថ្ងៃនៅក្នុងទូរទស្សន៍ ។ល។

ពាក្យ "តន្ត្រីពីក្រោយទស្សនីយភាព ឬ តន្ត្រីកំដរ" គឺភ្លេងដែលអ្នកមិនយកចិត្តទុកដាក់ ឬដែលគេប្រើសម្រាប់រៀបរាប់ទស្សនីភាពខ្លះដូចនៅក្នុងទូរទស្សន៍ ។ ឧទាហរណ៍ ភ្លេងនៅពេលដែលធ្វើឲ្យថប់អារម្មណ៍ នៅពេលខ្លាចឬកាលៈទេសៈឯទៀត ។

មិនបានសេចក្តីថាគេអាចស្តាប់ភ្លេងកំដរបាននោះទេ ពេលគេធ្វើកិច្ចការដែលត្រូវដាក់មកឲ្យធ្វើឯផ្ទះ ឬអាចបន្ទាបសម្លេងភ្លេងបានដើម្បីនឹងអាចនិយាយគ្នាបាន ទោះបីនៅក្នុងរថយន្តក្តី នៅក្នុងភោជនីយដ្ឋានក្តី នៅឯផ្ទះក្តី ។ តន្ត្រីប្រភេទនេះហ្រាំត្រូវចៀសវាង ។

ស្តាប់និងឮខុសគ្នាច្រើន ។ ពេលគេឮអ្វីមួយ វាគ្រាន់តែជាសម្លេងទេដែលចូលក្នុងត្រចៀកអ្នក អ្នកមិនយកចិត្តទុកដាក់វាទេ ជាញឹកញយអ្នកមិនកត់សម្គាល់វាទេ ដូចជាសម្លេងខ្យល់ដែលបក់នោះ សម្លេងរថយន្ត ឬសម្លេងនិយាយគ្នា ។ល។ជាដើម ។ ពេលស្តាប់អ្វីមួយ អ្នកនៅក្នុងសកម្មភាព អ្នកកំពុងធ្វើដោយចេតនា ។

ដូច្នេះ តន្ត្រីគ្រប់ប្រភេទដែលអ្នកស្តាប់ដោយចេតនា ទោះជាតន្ត្រីកំដរក្តី ក៏លែងជា "តន្ត្រីកំដរ" នៅក្នុងន័យខាងលើនេះ ទោះបីមានសម្លេងខ្លាំងក្តីតិចក្តី ។ តន្ត្រីប្រភេទនេះទៅជាហ្រាំ ។

យើងមិនត្រឹមតែចៀសវាងស្តាប់តន្ត្រីតែម្យ៉ាងទេ តែយើងមិនត្រូវទៅកន្លែងណាដែលគេបង្កើតសម្រាប់លេងតន្ត្រី ឬកន្លែងណាដែលមនុស្សរាំតាមតន្ត្រីទេដែ ។ កន្លែងបែបនេះ ដូចជារង្គសាល (disco) ឬកន្លែងបុណ្យជាដើម ធ្វើឲ្យមនុស្សធ្វេសប្រហែសស្មារតី បណ្តោយខ្លួនប្រព្រឹត្តដោយលែងគិតដល់បាបបុណ្យ ។ ពេលរាំរែកតាមតន្ត្រី អ្នកបណ្តោយឲ្យតន្ត្រីដឹកនាំទង្វើនិងគំនិតអ្នក ។ វាអាចនាំឲ្យអ្នកប្រព្រឹត្តទង្វើអសីលធម៌ច្រើនទៀត ។

ប្រការចុងក្រោយដែលត្រូវដឹងគឺ អល់ឡោះហ្ញ៍ ﷻ ដាក់បម្រាមហ្រាំដើម្បីផលប្រយោជន៍យើង ។ យើងត្រូវព្យាយាមយល់ដឹងថាហេតុអ្វីប្រការទាំងនោះហ្រាំដោយមានហេតុផលខាងលើនេះ តែពេលក្រោយ បើយើងជាក់ក្នុងចិត្តនិងមានជំនឿ យើងត្រូវតែព្រមទទួលច្បាប់អ៊ីស្លាម ។

សំខាន់បំផុតត្រូវស្វែរខ្លួនឯងនិងយល់ជំនឿយើង តែយើងមិនត្រូវមានះរឹងរូស

ទេដោយថា៖ "ព្រោះតែអញមិនយល់ ព្រោះតែវាមិនអាចយល់បានទេ ដូច្នេះវាមិនពិតទេ ។"

អល់ឡោះហ៍ﷻជាអ្នកបង្កើតយើង ព្រះអង្គﷻនៅក្បែរយើងជាងស្បែកយើងទៅទៀត ។ យើងត្រូវដឹងថាច្បាប់របស់ព្រះអង្គﷻនោះសម្រាប់ជួយយើងដុសខាត់ចរិយាមារយាទយើងឲ្យទៅជាសុក្រឹត និងជួយយើងបំពេញមុខងារយើងជាអ្នកតំណាងព្រះអង្គﷻនៅលើផែនដីនេះ ។

ស៊ូរ៉ោះត៍ អាល់-មុមីនូន អាយ៉ាស់ 3 (23:3) ចែងថា៖

وَٱلَّذِينَ هُمۡ عَنِ ٱللَّغۡوِ مُعۡرِضُونَ ٣

*3. បណ្ដាអ្នកដែលចៀសវាងអំពើដែលឥតខ្លឹមសារ [គ្រប់បែប និងចៀសឆ្ងាយពីវាចាដែលឥតខ្លឹមសារ]*

ព្រះសន្តអ៊ីម៉ាំ អ៊ាលី ប៊ិន អាប៊ូ ត៍លិបعليه والسلام صلوات اللهមានវចនៈថា *អំពើដែលឥតខ្លឹមសារ* គឺអ្វីៗដែលគ្មានការនឹករលឹកដល់អល់ឡោះហ៍ﷻ ។ យោលតាម អាស្ហ៊ុលុល-បៃត៍ عليهم السلام ពាក្យនេះមានន័យថាការកំសាន្តដែលឥតប្រយោជន៍ ការខាតពេលវេលា រាប់បញ្ចូលការកំសាន្តតន្ត្រីនិងល្បែងឥតខ្លឹមសារសម្រាប់តែចំណាយពេលវេលាដែរ ។

## ការកត់សម្គាល់

ក. តន្ត្រីដែលលេងឬអាចលេងឯទីជួបជុំឥតខ្លឹមសារ ឬកន្លែងដែលគេប្រព្រឹត្តអំពើហ្ារ៉ាំ ត្រូវហាម (ហ្ារ៉ាំ) ។
ខ. ការច្រៀងដោយសម្លេងមនុស្សផ្ទាល់ មិនហ្ារ៉ាំទេ លើកលែងវាធ្វើឲ្យអ្នកនឹកដល់កន្លែងដែលគេប្រព្រឹត្តទង្វើហ្ារ៉ាំ ។
គ. ការប្រគំតន្ត្រីផ្គុំជាមួយសម្លេងមនុស្សត្រូវហាម (ហ្ារ៉ាំ) ។

إِنَّمَا يُرِيدُ ٱلشَّيۡطَٰنُ أَن يُوقِعَ بَيۡنَكُمُ ٱلۡعَدَٰوَةَ وَٱلۡبَغۡضَآءَ فِي ٱلۡخَمۡرِ وَٱلۡمَيۡسِرِ وَيَصُدَّكُمۡ عَن ذِكۡرِ ٱللَّهِ وَعَنِ ٱلصَّلَوٰةِۖ فَهَلۡ أَنتُم مُّنتَهُونَ ٩١

*91. ស្ទៃតនប្រាថ្នាធ្វើឲ្យពួកអ្នកមានអរិភាពនិងទោសៈរវាងពួកអ្នក តាមរយៈសុរា*

*និងល្បែងស៊ីសង ដើម្បីធ្វើឲ្យពួកអ្នកបែរចេញពីការនឹករលឹកដល់អល់ឡោះហ៍ និងបែរចេញពីការបំពេញនមស្ការ [បូជាអល់ឡោះហ៍]។ ពួកអ្នកមិនចៀសវាងទេ ?*
(ស៊ូរ៉ោះត៍ អាល់-ម៉ាអ៊ីដ្ហាស់ អាយ៉ាស់ 91 (5:91))

*sources:*
www.saba-igc.org
shia974.fr
www.madressa.net

អ៊ីម៉ាំមេម៉ាស្ហាប់ទាំង ៤ ។

| ឈ្មោះអ៊ីម៉ាំមេម៉ាស្ហាប់ | ម៉ាស្ហាប់ | ថ្ងៃកំណើត/ថ្ងៃស្លាប់ សកករាជហ៊ីជ្រ៉ោះត៍ | ថ្ងៃកំណើត/ថ្ងៃស្លាប់ គ្រិស្តសករាជ |
|---|---|---|---|
| អាប៊ូ ហាានីហ្វាស់ | ហាណាហ្វី | 80-150 ស.ហ. | 699-767 គ.ស. |
| ម៉ាលិក | ម៉ាលីគី | 93-179 ស.ហ | 711-795 គ.ស. |
| អាស់-ស្ហាហ្វីអ៊ី | ស្ហាហ្វីអ៊ី | 150-204 ស.ហ | 767-820 គ.ស. |
| អាស់ម៉ាដ់ ហាន់បាល់ | ហាន់បាលី | 164-241 ស.ហ. | 780-855 គ.ស. |

ព្រះសាសា មូហាំម៉ាដ់ ប្រសូត/ចូលព្រះទិវង្គត ឆ្នាំ 570-632 គ.ស. ប្រសូតថ្ងៃសុក្រ ទី ១៧ ខែ របីអ៊ុល អាវ៉ាល់ ឆ្នាំដំរី សោយទិវង្គតថ្ងៃទី ២៨ ខែ ស្វហ្វារ ឆ្នាំ ១១ សកករាជហ៊ីជ្រ៉ោះត៍ ។

អ៊ីម៉ាំអ្នកស្នងព្រះសាស្តាមូហាំម៉ាដ់ﷺទាំង ១២ ។

| លំដាប់ | ឈ្មោះ | ឈ្មោះក្រៅ | ហាននួរស័ក្តិ | ថ្ងៃកំណើត/ថ្ងៃស្លាប់ គ.ស./ស.ហ. |
|---|---|---|---|---|
| 1 | អាលី | អាប៊ូ អាល់-ហាសាន់ | អាមីរុល-មុមីនីន | 600-661/23 មុន ស.ហ.-40 |
| 2 | ហាសាន់ | អាប៊ូ មូហាំម៉ាដ់ | អាល់-មុជ្តាបា | 625-670/3-50 |
| 3 | ហ៊ូសែន៍ | អាប៊ូ អាប់ឌុលឡោះហ្វ៍ | សៃយីដូ អាស់-ស្ហុហាដាអ៊ុ | 626-680/4-61 |
| 4 | អាលី ប៊ិន ហ៊ូសែន៍ | អាប៊ូ មូហាំម៉ាដ់ | អាស់-សាជ្ជ៉ាដ់ ស្សៃនុល-អាប៊ីឌីន | 659-713/38-95 |
| 5 | មូហាំម៉ាដ់ អាល់-បាកៀរ | អាប៊ូ យ៉ាក្កុហ្វារ | បាកៀរ អាល់-អ៊ូលូម | 676-733/57-114 |
| 6 | យ៉ាក្កុហ្វារ | អាប៊ូ អាប់ឌុលឡោះហ្វ៍ | អាស់-ស្វឌិក្ | 702-765/83-148 |
| 7 | មូសា ប៊ិន យ៉ាក្កុហ្វារ | អាប៊ូ អាល់-ហាសាន់ | អាល់-កាស្ហ៊ីម | 745-799/128-183 |
| 8 | អាលី ប៊ិន មូសា | អាប៊ូ អាល់-ហាសាន់ | អារ-រីដ្ហ៍ | 765-819/148-203 |
| 9 | មូហាំម៉ាដ់ ប៊ិន អាលី | អាប៊ូ យ៉ាក្កុហ្វារ | អាត់-តាគ្គី អាល់-យ៉ាវ៉ាដ់ | 811-835/195-220 |
| 10 | អាលី ប៊ិន មូហាំម៉ាដ់ | អាប៊ូ អាល់-ហាសាន់ | អាល់-ហាឌី អាន់-ណាគ្គី | 828-868/212-254 |
| 11 | ហាសាន់ ប៊ិន អាលី | អាប៊ូ មូហាំម៉ាដ់ | អាល់-អាស់ការី | 846-874/232-260 |
| 12 | មូហាំម៉ាដ់ ប៊ិន ហាសាន់ | អាប៊ូ ក៉ស៊ីម | អាល់-ម៉ាស្ឌី អាល់-ហ៊ុជ្ជ៉ាស់ ស្វហ៊ីប អាល់-ស្សាម៉ាន អាល់-ក៉អ៊ីម | 869/255 |